# វិញ្ញាសាគណិតវិទ្យា

## ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

គិតច្រើន ចេះច្រើន

## ឆ្នាំ២០១៨


រៀបរៀងដោយ

**លឹម សីហា**

គ្រូគណិតវិទ្យាវិទ្យាល័យសម្តេចឪ

ខេត្ត សៀមរាប

# អារម្ភកថា

ការបង្កើតសៀវភៅវិញ្ញាសា និងដំណោះស្រាយ នេះឡើងក្នុងគោលបំណងទុកជាឯកសារ សម្រាប់សិស្សានុសិស្ស កម្រិតវិទ្យាល័យសិក្សា អនុវត្តន៍ លំហាត់វិញ្ញាសាគណិតវិទ្យា ដើម្បីត្រៀមសម្រាប់ការប្រឡងយកសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ។

ចំពោះសៀវភៅវិញ្ញាសានេះផងដែរ បើមាននូវចំណុចខ្វះខាត ឬខុសឆ្គងត្រង់ចំណុចណា សូមបងប្អូន សិស្សានុសិស្ស មិត្តអ្នកអាន មេត្តាអធ្យាស្រ័យ ដោយកំហុសអចេតនារបស់ខ្ញុំបាទ។

សៀមរាប ១៥ សីហា ២០១៨

លីម សីហា .

លីម សីហា

# មាតិកា


វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨ 2

វិញ្ញាសាទី១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 2

វិញ្ញាសាទី២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 15

វិញ្ញាសាទី៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 26

វិញ្ញាសាទី៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 38

វិញ្ញាសាទី៥ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 49

វិញ្ញាសាទី៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 59

វិញ្ញាសាទី៧ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 71

វិញ្ញាសាទី៨ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 82

វិញ្ញាសាទី៩ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 93

វិញ្ញាសាទី១០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 104

វិញ្ញាសាទី១១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 115

វិញ្ញាសាទី១២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 128

វិញ្ញាសាទី១៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 139

វិញ្ញាសាទី១៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 151

វិញ្ញាសាទី១៥ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 162

វិញ្ញាសាទី១៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 172

វិញ្ញាសាទី១៧ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 184

វិញ្ញាសាទី១៨ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 195

វិញ្ញាសាទី១៩ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 206

វិញ្ញាសាទី២០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 217


លីម សីហា

# វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡង
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨

## [វិញ្ញាសាទី១]

I. (១០ពិន្ទុ) គណនាលីមីត៖

១. $\lim\limits_{x\to 0} \dfrac{\sin x + e^x - 1}{x^2 + x}$  ២. $\lim\limits_{x\to +\infty} \dfrac{\ln x + 2}{x+1}$

II. (១៥ពិន្ទុ)

១. កំណត់ចំនួនពិត $x$ និង $y$ ដើម្បីឲ្យ $2xi - y = \dfrac{(3-2i)(1+i)}{i(1+2i)}$ ។

២. គេឲ្យ $Z = \cos\dfrac{2\pi}{9} + i\sin\dfrac{2\pi}{9}$ ។ សរសេរ $(1+Z)^4$ ជាទម្រង់ត្រីកោណមាត្រ។

III. (១៥ពិន្ទុ)

១. កំណត់ចំនួនពិត $a, b$ និង $c$ ដើម្បីឲ្យបាន $\dfrac{x^2-2x-2}{(x-1)^2(x+2)} = \dfrac{a}{x-1} + \dfrac{b}{(x-1)^2} + \dfrac{c}{x+2}$ ចំពោះ $x \neq -2,\ x \neq 1$ ។

២. គណនាអាំងតេក្រាល $I = \displaystyle\int_{-1}^{0} \left(\frac{x^2-2x-2}{(x-1)^2(x+2)}\right)dx$ ។

IV. (១៥ពិន្ទុ)

១. ដោះស្រាយសមីការ $y'' - 6y' + 8y = 0 \ \ (\alpha)$ ។

២. រកអនុគមន៍ $g$ ដែលជាចម្លើយមួយនៃ $(\alpha)$ ដោយដឹងថាក្រាប $G$ របស់វាប៉ះនឹងបន្ទាត់ដេកមួយនៅត្រង់ $E(0,-1)$។

V. (១៥ពិន្ទុ)

១. រកកូអរដោនេនៃផ្ចិត កំពូល និងកំណុំនៃអេលីប $(E)$ : $4x^2 + 9y^2 - 8x + 36y + 4 = 0$ ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន$\left(O, \vec{i}, \vec{j}, \vec{k}\right)$។

២. រកកូអរដោនេនៃចំណុចប្រសព្វរវាង $(E)$ និងអ័ក្សទាំងពីរនៃតម្រុយហើយសង់អេលីប $(E)$។ ដោយយក $\dfrac{4\sqrt{2}}{3} = 1.9$ ។

VI. (២០ពិន្ទុ) នៅក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O, \vec{i}, \vec{j}, \vec{k}\right)$ គេឲ្យចំណុច $A(0,2,2)$ និង បន្ទាត់D ដែលមានសមីការប៉ារ៉ាម៉ែត $x = 1+t,\ y = 1-t,\ z = 2-t,\ t \in \mathbb{R}$ ។

១. បង្ហាញថាប្លង់ $P:\ x-y-z+4=0$ កាត់តាមចំណុច A ហើយកែងនឹងបន្ទាត់ D ។

២. ប្លង់ (P) កាត់អ័ក្ស Ox ត្រង់ M, Oy ត្រង់ N និង Oz ត្រង់ P ។ រកកូអរដោនេនៃចំណុច M, N និង P រួចសង់ចំណុច A, M, N, P នៅក្នុងតម្រុយ $\left(O, \vec{i}, \vec{j}, \vec{k}\right)$ ។

៣. បង្ហាញថាត្រីកោណ MNP ជាត្រីកោណសម័ង្ស។

៤. គណនា $\overrightarrow{MP} \times \overrightarrow{MN}$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ MNP ។

VII. (៣៥ពិន្ទុ)

១. f ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដោយ $f(x) = (1-x)e^x - 1$ ។ គណនា $f'(x)$ ។
សង់តារាងអថេរភាពនៃអនុគមន៍ f (ដោយមិនចាំបាច់គណនាលីមីតត្រង់ $-\infty$ និង $+\infty$ ) ។
ទាញរកសញ្ញានៃ $f(x)$ ។

២. g ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដោយ $g(x) = (2-x)e^x + 2 - x$ ។

ក. គណនា $\lim\limits_{x\to-\infty} g(x)$ និង $\lim\limits_{x\to+\infty} g(x)$ ។ គណនា $g'(x)$ ។ ដោយប្រើលទ្ធផលដែលបាននៅសំណួរ១. ចូរសិក្សាសញ្ញានៃ $g'(x)$ រួចសង់តារាងអថេរភាពនៃអនុគមន៍ g ។

ខ. បង្ហាញថាខ្សែកោង C តាងអនុគមន៍ g មានបន្ទាត់ $D:\ y = 2-x$ ជាអាស៊ីមតូតទ្រេត កាលណា x ខិតជិត $-\infty$ ។ បញ្ជាក់ទីតាំងនៃខ្សែកោង C ធៀបនឹងបន្ទាត់ D ។

គ. កំណត់សមីការបន្ទាត់ប៉ះនឹងខ្សែកោង C ដែលស្របនឹងបន្ទាត់ D ។

ឃ. រកកូអរដោនេនៃចំណុចរបត់របស់ខ្សែកោង C ។

ង. សង់ខ្សែកោង C ក្នុងតម្រុយអរតូណរម៉ាល់ $\left(O, \vec{i}, \vec{j}\right)$ ។ (ឯកតាលើអ័ក្សស្មើនឹង 1cm )។

## [ដំណោះស្រាយ]

I. គណនាលីមីត៖

១. $\lim\limits_{x\to 0}\dfrac{\sin x + e^x - 1}{x^2 + x}$ មានរាងមិនកំណត់ $\dfrac{0}{0}$

$$= \lim_{x\to 0}\frac{\frac{\sin x + e^x - 1}{x}}{\frac{x^2+x}{x}} = \lim_{x\to 0}\frac{\frac{\sin x}{x} + \frac{e^x-1}{x}}{x+1} = \frac{1+1}{0+1} = 2$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{\sin x + e^x - 1}{x^2 + x} = 2}$

២. $$\lim_{x\to+\infty}\frac{\ln x + 2}{x+1} = \lim_{x\to+\infty}\frac{\ln x}{x}\cdot\left(\frac{1+\frac{2}{\ln x}}{1+\frac{1}{x}}\right) = 0\left(\frac{1+0}{1+0}\right) = 0(1) = 0$$

ដូចនេះ $\boxed{\lim\limits_{x\to+\infty}\dfrac{\ln x + 2}{x+1} = 0}$

II. ១. កំណត់ចំនួនពិត x និង y

$$2xi - y = \frac{(3-2i)(1+i)}{i(1+2i)} \quad\Leftrightarrow\quad 2xi - y = \frac{3+3i-2i-2i^2}{i+2i^2}$$

$$2xi - y = \frac{(5+i)(i+2)}{(i-2)(i+2)}$$

$$2xi - y = \frac{5i+10+i^2+2i}{i^2-4}$$

$$2xi - y = -\frac{7}{5}i - \frac{9}{5}$$

$$\Longrightarrow \begin{cases} 2x = -\frac{7}{5} \Rightarrow x = -\frac{7}{10} \\ -y = -\frac{9}{5} \Rightarrow y = \frac{9}{5} \end{cases}$$

លឹម សីហា

ដូចនេះ $\boxed{x = -\dfrac{7}{10};\ y = \dfrac{9}{5}}$

២. សរសេរ $(1+Z)^4$ ជាទម្រង់ត្រីកោណមាត្រ

យើងមាន $Z = \cos\dfrac{2\pi}{9} + i\sin\dfrac{2\pi}{9}$

$$(1+Z)^4 = \left(1+\cos\frac{2\pi}{9} + i\sin\frac{2\pi}{9}\right)^4 = \left(2\cos^2\frac{\pi}{9} + i2\sin\frac{\pi}{9}\cos\frac{\pi}{9}\right)^4$$

$$= \left(2\cos\frac{\pi}{9}\left(\cos\frac{\pi}{9} + i\sin\frac{\pi}{9}\right)\right)^4 = 2^4\cos^4\frac{\pi}{9}\left(\cos\frac{4\pi}{9} + i\sin\frac{4\pi}{9}\right)$$

ដូចនេះ $\boxed{(1+Z)^4 = 16\cos^4\frac{\pi}{9}\left(\cos\frac{4\pi}{9} + i\sin\frac{4\pi}{9}\right)}$

III. ១. ដោះស្រាយសមីការ $y'' - 6y' + 8y = 0 \ (\alpha)$

$(\alpha)$ មានសមីការសម្គាល់ $r^2 - 6r + 8 = 0$

$\Delta = b^2 - 4ac = (-6)^2 - 4(1)(8) = 36 - 32 = \quad \Rightarrow \sqrt{\Delta} = 2$

$$r_1 = \frac{-b - \sqrt{\Delta}}{2a} = \frac{-(-6) - 2}{2(1)} = \frac{4}{2} = 2$$

$$r_2 = \frac{-b - \sqrt{\Delta}}{2a} = \frac{-(-6) + 2}{2(1)} = \frac{8}{2} = 4$$

ដូចនេះ $\boxed{\text{ចម្លើយទូទៅនៃសមីការ } (\alpha) \text{ គឺ } y = Ae^{2x} + Be^{4x} \quad ; A, B \in \mathbb{R}}$

២. រកអនុគមន៍ $g$ ដែលជាចម្លើយមួយនៃ $(\alpha)$ បើក្រាប $G$ របស់វាប៉ះនឹងបន្ទាត់ដេកមួយនៅត្រង់ $E(0,-1)$

យើងមាន ចម្លើយទូទៅនៃសមីការ $(\alpha)$ គឺ $y = Ae^{2x} + Be^{4x} \quad ; A, B \in \mathbb{R}$

ដោយក្រាប $G$ របស់វាប៉ះនឹងបន្ទាត់ដេកមួយនៅត្រង់ $E(0,-1)$ យើងបាន

- $y(0) = -1 \quad \Rightarrow Ae^0 + Be^0 = -1 \quad \Rightarrow \quad A + B = -1 \ (1)$
- បន្ទាត់ប៉ះជាបន្ទាត់ដេក នាំឲ្យ មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះត្រង់ចំណុច $(0,-1)$ ស្មើសូន្យ
  $y'(0) = 0$ ដោយ $y' = 2Ae^{2x} + 4Be^{4x} \Rightarrow 2Ae^0 + 4Be^0 = 0 \Rightarrow 2A + 4B = 0 \ (2)$

$(2): \ A + B = -1 \ \Rightarrow \ A = -1 - B$ ជួសក្នុង $(2) \ \Rightarrow \ 2(-1-B) + 4B = 0 \Rightarrow B = 3$

$B = 3 \quad \Rightarrow A = -1 - 3 = -4$

ដូចនេះ $\boxed{\text{ចម្លើយពិសេសមួយនៃ } (\alpha) \text{ គឺ } y = -4e^{2x} + 3e^{3x}}$

IV. ១. រកកូអរដោនេនៃផ្ចិត កំពូល និងកំណុំនៃអេលីប $(E): \ 4x^2 + 9y^2 - 8x + 36y + 4 = 0$

$(E): 4x^2 + 9y^2 - 8x + 36y + 4 = 0$

$\Leftrightarrow 4\left(x^2 - 2x + 1\right) - 4 + 9\left(y^2 + 4y + 4\right) - 9(4) + 4 = 0$

$\Leftrightarrow 4(x-1)^2 + 9(y+2)^2 = 36$

$$\Leftrightarrow \frac{4(x-1)^2}{36} + \frac{9(y+2)^2}{36} = \frac{36}{36}$$

$$\Leftrightarrow \frac{(x-1)^2}{9} + \frac{(y+2)^2}{4} = 1$$

$$\Leftrightarrow \frac{(x-1)^2}{3^2} + \frac{(y+2)^2}{2^2} = 1$$

យើងបាន

- អ័ក្សធំនៃអេលីប ជាអ័ក្សដេក
- $h = 1,\ k = -2 \quad ;\ a = 3,\ b = 2 \quad ;\ c^2 = a^2 - b^2 = 9 - 4 = 5 \qquad \Rightarrow c = \sqrt{5}$
- ផ្ចិត$(h, k)$ $\Rightarrow$ ផ្ចិត$(1, -2)$
- កំពូល $V_1(h-a, k);\ V_2(h-a, k)$ $\Rightarrow$ កំពូល $V_1(-2, -2);\ V_2(4, -2)$
- កំណុំ $F_1(h-c, k);\ F_2(h+c, k)$ $\Rightarrow$ កំណុំ $F_1(1-\sqrt{5}, -2);\ F_2(1+\sqrt{5}, -2)$

២. រកកូអរដោនេនៃចំណុចប្រសព្វរវាង (E) និងអ័ក្សទាំងពីរនៃតម្រុយហើយសង់អេលីប (E)

- $(E) \cap (x'ox) \Leftrightarrow y = o \quad \Rightarrow \frac{(x-1)^2}{9} + \frac{(0+2)^2}{4} = 1$

$$\frac{(x-1)^2}{9} = 0$$

$$(x-1)^2 = 0$$

$$(x-1)(x-1) = 0 \qquad \Rightarrow x_1 = x_2 = 1$$

ដូចនេះ (E) កាត់អ័ក្សអាប់ស៊ីសត្រង់ $x = 1$

$(E) \cap (y'oy) \Leftrightarrow x = 0 \quad \Rightarrow \frac{(0-1)^2}{9} + \frac{(y+2)^2}{4} = 1$

$$\frac{1}{9} + \frac{(y+2)^2}{4} = 1$$

$$\frac{(y+2)^2}{4} = \frac{8}{9}$$

$$(y+2)^2 = \frac{32}{9}$$

$$y + 2 = \pm\sqrt{\frac{32}{9}}$$

$$y = -2 \pm \frac{4\sqrt{2}}{3} = -2 \pm 1.9$$

$$\Rightarrow \quad y_1 = -2 + 1.9 = -0.1$$

$$y_2 = -2 - 1.9 = -3.9$$

ដូចនេះ (E) កាត់អ័ក្សអរដោនេត្រង់ $y = -0.1$ និង $y = -3.9$

សង់អេលីប




V. ១. កំណត់ចំនួនពិត a, b និង c ដើម្បីឲ្យបាន $\frac{x^2-2x-2}{(x-1)^2(x+2)} = \frac{a}{x-1} + \frac{b}{(x-1)^2} + \frac{c}{x+2}$

$$\frac{x^2-2x-2}{(x-1)^2(x+2)} = \frac{a}{x-1} + \frac{b}{(x-1)^2} + \frac{c}{x+2}$$

$$= \frac{a(x-1)(x+2) + b(x+2) + c(x-1)^2}{(x-1)^2(x+2)}$$

$$= \frac{ax^2 + 2ax - ax - 2a + bx + 2b + cx^2 - 2cx + c}{(x-1)^2(x+2)}$$

$$= \frac{(a+c)x^2 + (a+b-2c) + (-2a+2b+c)}{(x-1)^2(x+2)}$$

$$\Longrightarrow \begin{cases} a + c = 1 & (1) \\ a + b - 2c = -2 & (2) \\ -2a + 2b + c = -2 & (3) \end{cases}$$

(1) $\Rightarrow a = 1 - c$ ជំនួសក្នុង (2) $\Rightarrow 1 - c + b - 2c = -2 \Rightarrow b = 3c - 3$

យក $a = 1 - c$ និង $b = 3c - 3$ ជំនួសក្នុង (3) យើងបាន

$$\begin{aligned}
-2(1-c) + 2(3c-3) + c = -2 \quad &\Leftrightarrow \quad -2 + 2c + 6c - 6 + c = -2 \\
&\Rightarrow \quad c = \frac{2}{3} \\
&\Rightarrow \quad a = 1 - c = 1 - \frac{2}{3} = \frac{1}{3} \\
&\Rightarrow \quad b = 3c - 3 = 3\frac{2}{3} - 3 = -1
\end{aligned}$$

ដូចនេះ $\boxed{a = \frac{1}{3},\ b = -1,\ c = \frac{2}{3}}$

២. គណនាអាំងតេក្រាល $I = \int_{-1}^{0} \left( \frac{x^2 - 2x - 2}{(x-1)^2(x+2)} \right) dx$

$$\frac{x^2 - 2x - 2}{(x-1)^2(x+2)} = \frac{a}{x-1} + \frac{b}{(x-1)^2} + \frac{c}{x+2} = \frac{\frac{1}{3}}{x-1} - \frac{1}{(x-1)^2} + \frac{\frac{2}{3}}{x+2}$$

$$\begin{aligned}
I = \int_{-1}^{0} \left( \frac{x^2 - 2x - 2}{(x-1)^2(x+2)} \right) dx &= \int \left( \frac{\frac{1}{3}}{x-1} - \frac{1}{(x-1)^2} + \frac{\frac{2}{3}}{x+2} \right) dx \\
&= \left[ \frac{1}{3} \ln|x-1| - \frac{-1}{x-1} + \frac{2}{3} \ln|x+2| \right]_{-1}^{0} \\
&= \frac{1}{3} \ln 1 - 1 + \frac{2}{3} \ln 2 - \left( \frac{1}{3} \ln 2 - \frac{1}{2} + \frac{2}{3} \ln 1 \right) \\
&= -1 + \frac{2}{3} \ln 2 - \frac{1}{3} \ln 2 + \frac{1}{2} \\
&= \frac{\ln 2}{3} - \frac{1}{2}
\end{aligned}$$

ដូចនេះ $\boxed{I = \frac{\ln 2}{3} - \frac{1}{2}}$

VI. ១. បង្ហាញថាប្លង់ P កាត់តាមចំណុច A ហើយកែងនឹងបន្ទាត់ D

- P កាត់តាមចំណុច A លុះត្រាតែ ចំណុច A ផ្ទៀងផ្ទាត់ នឹងប្លង់ P
- P កែងនឹងបន្ទាត់ D លុះត្រាតែ វិចទ័រណរម៉ាល់ $\vec{n}$ ស្របនឹងវិចទ័រប្រាប់ទិស $\vec{u}$ នៃបន្ទាត់ D

យើងមាន $A(0,2,2)$

$P:\ x-y-z+4=0 \quad \Rightarrow$ វ៉ិចទ័រណរម៉ាល់នៃប្លង់P គឺ $\vec{n}\,(1,-1,-1)$

$D: x=1+t,\ y=1-t,\ z=2-t \quad \Rightarrow$ វ៉ិចប្រាប់ទិសនៃ បន្ទាត់D គឺ $\vec{u}\,(1,-1,-1)$

យក $A(0,2,2)$ ជួសក្នុង ប្លង់P យើងបាន $0-2-2+4=0$ ពិត $\Rightarrow$ P កាត់តាម A

$\vec{n}=\vec{u} \Rightarrow \vec{n} \mathbin{/\mkern-5mu/} \vec{u} \quad \Rightarrow$ P កែងនឹងបន្ទាត់ D

ដូចនេះ **ប្លង់P កាត់តាមចំនុច A ហើយកែងនឹងបន្ទាត់ D**

២. រកកូអរដោនេនៃចំណុច $M, N$ និង $P$

- ប្លង់ (P) កាត់អ័ក្ស Ox ត្រង់ M យើងបាន $y=0; z=0 \Rightarrow x-0-0+4=0 \Rightarrow x=-4$

  ដូចនេះ **$M(-4,0,0)$**

- ប្លង់ (P) កាត់អ័ក្ស Oy ត្រង់ N យើងបាន $x=0, z=0 \Rightarrow 0-y-0+4=0 \Rightarrow y=4$

  ដូចនេះ **$N(0,4,0)$**

- ប្លង់ (P) កាត់អ័ក្ស Oz ត្រង់ P យើងបាន $x=0, y=0 \Rightarrow 0-0-z+4=0 \Rightarrow z=4$

  ដូចនេះ **$P(0,0,4)$**

លឹម សីហា

សង់ចំណុច $A, M, N, P$



៣. បង្ហាញថាត្រីកោណ MNP ជាត្រីកោណសម័ង្ស

$M(-4,0,0)$ ; $N(0,4,0)$ ; $P(0,0,4)$

- $MN = \sqrt{(0+4)^2+(4-0)^2+(0-0)^2} = 4\sqrt{2}$
- $MP = \sqrt{(0+4)^2+(0-0)^2+(4-0)^2} = 4\sqrt{2}$
- $NP = \sqrt{(0-0)^2+(0-4)^2+(4-0)^2} = 4\sqrt{2}$

ដោយ ប្រវែង $MN = MP = NP = 4\sqrt{2}$ ដូចនេះ $\boxed{\Delta MNP \text{ ជាត្រីកោណសម័ង្ស}}$

៤. គណនា $\overrightarrow{MP} \times \overrightarrow{MN}$

- $\overrightarrow{MP}(0+4, 0-0, 4-0) \quad \Rightarrow \overrightarrow{MP}(4,0,4)$
- $\overrightarrow{MN}(0+4, 4-0, 0) \quad \Rightarrow \overrightarrow{MN}(4,4,0)$

$$\overrightarrow{MP} \times \overrightarrow{MN} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 4 & 0 & 4 \\ 4 & 4 & 0 \end{vmatrix} = (0-16)\,\vec{i} - (0-16)\,\vec{j} + (16-0)\,\vec{k}$$

$$= -16\,\vec{i} + 16\,\vec{j} + 16\,\vec{k}$$

ដូចនេះ $\boxed{\overrightarrow{MP} \times \overrightarrow{MN} = -16\,\vec{i} + 16\,\vec{j} + 16\,\vec{k}}$

ទាញរកផ្ទៃក្រឡានៃត្រីកោណ MNP

$$S_{\Delta MNP} = \frac{1}{2}\left|\overrightarrow{MP} \times \overrightarrow{MN}\right| = \frac{1}{2}\sqrt{(-16)^2+(16)^2+(16)^2} = \frac{16}{2}\sqrt{3} = 8\sqrt{3}$$

ដូចនេះ $\boxed{S_{\Delta MNP} = 8\sqrt{3} \text{ ឯកតាផ្ទៃ}}$

VII. ១. គណនា $f'(x)$

$f(x) = (1-x)e^x - 1$

$$f'(x) = ((1-x)\,e^x - 1)' = (1-x)'\,e^x + (e^x)'\,(1-x) = -e^x + e^x - xe^x = -xe^x$$

ដូចនេះ $\boxed{f'(x) = -xe^x}$

លីម សីហា

សង់តារាងអថេរភាពនៃអនុគមន៍ $f$

- $f'(x) = -xe^x$ ដោយ $e^x > 0 \quad \forall x \in \mathbb{R} \Rightarrow f'(x)$ មានសញ្ញាតាម $-x$
- $f'(x) = 0 \Leftrightarrow -x = 0 \quad \Rightarrow x = 0$
- $f'(x) > 0 \Leftrightarrow -x > 0 \quad \Rightarrow x < 0$
- $f'(x) < 0 \Leftrightarrow -x < 0 \quad \Rightarrow x > 0$
- $f(0) = (1-0)e^0 - 1 = 0$

តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | | ↗ | $0$ | ↘ | |

លឹម សីហា

ទាញរកសញ្ញានៃ $f(x)$

តាមតារាងអថេរភាព $f$ មានតម្លៃអតិបរមាធៀបមួយ ដែលមានតម្លៃស្មើ $0$

ដូចនេះ $\boxed{f(x) \leq 0 \quad \forall x \in \mathbb{R}}$

២. ក. គណនា $\lim\limits_{x \to -\infty} g(x)$ និង $\lim\limits_{x \to +\infty} g(x)$

$g(x) = (2-x)e^x + 2 - x$

- $\lim\limits_{x \to -\infty} g(x) = \lim\limits_{x \to -\infty} ((2-x)e^x + 2 - x) = 0 + 2 - (-\infty) = +\infty$

ដូចនេះ $\boxed{\lim\limits_{x \to +\infty} f(x) = +\infty}$

- $\lim\limits_{x \to +\infty} g(x) = \lim\limits_{x \to +\infty} ((2-x)e^x + 2 - x) = -\infty + 2 - (+\infty) = -\infty$

ដូចនេះ $\boxed{\lim\limits_{x \to -\infty} f(x) = -\infty}$

គណនា $g'(x)$

$$g'(x) = ((2-x)e^x + 2 - x)' = (2-x)' \, e^x + (e^x)' \, (2-x) - 1 = -e^x + 2e^x - xe^x - 1$$

$$= e^x - xe^x - 1 = (1-x) \, e^x - 1$$

ដូចនេះ $\boxed{g'(x) = (1-x)\,e^{x} - 1}$

សិក្សាសញ្ញានៃ $g'(x)$

ដោយ $g'(x) = (1-x)\,e^{x} - 1 = f(x)$ តាមលទ្ធផលដែលបាននៅសំណួរ១.

$f(x) \leq 0 \quad \Rightarrow g'(x) \leq 0 \quad \forall x \in \mathbb{R}$

$f(0) = 0 \quad \Rightarrow g'(0) = 0$

សង់តារាងអថេរភាពនៃអនុគមន៍ $g$

- $g(0) = (2-0)e^{0} + 2 - 0 \quad \Rightarrow g(0) = 4$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $g'(x)$ | | $-$ | $0$ | $-$ | |
| $g(x)$ | $+\infty$ | ↘ | $4$ | ↘ | $-\infty$ |

២. បង្ហាញថា $D:\ y = 2 - x$ ជាអាស៊ីមតូតទ្រេត កាលណា $x$ ខិតជិត $-\infty$

$g(x) = (2-x)\,e^{x} + 2 - x$ ដោយ $\lim\limits_{x \to -\infty} (2-x)\,e^{x} = 0$

ដូចនេះ បន្ទាត់ $(D):\ y = 2 - x$ ជាអាស៊ីមតូតទ្រេត (boxed)

បញ្ជាក់ទីតាំងនៃខ្សែកោង $C$ ធៀបនឹងបន្ទាត់ $D$

- $(C):\ g(x) = (2-x)e^{x} + (2-x)$
- $(D):\ y = 2 - x$

$\Rightarrow \quad g(x) - y = (2-x)e^{x}$

- $g(x) - y = 0 \quad \Leftrightarrow (2-x)e^{x} = 0 \Rightarrow 2 - x = 0 \Rightarrow -x = -2 \Rightarrow x = 2$

  ដូចនេះ ពេល $x = 2$ ក្រាប $C$ កាត់បន្ទាត់ $D$ (boxed)

- $g(x) - y > 0 \quad \Leftrightarrow (2-x)e^{x} > 0 \Rightarrow 2 - x > 0 \Rightarrow -x > -2 \Rightarrow x < 2$

  ដូចនេះ ពេល $x < 2$ ក្រាប $C$ ស្ថិតលើបន្ទាត់ $D$ (boxed)

- $g(x) - y < 0 \quad \Leftrightarrow (2-x)e^{x} < 0 \Rightarrow 2 - x < 0 \Rightarrow -x < -2 \Rightarrow x < 2$

ដូចនេះ $\boxed{\text{ត្រង់ } x < 2 \text{ ក្រាប } C \text{ ស្ថិតក្រោមបន្ទាត់ } D}$

គ. កំណត់សមីការបន្ទាត់ប៉ះនឹងខ្សែកោង C ដែលស្របនឹងបន្ទាត់ D

សមីការបន្ទាត់ប៉ះ $(T): \; y = g'(x_o)(x - x_o) + g(x_o)$

- $(T) // D: \; y = 2 - x \Rightarrow \; g'(x_o) = -1$
- $g'(x_o) = -1 \quad \Leftrightarrow (1 - x_o)e^{x_o} - 1 = -1 \quad \Rightarrow 1 - x_o = 0 \quad \Rightarrow x_o = 1$

  $g(x_o) = g(1) = (2 - 1)e^1 + 2 - 1 = e + 1$

$\Rightarrow (T): \; y = -(x - 1) + e + 1 = -x + e + 2$

ដូចនេះ $\boxed{\text{បន្ទាត់ប៉ះ គឺ } (T): \; y = -x + e + 2}$

ឃ. រកកូអរដោនេនៃចំណុចរបត់របស់ខ្សែកោង C

$$g''(x) = ((1 - x)e^x - 1)' = (1 - x)' e^x + (e^x)(1 - x) = -e^x + e^x - xe^x = -xe^x$$

- $g''(x) = -xe^x$ ដោយ $e^x > 0 \quad \forall x \in \mathbb{R} \Rightarrow g''(x)$ មានសញ្ញាតាម $-x$
- $g''(x) = 0 \Leftrightarrow -x = 0 \quad \Rightarrow x = 0$
- $g''(x) > 0 \Leftrightarrow -x > 0 \quad \Rightarrow x < 0$
- $g''(x) < 0 \Leftrightarrow -x < 0 \quad \Rightarrow x > 0$

លឹម សីហា

តារាងសញ្ញានៃ $g''(x)$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $g''(x)$ | | $+$ | $0$ | $-$ | |

- ត្រង់ $x = 0, f''(x) = 0$ ហើយប្តូរសញ្ញា យើងបាន g មានចំណុចរបត់មួយ ត្រង់ $x = 0, \; g(0) = 2 + 2 = 4$

ដូចនេះ $\boxed{\text{ចំណុចរបត់គឺ } (0, 4)}$

៦. សង់ខ្សែកោង C




លឹម សីហា

# វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡង
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨

## [វិញ្ញាសាទី២]

I. (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to-3}\dfrac{x^2+6x+9}{x^2+4x+3}$

គ. $\lim\limits_{x\to0}\dfrac{\sqrt{2+x}-\sqrt{2-x}}{x}$

ខ. $\lim\limits_{x\to0}\dfrac{\sin^2 x}{-3x}$

ឃ. $\lim\limits_{x\to+\infty}(2e^x+2x-2)$

II. (១៥ពិន្ទុ) ក្រូចត្លុង 20 ផ្លែដែលដាក់លក់មាន 16 ផ្លែមានរសជាតិផ្អែម និង 4 ផ្លែទៀតមានរសជាតិជូរ។ អ្នកទិញម្នាក់ជ្រើសរើសយកក្រូច 3 ផ្លែដោយចៃដន្យ។ រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

១. A : ក្រូចទាំង 3 ផ្លែសុទ្ធតែជូរ។

២. B : ក្រូចទាំង 3 ផ្លែសុទ្ធតែផ្អែម។

៣. C : យ៉ាងតិចមានក្រូច 1 ផ្លែមានរសជាតិផ្អែម។

លឹម សីហា

III. (២០ពិន្ទុ) គេឲ្យសមីការ $y''-4y'+5y=0$ (E) ។

១. រកចម្លើយទូទៅ $y_c$ នៃសមីការ (E) ។

២. គេដឹងថា $y_p=a\cos x+b\sin x$ ជាចម្លើយពិសេសនៃសមីការ
$y''-4y'+5y=4\cos x-12\sin x$ (F) ចំពោះគ្រប់ចំនួនពិត $x$ ។
រកចំនួនពិត $a$ និង $b$ ហើយទាញរកចម្លើយទូទៅនៃសមីការ (F) ។

IV. (១០ពិន្ទុ) គេមានសមីការ $18x^2+10y^2=90$

ក. បង្ហាញថាសមីការនេះជាសមីការអេលីប។
រកប្រវែងអ័ក្សធំ, ប្រវែងអ័ក្សតូច និងកូអរដោនេនៃកំពូលទាំងពីរ។

ខ. សង់អេលីបនេះ។

V. (៣០ពិន្ទុ) នៅក្នុងតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ គេឲ្យចំណុច $A(1,0,1)$ និងវ៉ិចទ័រ $\overrightarrow{AB}=(-1,2,1)$ ។

១. រកកូអរដោនេចំណុច B។ រកសមីការប្លង់ P ដែលកាត់តាមចំណុច A និងមានវ៉ិចទ័រប្រាប់ទិស $\overrightarrow{AB}$ ។

២. គេឲ្យចំណុច $C(2,1,0)$ និង $D(1,3,1)$ ។
រកកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AC}$ និង $\overrightarrow{CD}$ ។ គណនា $\overrightarrow{AB}\cdot\overrightarrow{AC}$ រួចបង្ហាញថា ABDC ជាចតុកោណកែង។

៣. គណនា $\overrightarrow{AB}\times\overrightarrow{AC}$ ទាញរកផ្ទៃក្រឡានៃចតុកោណ ABDC ។

៤. រកមាឌចតុមុខ OABC ។ ទាញរកចម្ងាយពីគល់ O ទៅប្លង់ ABC ។

VI. (៣៥ពិន្ទុ) f ជាអនុគមន៍កំណត់ចំពោះគ្រប់ចំនួនពិត x ដោយ $y=f(x)=-x-2+\dfrac{4e^x}{e^x+1}$ ហើយមានខ្សែកោង C នៅក្នុងតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j}\right)$ មួយដែលមានឯកតា 1cm ។

១. គណនា $\lim\limits_{x\to-\infty}f(x)$ និង $\lim\limits_{x\to+\infty}f(x)$ ។
រកសមីការអាស៊ីមតូតទ្រេតនៃខ្សែកោង C កាលណា $x\to-\infty$ ។

២. គណនា $f'(x)$ ហើយបង្ហាញថា $f'(x)\leq 0,\ x\in\mathbb{R}$ ។
គណនា $f'(0)$ , $f(0)$ រួចសង់តារាងអថេរភាពនៃ f ។

៣. បង្ហាញថាគល់កូអរដោនេ O ជាចំណុចរបត់ និងជាផ្ចិតឆ្លុះរបស់ខ្សែកោង C ។

៤. រក $f(3)$ រួចសង់ខ្សែកោង C (គេយក $e^3=20$) ។ ដោះស្រាយវិសមីការ $\dfrac{4e^x}{e^x+1}\geq x+2$ ដោយប្រើខ្សែកោង C ។

លីម សីហា

## [ដំណោះស្រាយ]

**I. គណនាលីមីត៖**

ក. $\lim\limits_{x\to -3}\dfrac{x^2+6x+9}{x^2+4x+3}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to -3}\frac{(x+3)(x+3)}{(x+1)(x+3)}=\lim_{x\to -3}\frac{x+3}{x+1}=\frac{-3+3}{-3+1}=\frac{0}{-2}=0$$

ដូចនេះ $\boxed{\lim\limits_{x\to -3}\dfrac{x^2+6x+9}{x^2+4x+3}=0}$

ខ. $\lim\limits_{x\to 0}\dfrac{\sin^2 x}{-3x}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to 0}\frac{1}{-3}\cdot\frac{\sin x}{x}\cdot\sin x=\frac{1}{-3}(1)(0)=0$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{\sin^2 x}{-3x}=0}$

គ. $\lim\limits_{x\to 0}\dfrac{\sqrt{2+x}-\sqrt{2-x}}{x}$ (មានរាងមិនកំណត់$\frac{0}{0}$)

$$=\lim_{x\to 0}\frac{\left(\sqrt{2+x}-\sqrt{2-x}\right)}{x}\times\frac{\left(\sqrt{2+x}+\sqrt{2-x}\right)}{\left(\sqrt{2+x}+\sqrt{2-x}\right)}=\lim_{x\to 0}\frac{2+x-(2-x)}{x\left(\sqrt{2+x}+\sqrt{2-x}\right)}$$

$$=\lim_{x\to 0}\frac{2x}{x\left(\sqrt{2+x}+\sqrt{2-x}\right)}=\frac{2}{\sqrt{2+0}+\sqrt{2-0}}=\frac{2}{2\sqrt{2}}=\frac{1}{\sqrt{2}}\times\frac{\sqrt{2}}{\sqrt{2}}=\frac{\sqrt{2}}{2}$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{\left(\sqrt{2+x}-\sqrt{2-x}\right)}{x}=\dfrac{\sqrt{2}}{2}}$

ឃ. $\lim\limits_{x\to +\infty}(2e^x+2x-2)=2(+\infty)+2(+\infty)-2=+\infty$

ដូចនេះ $\boxed{\lim\limits_{x\to +\infty}(2e^x+2x-2)=+\infty}$

**II. រកប្រូបាបនៃព្រឹត្តិការណ៍៖**

១. A : ក្រូចទាំង 3 ផ្លែសុទ្ធតែជូរ

តាមរូបមន្ត $P(A)=\dfrac{n(A)}{n(S)}$ ដោយ $n(A)=C(4,3)=\dfrac{4!}{1!3!}=4$

$$n(S)=C(20,3)=\frac{20!}{17!3!}=\frac{20\times 19\times 18}{3\times 2\times 1}$$

$$=20\times 19\times 3=1140$$

យើងបាន $P(A)=\dfrac{4}{1140}=\dfrac{1}{285}$ ដូចនេះ $\boxed{P(A)=\dfrac{1}{285}}$

២. B : ក្រូចទាំង 3 ផ្លែសុទ្ធតែផ្អែម

តាមរូបមន្ត $P(B)=\dfrac{n(B)}{n(S)}$ ដោយ $n(B)=C(16,3)=\dfrac{16!}{13!3!}=\dfrac{16\times15\times14}{3\times2\times1}$

$$=8\times5\times14=560$$

$$n(S)=1140$$

យើងបាន $P(B)=\dfrac{560}{1140}=\dfrac{8\times5\times14}{20\times19\times3}=\dfrac{28}{57}$ ដូចនេះ $\boxed{P(B)=\dfrac{28}{57}}$

៣. C : យ៉ាងតិចមានក្រូច 1 ផ្លែមានរសជាតិផ្អែម

តាមរូបមន្ត $P(C)=1-P(A)=1-\dfrac{1}{285}=\dfrac{284}{285}$

ដូចនេះ $\boxed{P(C)=\dfrac{284}{285}}$

III. ១. រកចម្លើយទូទៅ $y_c$ នៃសមីការ (E) : $y''-4y'+5y=0$

(E) មានសមីការសម្គាល់ $r^2-4r+5=0$

$\Delta=b^2-4ac=16-4(1)(5)=-4 \Rightarrow \sqrt{\Delta}=2i$

$\Rightarrow r_1=\dfrac{4-2i}{2}=2-i \quad ; \quad r_2=\dfrac{4+2i}{2}=2+i$

ដូចនេះ $\boxed{y_c=e^{2x}(A\cos x+B\sin x) \quad ; \quad A,B\in\mathbb{R}}$

២. រកចំនួនពិត a និង b

យើងមាន $y_p=a\cos x+b\sin x \quad ; \quad y''-4y'+5y=4\cos x-12\sin x \ \ (F)$

$y_p$ ជាចម្លើយនៃ (F) លុះត្រាតែ $y_p''-4y_p'+5y_p=4\cos x-12\sin x$

ដោយ $y_p'=(a\cos x+b\sin x)'=-a\sin x+b\cos x$

$y_p''=(-a\sin x+b\cos x)'=-a\cos x-b\sin x$

គេបាន

$$-a\cos x-b\sin x-4(-a\sin x+b\cos x)+5(a\cos x+b\sin x)=4\cos x-12\sin x$$

$$(-4b+4a)\cos x+(4a+4b)\sin x=4\cos x-12\sin x$$

$$\Rightarrow \quad \begin{cases} -4b + 4a = 4 \\ \underline{4a + 4b = -12} \end{cases} \; +$$

$$8a = -8 \quad \Rightarrow \quad a = -1 \; ; \quad \Rightarrow \; b = -2$$

ដូចនេះ $\boxed{y_p = -\cos x - 2\sin x}$

ទាញរកចម្លើយទូទៅនៃសមីការ (F)

$\boxed{\text{ចម្លើយទូទៅនៃ(F)គឺ } y = y_c + y_p = e^{2x}(A\cos x + B\sin x) - \cos x - 2\sin x \; ; \quad A, B \in \mathbb{R}}$

IV. ក. បង្ហាញថាសមីការ $18x^2 + 10y^2 = 90$ ជាសមីការអេលីប

$$18x^2 + 10y^2 = 90 \quad \Leftrightarrow \quad \frac{18x^2}{90} + \frac{10y^2}{90} = \frac{90}{90}$$

$$\Leftrightarrow \quad \frac{x^2}{5} + \frac{y^2}{9} = 1$$

$$\Leftrightarrow \quad \frac{(x-0)^2}{\left(\sqrt{5}\right)^2} + \frac{(y-0)^2}{3^2} = 1$$ ជាសមីការអេលីប

លីម សីហា

គេបាន

- អ័ក្សធំជាអ័ក្សឈរ
- $h = 0, \; k = 0; \quad a = 3; \; b = \sqrt{5}$
- រកប្រវែងអ័ក្សធំគឺ $2a = 2(3) = 6$ ឯកតាប្រវែង
- ប្រវែងអ័ក្សតូចគឺ $2b = 2(\sqrt{5}) = 2\sqrt{5}$ ឯកតាប្រវែង
- កំពូលគឺ $V_1(h, k-a); \; V_2(h, k+a)$ **ដូចនេះ** $\boxed{V_1(0,-3); \; V_2(0,3)}$

ខ. សង់អេលីបនេះ



V. ១. គណនាកូអរដោនេនៃចំណុច B

យើងមាន $A(1,0,1)$ ; $\overrightarrow{AB}=(-1,2,1)$

ដោយ $\overrightarrow{AB}(x_B-x_A,y_B-y_A,z_B-z_A)\Rightarrow\overrightarrow{AB}(x_B-1,y_B-0,z_B-1)$

តែ $\overrightarrow{AB}(-1,2,1)$

$$\Longrightarrow\begin{cases}x_B-1=-1\\ y_B=2\\ z_B-1=1\end{cases}\Rightarrow\begin{cases}x_B=0\\ y_B=2\\ z_B=2\end{cases}$$

ដូចនេះ **កូអរដោនេះចំណុចB គឺ $B(0,2,2)$**

រកសមីការប្លង់ P ដែលកាត់តាមចំណុច A និងមានវ៉ិចទ័រប្រាប់ទិស $\overrightarrow{AB}$

សមីការប្លង់ P : $a(x-x_o)+b(y-y_o)+c(z-z_o)=0$

- P ដែលកាត់តាមចំណុច $A(1,0,1)$
- P មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{AB}(-1,2,1)$

នាំឲ្យ $(P):-1(x-1)+2(y-0)+1(z-1)=0$

$-x+2y+z=0$

លឹម សីហា

ដូចនេះ **សមីការប្លង់$(P):\ -x+2y+z=0$**

២. រកកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AC}$ និង $\overrightarrow{CD}$

យើងមាន $A(1,0,1)$; $C(2,1,0)$ និង $D(1,3,1)$

យើងបាន $\overrightarrow{AC}(2-1,1-0,0-1)\Rightarrow$ **$\overrightarrow{AC}(1,1,-1)$**

$\overrightarrow{CD}(1-2,3-1,1-0)\Rightarrow$ **$\overrightarrow{CD}(-1,2,1)$**

គណនា $\overrightarrow{AB}\cdot\overrightarrow{AC}$

យើងមាន $\overrightarrow{AB}(-1,2,1)$ ; $\overrightarrow{AC}(1,1,-1)$

យើងបាន $\overrightarrow{AB}\cdot\overrightarrow{AC}=(-1)(1)+(2)(1)+1(-1)=0$ ដូចនេះ **$\overrightarrow{AB}\cdot\overrightarrow{AC}=0$**

បង្ហាញថា ABDC ជាចតុកោណកែង

ដោយ

- $\overrightarrow{AB}\cdot\overrightarrow{AC}=0 \Rightarrow \overrightarrow{AB}\perp\overrightarrow{AC} \quad (1)$
- $\overrightarrow{AB}(-1,2,1)=\overrightarrow{CD}(-1,2,1) \Rightarrow \left|\overrightarrow{AB}\right|=\left|\overrightarrow{CD}\right| \quad (2)$

តាម (1) និង (2) ដូចនេះ $\boxed{\text{ABDC ជាចតុកោណកែង}}$

៣. គណនា $\overrightarrow{AB}\times\overrightarrow{AC}$

យើងមាន $\overrightarrow{AB}(-1,2,1)\ ;\ \overrightarrow{AC}(1,1,-1)$

យើងបាន
$$\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -1 & 2 & 1\\ 1 & 1 & -1\end{vmatrix}=(-2-1)\vec{i}-(1-1)\vec{j}+(-1-2)\vec{k}$$
$$=-3\vec{i}+0\vec{j}-3\vec{k}$$

ដូចនេះ $\boxed{\overrightarrow{AB}\times\overrightarrow{AC}=-3\vec{i}+0\vec{j}-3\vec{k}}$

លឹម សីហា

ទាញរកផ្ទៃក្រឡានៃចតុកោណ ABDC

$$S_{ABCD}=\left|\overrightarrow{AB}\times\overrightarrow{AC}\right|=\sqrt{(-3)^2+0^2+(-3)^2}=3\sqrt{2}$$

ដូចនេះ $\boxed{S_{ABCD}=3\sqrt{2}\ \text{ឯកតាផ្ទៃ}}$

៤. រកមាឌចតុមុខ OABC

$$V_{\text{ចតុមុខ}OABC}=\frac{1}{6}\left|\overrightarrow{AB}\times\overrightarrow{AC}\right|\cdot AO \qquad ;\ AO=\sqrt{1^2+0^2+1^2}=\sqrt{2}$$
$$=\frac{1}{6}\cdot 3\sqrt{2}\cdot\sqrt{2}=1$$

ដូចនេះ $\boxed{V=1\ \text{ឯកតាមាឌ}}$

ទាញរកចម្ងាយពីគល់ O ទៅប្លង់ ABC

តាមរូបមន្ត $V_{\text{តេត្រាអ៊ែត}OABC} = \frac{1}{3} S_{\Delta ABC} \cdot h$

$$\Rightarrow \quad h = \frac{3V}{S}$$

$$h = \frac{3V}{\frac{1}{2}\left|\overrightarrow{AB} \times \overrightarrow{AC}\right|} \quad ; \ h = d\,(O, (ABC))$$

$$\Rightarrow \quad d(o, (ABC)) = \frac{6V}{3\sqrt{2}} = 2 \cdot \frac{1}{\sqrt{2}} \times \frac{\sqrt{2}}{\sqrt{2}} = \sqrt{2}$$

ដូចនេះ $\boxed{d\,(O, (ABC)) = \sqrt{2} \text{ ឯកតាប្រវែង}}$

VI. ១. គណនា $\lim\limits_{x \to -\infty} f(x)$ និង $\lim\limits_{x \to +\infty} f(x)$

$$y = f(x) = -x - 2 + \frac{4e^x}{e^x + 1}$$

$$\lim_{x \to -\infty} f(x) = \lim_{x \to -\infty} \left(-x - 2 + \frac{4e^x}{e^x + 1}\right) = -(-\infty) - 2 + \frac{0}{0 + 1} = +\infty$$

$$\boxed{\lim_{x \to -\infty} f(x) = +\infty}$$

$$\lim_{x \to +\infty} f(x) = \lim_{x \to +\infty} \left(-x - 2 + \frac{4e^x}{e^x + 1}\right) = -(+\infty) - 2 + \frac{4}{1 + 0} = -\infty$$

$$\boxed{\lim_{x \to +\infty} f(x) = -\infty}$$

លឹម សីហា

រកសមីការអាស៊ីមតូតទ្រេតនៃខ្សែកោង C កាលណា $x \to -\infty$

$$y = f(x) = -x - 2 + \frac{4e^x}{e^x + 1} \text{ ដោយ } \lim_{x \to -\infty} \frac{e^x}{e^x + 1} = \frac{4(0)}{0 + 1} = 0$$

ដូចនេះ $\boxed{\text{បន្ទាត់} y = -x - 2 \text{ ជាអាស៊ីមតូតទ្រេត}}$

២. គណនា $f'(x)$

$$f'(x) = \left(-x - 2 + \frac{4e^x}{e^x + 1}\right)' = -1 + \frac{(4e^x)'(e^x + 1) - (4e^x)(e^x + 1)'}{(e^x + 1)^2}$$

$$= -1 + \frac{4e^{2x} + 4e^x - 4e^{2x}}{(e^x + 1)^2} = \frac{-e^{2x} - 2e^x - 1}{(e^x + 1)^2} + \frac{4e^x}{(e^x + 1)^2}$$

$$= \frac{-\left(e^{2x} - 2e^{x} + 1\right)}{(e^{x}+1)^2} = -\frac{(e^{x}-1)^2}{(e^{x}+1)^2}$$

ដូចនេះ $\boxed{f'(x) = -\dfrac{(e^{x}-1)^2}{(e^{x}+1)^2}}$

បង្ហាញថា $f'(x) \leq 0,\ x \in \mathbb{R}$

$f'(x) = -\dfrac{(e^{x}-1)^2}{(e^{x}+1)^2} < 0 \quad \forall x \in \mathbb{R}$ ព្រោះ $\dfrac{(e^{x}-1)^2}{(e^{x}+1)^2} > 0$

ដូចនេះ $\boxed{f'(x) < 0 \quad \forall x \in \mathbb{R}}$

គណនា $f'(0)$ , $f(0)$

- $f'(0) = -\dfrac{\left(e^{0}-1\right)^2}{\left(e^{0}+1\right)^2} = -\dfrac{0}{4} = 0 \quad \boxed{f'(0) = 0}$
- $f(0) = -0 - 2 + \dfrac{4e^{0}}{e^{0}+1} = -2 + 2 = 0 \quad \boxed{f(0) = 0}$

លីម សីហា

តារាងអថេរភាពនៃf

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $-$ | |
| $f(x)$ | $+\infty$ | ↘ | $0$ | ↘ | $-\infty$ |

៣. បង្ហាញថាគល់កូអរដោនេ O ជាចំណុចរបត់ និងជាផ្ចិតឆ្លុះរបស់ខ្សែកោង C

$$f''(x) = \left(-\frac{(e^{x}-1)^2}{(e^{x}+1)^2}\right)' = \frac{-2e^{x}(e^{x}-1)(e^{x}+1)^2 + 2e^{x}(e^{x}+1)(e^{x}-1)^2}{(e^{x}+1)^4}$$

$$= \frac{-2e^{x}(e^{x}-1)(e^{x}+1) + 2e^{x}(e^{x}-1)^2}{(e^{x}+1)^2}$$

$$= \frac{-2e^{3x} - 2e^{2x} + 2e^{2x} + 2e^{x} + 2e^{3x} - 4e^{2x} + 2e^{x}}{(e^{x}+1)^3} = \frac{4e^{x} - 4e^{2x}}{(e^{x}+1)^3}$$

$$= \frac{4e^{x}(1-e^{x})}{(e^{x}+1)^3}$$

$f''(x)$ មានសញ្ញាតាម $1-e^x$

- $f''(x)=0 \quad \Leftrightarrow \quad 1-e^x=0 \Rightarrow 1=e^x \Rightarrow x=0$
- $f''(x)<0 \quad \Leftrightarrow \quad 1-e^x<0 \Rightarrow 1<e^x \Rightarrow x>0$
- $f''(x)>0 \quad \Leftrightarrow \quad 1-e^x>0 \Rightarrow 1>e^x \Rightarrow x<0$

តារាងសញ្ញា$f''(x)$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f''(x)$ | | $+$ | $0$ | $-$ | |

- ត្រង់$x=0,\ f''(0)=0$ ហើយវាប្តូរសញ្ញាពីរ $+$ ទៅ $-$ ដូចនេះ យើងបាន $f$ មានចំនុចរបត់មួយ ត្រង់ $x=0, f(0)=0$

ដូចនេះ **គល់ $O(0,0)$ ជាចំណុចរបត់នៃខ្សែកោង**

លឹម សីហា

បង្ហាញថាគល់$O(0,0)$ ជាផ្ចិតឆ្លុះ

$O(0,0)$ ជាផ្ចិតឆ្លុះ លុះត្រាតែ $f(2\times 0-x)+f(x)=2\times 0 \quad \Leftrightarrow \quad f(-x)+f(x)=0$

- $f(x)=-x-2+\dfrac{4e^x}{e^x+1}$
- $f(-x)=x-2+\dfrac{4e^{-x}}{e^{-x}+1}=x-2+\dfrac{4}{1+e^x}$

$\Rightarrow f(-x)+f(x)=-4+\dfrac{4e^x}{e^x+1}+\dfrac{4}{e^x+1}=-4+4\left(\dfrac{e^x+1}{e^x+1}\right)=0$ ពិត

ដូចនេះ **គល់$O(0,0)$ ជាផ្ចិតឆ្លុះ**

៤. រក $f(3)$

$f(3)=-3-2+\dfrac{4e^3}{e^3+1}=-5+\dfrac{4e^3}{e^3+1}=-1.19$ **$f(3)=-1.19$**

សង់ខ្សែកោង $C$

- $y=-x-2$

| $x$ | $0$ | $-2$ |
|---|---|---|
| $y$ | $-2$ | $0$ |




ដោះស្រាយវិសមីការ $\frac{4e^x}{e^x+1} \geq x+2$ ដោយប្រើខ្សែកោង C

$$\frac{4e^x}{e^x+1} \geq x+2 \quad \Leftrightarrow \quad -x-2+\frac{4e^x}{e^x+1} \geq 0 \quad \Leftrightarrow \quad f(x) \geq 0$$

តាមក្រាប $f(x) \geq 0$ លុះត្រាតែ $x \in (-\infty, 0]$

លីម សីហា

# វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡង
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨

## [វិញ្ញាសាទី៣]

I. (១០ពិន្ទុ) គេមានចំនួនកុំផ្លិចពីរ $Z_1=\dfrac{2\left(\cos\frac{\pi}{12}+i\sin\frac{\pi}{12}\right)^2}{1+i\sqrt{3}}$ និង $Z_2=(1-i)x+(1-y)(1+i)$។

១. សរសេរ $Z_1$ ជាទម្រង់ត្រីកោណមាត្រ ហើយសរសេរជាទម្រង់ពីជគណិត។

២. កំណត់ចំនួនពិត $x$ និង $y$ ដើម្បីឲ្យបាន $2\overline{Z}_1-(Z_2+y-1)=0$ ($\overline{Z}_1$ ជាចំនួនកុំផ្លិចឆ្លាស់នៃ $Z_1$) ។

II. (១៥ពិន្ទុ) គណនាលីមីតខាងក្រោម៖

ក. $\displaystyle\lim_{x\to\frac{\pi}{4}}\frac{2\sin\left(x-\frac{\pi}{4}\right)}{\frac{\pi}{4}-x}$

ខ. $\displaystyle\lim_{x\to 0}\frac{-2\sin 5x}{\sqrt{5}-\sqrt{x+5}}$

គ. $\displaystyle\lim_{x\to 0}\frac{1-\cos^2 3x}{-2x^2}$

ឃ. $\displaystyle\lim_{x\to 0}\frac{x^2-x}{|x|}$

III. (១៥ពិន្ទុ) ក្នុងធុងមួយគេមានប៊ូលក្រហម៤ ប៊ូលស៣ និងប៊ូលខៀវ១។ គេចាប់យកប៊ូល៣ក្នុងពេលតែមួយចេញពីធុងដោយចៃដន្យ។

ក. រកប្រូបាបដែល «គេចាប់បានប៊ូលក្រហមពីរ និងមួយទៀតមិនក្រហម»

ខ. រកប្រូបាបដែល «គេចាប់បានប៊ូលក្រហមទាំងបី»

គ. រកប្រូបាបដែល «គេចាប់បានយ៉ាងតិចប៊ូលក្រហមពីរ»

IV. (១៥ពិន្ទុ) គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{5x^2+20x+6}{x^3+2x^2+x}$។

១. សរសេរ $f(x)$ ជារាង $\dfrac{A}{x}+\dfrac{B}{x+1}+\dfrac{C}{(x+1)^2}$ ដែល $A$ ,$B$ និង $C$ ជាចំនួនថេរដែលត្រូវកំណត់។

២. គណនា $\displaystyle\int\frac{5x^2+20x+6}{x^3+2x^2+x}dx$ ។

V. (១០ពិន្ទុ) គេមានប៉ារ៉ាបូលមួយមានកំពូលនៅត្រង់ចំណុច $o(0,0)$ និង កំណុំ $F$ ស្ថិតនៅលើអ័ក្សអរដោនេ។

ក. រកសមីការស្តង់ដានៃប៉ារ៉ាបូលនេះ បើគេដឹងថាវាកាត់តាមចំណុច $A(2,6)$។

ខ. រកតម្លៃនៃ $x$ បើ $B\left(x_1,\dfrac{3}{2}\right)$ ស្ថិតនៅលើប៉ារ៉ាបូលនេះ។ ចូរសង់ប៉ារ៉ាបូលនេះ។

VI. (២៥ពិន្ទុ) ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់វិជ្ជមាន $\left(O, \vec{i}, \vec{j}, \vec{k}\right)$ គេឲ្យចំណុច $A(3,2,0)$ និង $K(0,-1,3)$ ។

១. រកសមីការប្លង់ $P$ ដែលកាត់តាម $A$ ហើយកែងនឹងបន្ទាត់ $AK$ ។

២. គេឲ្យចំណុច $B(5,0,0)$; $C(0,5,0)$ និង $D(0,0,-5)$ ។ផ្ទៀងផ្ទាត់ថាចំណុច $B, C$ និង $D$ ជាចំណុចរបស់ប្លង់ $P$ ។

៣. គណនាផ្ទៃក្រឡានៃត្រីកោណ $BCD$ ។

៤. គណនាប្រវែង $AK$ រួចទាញរកមាឌនៃតេត្រាអ៊ែត $KBCD$ ។

VII. (៣៥ពិន្ទុ) $f$ ជាអនុគមន៍កំណត់ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $x$ ដោយ $y = f(x) = -x - \dfrac{4\ln x}{x}$ ហើយមានខ្សែកោង $C$ នៅក្នុងតម្រុយអរតូណរម៉ាល់ $\left(O, \vec{i}, \vec{j}, \vec{k}\right)$ មួយ។

១. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ ។ ទាញរកសមីការអាស៊ីមតូតឈរនៃក្រាប $C$ ។

២. បង្ហាញថាបន្ទាត់$L : y = -x$ ជាអាស៊ីមតូតទ្រេតនៃក្រាប$C$។ សិក្សាទីតាំងរវាងក្រាប$C$ និងបន្ទាត់$L$។

៣. បង្ហាញថាដេរីវេ $f'(x) < 0$ បើគេដឹងថា $x^2 + 4 - 4\ln x > 0$ ចំពោះ $x > 0$ ។
សង់តារាងអថេរភាពនៃ $f$ ។ បន្ទាត់ $D$ ប៉ះនឹងក្រាប $C$ ត្រង់ចំណុច $A$ ហើយស្របនឹងបន្ទាត់ $L$ ។
រកកូអរដោនេនៃចំណុច $A$ និងសមីការនៃបន្ទាត់ $D$ ។

៤. សង់ $L, D$ និងក្រាប $C$ នៅក្នុងតម្រុយ $\left(O, \vec{i}, \vec{j}\right)$ ដោយយក $e = 2.7$, $\dfrac{4}{e} = 1.5$ ។
គេយក $S(a)$ ជាផ្ទៃក្រឡាផ្នែកប្លង់កំណត់ដោយក្រាប$C$ និងអាស៊ីមតូតទ្រេត$L$ ដែលត្រូវនឹង $1 \le x \le a$។
រកតម្លៃ $a$ ដើម្បីឲ្យ $S(a) = 2$ ឯកតាផ្ទៃ។

ខេមរៈ

## [ដំណោះស្រាយ]

I. ១. សរសេរ $Z_1$ ជាទម្រង់ត្រីកោណមាត្រ ហើយសរសេរជាទម្រង់ពីជគណិត

$$Z_1=\frac{2\left(\cos\frac{\pi}{12}+i\sin\frac{\pi}{12}\right)^2}{1+i\sqrt{3}}=\frac{2\left(\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right)}{2\left(\frac{1}{2}+i\frac{\sqrt{3}}{2}\right)}=\frac{\cos\frac{\pi}{6}+i\sin\frac{\pi}{6}}{\cos\frac{\pi}{3}+i\sin\frac{\pi}{3}}$$

$$=\cos\left(\frac{\pi}{6}-\frac{\pi}{3}\right)+i\sin\left(\frac{\pi}{6}-\frac{\pi}{3}\right)=\cos\left(-\frac{\pi}{6}\right)+i\sin\left(-\frac{\pi}{6}\right)$$

ដូចនេះ $\boxed{\text{ទម្រង់ត្រីកោណមាត្រគឺ } Z_1=\cos\left(-\frac{\pi}{6}\right)+i\sin\left(-\frac{\pi}{6}\right)}$

$$Z_1=\cos\left(-\frac{\pi}{6}\right)+i\sin\left(-\frac{\pi}{6}\right)=\frac{\sqrt{3}}{2}-\frac{1}{2}i$$

ដូចនេះ $\boxed{\text{ទម្រង់ពិជគណិត គឺ } Z_1=\frac{\sqrt{3}}{2}-\frac{1}{2}i}$

២. កំណត់ចំនួនពិត $x$ និង $y$ ដើម្បីឲ្យបាន $2\overline{Z}_1-(Z_2+y-1)=0$

- $Z_1=\frac{\sqrt{3}}{2}-\frac{1}{2}i \quad\Rightarrow \overline{Z_1}=\frac{\sqrt{3}}{2}+\frac{1}{2}i$
- $Z_2=(1-i)x+(1-y)(1+i)=x-xi+1+i-y-yi$

$$2\overline{Z}_1-(Z_2+y-1)=0 \quad\Leftrightarrow 2\left(\frac{\sqrt{3}}{2}+\frac{1}{2}i\right)-(x-xi+1+i-y-yi+y-1)=0$$

$$\sqrt{3}+i-x+xi-i+yi=0$$

$$\left(\sqrt{3}-x\right)+(x+y)i=0+0i$$

$$\Longrightarrow\begin{cases}\sqrt{3}-x=0 & \Rightarrow x=\sqrt{3}\\ x+y=0 & \Rightarrow y=-x=-\sqrt{3}\end{cases}$$

ដូចនេះ $\boxed{x=\sqrt{3}\ ;\ y=-\sqrt{3}}$

II. គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to\frac{\pi}{4}}\frac{2\sin\left(x-\frac{\pi}{4}\right)}{\frac{\pi}{4}-x}$ (មានរាងមិនកំណត់$\frac{0}{0}$)

$$=\lim_{x\to\frac{\pi}{4}}2\frac{\sin\left(x-\frac{\pi}{4}\right)}{-\left(x-\frac{\pi}{4}\right)}=\frac{2}{-1}\times 1=-2 \qquad \boxed{\lim_{x\to\frac{\pi}{4}}\frac{2\sin\left(x-\frac{\pi}{4}\right)}{\frac{\pi}{4}-x}=-2}$$

ខ. $\lim\limits_{x\to 0}\dfrac{-2\sin 5x}{\sqrt{5}-\sqrt{x+5}}$ (មានរាងមិនកំណត់$\frac{0}{0}$)

$$=\lim_{x\to 0}\frac{-2\sin 5x\left(\sqrt{5}+\sqrt{x+5}\right)}{\left(\sqrt{5}-\sqrt{x+5}\right)\left(\sqrt{5}+\sqrt{x+5}\right)}=\lim_{x\to 0}\frac{-2\sin 5x\left(\sqrt{5}+\sqrt{x+5}\right)}{5-(x+5)}$$

$$=\lim_{x\to 0}2\times 5\frac{\sin 5x}{5x}\left(\sqrt{5}+\sqrt{x+5}\right)=10\times 1\times 2\sqrt{5}=20\sqrt{5}$$

$$\boxed{\lim_{x\to 0}\frac{-2\sin 5x}{\sqrt{5}-\sqrt{x+5}}=20\sqrt{5}}$$

គ. $\lim\limits_{x\to 0}\dfrac{1-\cos^2 3x}{-2x^2}$ (មានរាងមិនកំណត់$\frac{0}{0}$)

$$=\lim_{x\to 0}\frac{\sin^2 3x}{(3x)^2}\left(\frac{3^2}{-2}\right)=1\times\left(-\frac{9}{2}\right)=-\frac{9}{2}\qquad\boxed{\lim_{x\to 0}\frac{1-\cos^2 3x}{-2x^2}=-\frac{9}{2}}$$

ឃ. $\lim\limits_{x\to 0}\dfrac{x^2-x}{|x|}$ (មានរាងមិនកំណត់$\frac{0}{0}$)

$$=\lim_{x\to 0}\frac{x(x-1)}{|x|}=\left[\begin{array}{l}\lim\limits_{x\to 0^-}\dfrac{x(x-1)}{-x}=\dfrac{0-1}{-1}=1\\ \lim\limits_{x\to 0^+}\dfrac{x(x-1)}{x}=\dfrac{0-1}{1}=-1\end{array}\right.\qquad\boxed{\lim_{x\to 0}\frac{x^2-x}{|x|}=\pm 1}$$

III. ក. រកប្រូបាបដែល «គេចាប់បានប៊ូលក្រហមពីរ និងមួយទៀតមិនក្រហម»

តាង A : «គេចាប់បានប៊ូលក្រហមពីរ និងមួយទៀតមិនក្រហម»

**តាមរូបមន្ត** $P(A)=\dfrac{n(A)}{n(S)}$ ដោយ $n(A)=C(4,2)\times C(3,1)+C(4,2)\times C(1,1)$

$$=\frac{4!}{2!2!}\times\frac{3!}{2!1!}+\frac{4!}{2!2!}\times\frac{1!}{0!1!}$$

$$=6\times 3+6=24$$

$$n(S)=C(8,3)=\frac{8!}{5!3!}=\frac{8\times 7\times 6\times 5!}{5!3\times 2\times 1}=56$$

គេបាន $P(A)=\dfrac{n(A)}{n(S)}=\dfrac{24}{56}=\dfrac{3}{7}$ ដូចនេះ $\boxed{P(A)=\dfrac{3}{7}}$

ខ. រកប្រូបាបដែល «គេចាប់បានប៊ូលក្រហមទាំងបី»   តាង B : «គេចាប់បានប៊ូលក្រហមទាំងបី»

**តាមរូបមន្ត** $P(B) = \dfrac{n(B)}{n(S)}$   ដោយ $n(B) = C(4,3) = \dfrac{4!}{1!3!} = \dfrac{4\times 3!}{3!} = 4$

$$n(S) = 56$$

គេបាន $P(B) = \dfrac{4}{56} = \dfrac{1}{14}$   ដូចនេះ $\boxed{P(B) = \dfrac{1}{14}}$

គ. រកប្រូបាបដែល «គេចាប់បានយ៉ាងតិចប៊ូលក្រហមពីរ»

តាង C : «គេចាប់បានយ៉ាងតិចប៊ូលក្រហមពីរ»

**តាមរូបមន្ត** $P(C) = \dfrac{n(C)}{n(S)}$

ដោយ $n(C) = C(4,2)\times C(3,1) + C(4,2)\times C(1,1) + C(4,3) = 24 + 4 = 28$

$n(S) = 56$

គេបាន $P(C) = \dfrac{n(C)}{n(S)} = \dfrac{28}{56} = \dfrac{1}{2}$   ដូចនេះ $\boxed{P(C) = \dfrac{1}{2}}$

លឹម សីហា

IV. ១. សរសេរ f(x) ជារាង $\dfrac{A}{x} + \dfrac{B}{x+1} + \dfrac{C}{(x+1)^2}$

$$f(x) = \frac{5x^2 + 20x + 6}{x^3 + 2x^2 + x}$$

$$f(x) = \frac{A}{x} + \frac{B}{x+1} + \frac{C}{(x+1)^2} \Leftrightarrow \frac{5x^2+20x+6}{x^3+2x^2+x} = \frac{A}{x} + \frac{B}{x+1} + \frac{C}{(x+1)^2}$$

$$= \frac{A(x+1)^2 + Bx(x+1) + Cx}{x\left(x^2+2x+1\right)}$$

$$= \frac{(A+B)x^2 + (2A+B+C)x + A}{x^3+2x^2+x}$$

$$\Rightarrow \begin{cases} A + B = 5 & (1) \\ 2A + B + C = 20 & (2) \\ A = 6 & (3) \end{cases}$$

$(3):\ A = 6 \quad \Rightarrow (1):\ 6 + B = 5 \quad \Rightarrow B = -1$

$(2):\ 2A + B + C = 20 \quad \Rightarrow 2(6) - 1 + C = 20 \quad \Rightarrow C = 9$

ដូចនេះ $\boxed{f(x)=\frac{6}{x}-\frac{1}{x+1}+\frac{9}{(x+1)^2}}$

២. គណនា $\int\frac{5x^2+20x+6}{x^3+2x^2+x}dx=\int\left(\frac{6}{x}-\frac{1}{x+1}+\frac{9}{(x+1)^2}\right)dx$

$$=6\ln|x|-\ln|x+1|+\frac{-9}{x+1}+C \quad ;\ C\in\mathbb{R}$$

$$=\ln\left|\frac{x^6}{x+1}\right|-\frac{9}{x+1}+C \quad ;\ C\in\mathbb{R}$$

ដូចនេះ $\boxed{\int\frac{5x^2+20x+6}{x^3+2x^2+x}dx=\ln\left|\frac{x^6}{x+1}\right|-\frac{9}{x+1}+C \quad ;\ C\in\mathbb{R}}$

V. ក. រកសមីការស្តង់ដានៃប៉ារ៉ាបូល

ដោយ កំពូល $o(0,0)$ និង កំណុំ F ស្ថិតនៅលើអ័ក្សអរដោនេ គេបាន អ័ក្សឆ្លុះជាអ័ក្សឈរ

គេបាន សមីការស្តង់ដានៃប៉ារ៉ាបូលគឺ $(x-h)^2=4p(y-k)$

- កំពូល$(h,k)$ គឺ កំពូល $o(0,0)$ $\Rightarrow h=0, k=0$
- ប៉ារ៉ាបូលកាត់តាមចំណុច $A(2,6)$

គេបាន $(2-0)^2=4p(6-0)$ $\Leftrightarrow$ $4=24p$ $\Rightarrow$ $p=\frac{4}{24}=\frac{1}{6}$

គេបាន សមីការប៉ារ៉ាបូលគឺ $x^2=\frac{4}{6}y$ $\Leftrightarrow$ $x^2=\frac{2}{3}y$

ដូចនេះ $\boxed{\text{ប៉ារ៉ាបូលមានសមីការ } x^2=\frac{2}{3}y}$

ខ. រកតម្លៃនៃ $x_1$

បើ $B\left(x_1,\frac{3}{2}\right)$ ស្ថិតនៅលើប៉ារ៉ាបូលនេ

គេបាន $x_1^2=\frac{2}{3}\left(\frac{3}{2}\right)$ $\Leftrightarrow$ $x_1=\pm1$

ដូចនេះ $\boxed{x_1=\pm1}$

លឹម សីហា

សង់ប៉ារ៉ាបូល




VI. ១. រកសមីការប្លង់ P ដែលកាត់តាម A ហើយកែងនឹងបន្ទាត់ AK

$A(3,2,0)$ ; $K(0,-1,3)$ $\quad \Rightarrow \overrightarrow{AK}(0-3,-1-2,3-0) \Rightarrow \overrightarrow{AK}(-3,-3,3)$

សមីការប្លង់ (P) កំណត់ដោយ $a(x-x_o)+b(y-y_o)+c(z-z_o)=0$

- (P) កាត់តាម $A(3,2,0)$ $\quad \Rightarrow x_o=3,\ y_o=2,\ z_o=0$

- $(p)\perp(AK) \Rightarrow (P)\perp\overrightarrow{AK}(-3,-3,3) \Rightarrow a=-3, b=-3, c=3$

$\Rightarrow (P):\ -3(x-3)-3(y-2)+3(z-0) \quad \Leftrightarrow (P):\ -3x-3y+3z+15=0$

ដូចនេះ សមីការប្លង់$(P):\ -3x-3y+3z+15=0$

លឹម សីហា

២. ផ្ទៀងផ្ទាត់ថាចំណុច B, C និង D ជាចំណុចរបស់ប្លង់ P

- $B(5,0,0)$; $C(0,5,0)$ ; $D(0,0,-5)$

- $(P):\ -3x-3y+3z+15=0$

យើងបាន

- $B\in(P) \Leftrightarrow -3(5)-3(0)+3(0)+15=0 \Rightarrow 0=0$ ពិត

- $C\in(P) \Leftrightarrow -3(0)-3(5)+3(0)+15=0 \Rightarrow 0=0$ ពិត

- $D\in(P) \Leftrightarrow -3(0)-3(0)+3(-5)+15=0 \Rightarrow 0=0$ ពិត

ដូចនេះ ចំណុច B, C និង D ជាចំណុចរបស់ប្លង់ P

៣. គណនាផ្ទៃក្រឡានៃត្រីកោណ BCD

$S_{\Delta BCD} = \dfrac{1}{2}\left|\overrightarrow{BC}\times\overrightarrow{BD}\right|$

- $B(5,0,0)$; $C(0,5,0)$ ; $D(0,0,-5)$
- $\Rightarrow \overrightarrow{BC}(-5,5,0)$
- $\Rightarrow \overrightarrow{BD}(-5,0,-5)$

$$\overrightarrow{BC}\times\overrightarrow{BD} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -5 & 5 & 0 \\ -5 & 0 & -5 \end{vmatrix} = (-25-0)\,\vec{i} - (25-0)\,\vec{k} + (0-25)\,\vec{k}$$

$$= -25\,\vec{i} - 25\,\vec{j} - 25\,\vec{k}$$

$$\Rightarrow \left|\overrightarrow{BC}\times\overrightarrow{BD}\right| = \sqrt{(-25)^2+(-25)^2+(-25)^2} = \sqrt{3\cdot 25^2} = 25\sqrt{3}$$

$$\Rightarrow S_{\Delta BCD} = \frac{1}{2}\cdot 25\sqrt{3} = \frac{25\sqrt{3}}{2}$$

ដូចនេះ $\boxed{S_{\Delta BCD} = \dfrac{25\sqrt{3}}{2} \text{ ឯកតាផ្ទៃ}}$

លឹម សីហា

៤. គណនាប្រវែង AK

$\overrightarrow{AK}(-3,-3,3) \Rightarrow \left|\overrightarrow{AK}\right| = \sqrt{(-3)^2+(-3)^2+3^2} = 3\sqrt{3}$

ដូចនេះ $\boxed{AK = 3\sqrt{3} \text{ ឯកតាប្រវែង}}$

ទាញរកមាឌនៃតេត្រាអ៊ែត KBCD

$\overrightarrow{AK}\perp(P) \Rightarrow AK$ ជាកម្ពស់នៃតេត្រាអ៊ែតKBCD

$$V_{\text{តេត្រាអ៊ែត}} = \frac{1}{3}\cdot AK\cdot S_{\Delta BCD}$$
$$= \frac{1}{3}\cdot 3\sqrt{3}\cdot\frac{25\sqrt{3}}{2}$$
$$= \frac{75}{2}$$

ដូចនេះ $\boxed{V_{KBCD} = \dfrac{75}{2} \text{ ឯកតាមាឌ}}$

VII. ១. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$

យើងមាន $y = f(x) = -x - \dfrac{4\ln x}{x}$ យើងបាន

$$\lim_{x\to 0^+} f(x) = \lim_{x\to 0^+}\left(-x - \frac{4\ln x}{x}\right) = -0 - (-\infty) = +\infty$$ ដូចនេះ $\boxed{\lim\limits_{x\to 0^+} f(x) = +\infty}$

$$\lim_{x\to +\infty} f(x) = \lim_{x\to +\infty}\left(-x - \frac{4\ln x}{x}\right) = -(+\infty) - 0 = -\infty$$ ដូចនេះ $\boxed{\lim\limits_{x\to +\infty} f(x) = -\infty}$

ទាញរកសមីការអាស៊ីមតូតឈរនៃក្រាប C

ដោយ $\lim\limits_{x\to 0^+} f(x) = +\infty$ ដូចនេះ $\boxed{\text{បន្ទាត់ } x = 0 \text{ ជាអាស៊ីមតូតឈរ}}$

២. បង្ហាញថាបន្ទាត់ $L : y = -x$ ជាអាស៊ីមតូតទ្រេតនៃក្រាបC

យើងមាន $f(x) = -x - \dfrac{4\ln x}{x}$

ដោយ $\lim\limits_{x\to +\infty} [f(x) - (-x)] = \lim\limits_{x\to +\infty}\left(-\dfrac{4\ln x}{x}\right) = 0$

ដូចនេះ $\boxed{\text{បន្ទាត់ } L : \ y = -x \text{ ជាអាស៊ីមតូតទ្រេត}}$

លីម សីហា

សិក្សាទីតាំងរវាងក្រាបC និងបន្ទាត់ L

$(C) : \ y_c = f(x) = -x - \dfrac{4\ln x}{x}$ ; $(L) : \ y_L = -x$

$\Rightarrow y_c - y_L = -\dfrac{4\ln x}{x}$ ដោយ $x > 0$ $\Rightarrow y_c - y_L$ មានសញ្ញាតាមភាគយក $-4\ln x$

- $y_c - y_L = 0 \Leftrightarrow -4\ln x = 0 \quad \Leftrightarrow \ln x = 0 \Rightarrow x = 1$
- $y_c - y_L < 0 \Leftrightarrow -4\ln x < 0 \quad \Leftrightarrow \ln x > 0 \Rightarrow x > 1$
- $y_c - y_L > 0 \Leftrightarrow -4\ln x > 0 \quad \Leftrightarrow \ln x < 0 \Rightarrow x < 1$

ដូចនេះ

| |
|---|
| ពេល $x = 1$ ក្រាប C កាត់បន្ទាត់ L |
| ពេល $x \in (1, +\infty)$ ក្រាប C ស្ថិតនៅក្រោមបន្ទាត់ L |
| ពេល $x \in (0, 1)$ ក្រាប C ស្ថិតនៅលើបន្ទាត់ L |

៣. បង្ហាញថាដេរីវេ $f'(x) < 0$ បើគេដឹងថា $x^2 + 4 - 4\ln x > 0$ ចំពោះ $x > 0$

$$f'(x) = \left(-x - \frac{4\ln x}{x}\right)' = -1 - \frac{(4\ln x)'x - (x')4\ln x}{x^2} = -1 - \frac{4 - 4\ln x}{x^2}$$
$$= \frac{-x^2 - 4 + 4\ln x}{x^2} = -\frac{x^2 + 4 - 4\ln x}{x^2}$$

ដោយ $x^2 + 4 - 4\ln x > 0$ ចំពោះ $x > 0$ យើងបាន $\dfrac{x^2 + 4 - 4\ln x}{x^2} > 0$

ដូចនេះ $\boxed{f'(x) = -\dfrac{x^2 + 4 - 4\ln x}{x^2} < 0}$

សង់តារាងអថេរភាពនៃ f

| $x$ | $0$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | ‖ | $-$ | |
| $f(x)$ | ‖ $+\infty$ | ↘ | $-\infty$ |

លឹម សីហា

រកកូអរដោនេនៃចំណុច A និងសមីការនៃបន្ទាត់ D

ដោយ បន្ទាត់ D ប៉ះនឹងក្រាប C យើងបាន D កំណត់ដោយ

$(D): \; y = f'(x_o)(x - x_o) + f(x_o)$

បម្រាប់

- D ប៉ះនឹងក្រាប C ត្រង់ចំណុច $A(x_A, y_A)$ $\Rightarrow f'(x_o) = f'(x_A) = -\dfrac{x_A^2 + 4 - 4\ln x_A}{x_A^2}$

  $f(x_o) = f(x_A) = y_A$

- D ស្របនឹងបន្ទាត់ $L: \; y = -x \Rightarrow f'(x_A) = -1$

យើងបាន

$$-\frac{x_A^2 + 4 - 4\ln x_A}{x_A^2} = -1 \quad \Leftrightarrow -x_A^2 - 4 + 4\ln x_A = -x_A^2$$

$$4\ln x_A = 4$$

$$\ln x_A = 1 \quad \Rightarrow x_A = e$$

$$\Longrightarrow y_A = f(x_A) = f(e) = -e - \frac{4}{e}$$

ដូចនេះ $\boxed{\text{ចំណុច } A\left(e, -e - \frac{4}{e}\right)}$

$$D:\ y = f'(x_A)(x - x_A) + f(x_A) = -(x - e) + \left(-e - \frac{4}{e}\right) = -x - \frac{4}{e}$$

ដូចនេះ $\boxed{(D):\ y = -x - \frac{4}{e}}$

៤. សង់ L, D និងក្រាប C



រកតម្លៃ a ដើម្បីឲ្យ $S(a) = 2$ ឯកតាផ្ទៃ

ដោយ $S(a)$ ជាផ្ទៃក្រឡាផ្នែកប្លង់កំណត់ដោយក្រាបC និងអាស៊ីមតូតទ្រេតL ដែលត្រូវនឹង $1 \le x \le a$

យើងបាន $S(a) = \int_1^a [-x - f(x)]\, dx = \int_1^a \frac{4\ln x}{x} dx = \int_1^a 4 \cdot \ln x (\ln x)' dx$

$$= \left[\frac{4\ln^2 x}{2}\right]_1^a = 2\ln^2 a - 2\ln^2 1 = 2\ln^2 a$$

$$S(a) = 2 \quad \Rightarrow 2\ln^2 a = 2 \Rightarrow \ln^2 a = 1 \Rightarrow \ln a = \pm 1 \Rightarrow a = e^{\pm 1}$$

តែ $a = e^{-1} = \frac{1}{e} < 1$ មិនយក ដូចនេះ $\boxed{a = e}$

លីម សីហា

# វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡង
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨

## វិញ្ញាសាទី៨

I. (១០ពិន្ទុ) ក្នុងប្រអប់មួយមានខ្មៅដៃពណ៌ខៀវ 5 ដើម និង ខ្មៅដៃពណ៌ក្រហម 4 ដើម។ សិស្សម្នាក់បានចាប់យកខ្មៅដៃ 3 ព្រមគ្នាចេញពីប្រអប់ដោយចៃដន្យ។

១. រកប្រូបាបដែល «សិស្សយកបានខ្មៅដៃពណ៌ខៀវ 2 ដើម និង ខ្មៅដៃពណ៌ក្រហម 1 ដើម»

២. រកប្រូបាបដែល «សិស្សយកបានខ្មៅដៃពណ៌ដូចគ្នា»

II. (២០ពិន្ទុ) គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 1}\dfrac{x^3-x^2+x-1}{x-1}$

ខ. $\lim\limits_{x\to -\frac{\pi}{2}}\dfrac{\sin^2 x-1}{1+\sin x}$

គ. $\lim\limits_{x\to +\infty}\left(\sqrt{x^2+x}-x\right)$

ឃ. $\lim\limits_{x\to 0}\dfrac{(e^{-x}+e^{x})\sin^2 x}{2x^2}$

ង. $\lim\limits_{x\to +\infty}\left(\ln(x+2)-\ln x-\dfrac{2}{x+2}+\dfrac{1}{4}\right)$

III. (១៥ពិន្ទុ) គេឲ្យចំនួនកុំផ្លិច $Z=\dfrac{2\left(-1+i\sqrt{3}\right)}{1+i\sqrt{3}}$ ។

១. សរសេរ $Z$ ជាទម្រង់ពីជគណិត រួចជាទម្រង់ត្រីកោណមាត្រ។

២. សរសេរ $Z'=1+i$ ជាទម្រង់ត្រីកោណមាត្រ រួចទាញរកម៉ូឌុល និងអាគុយម៉ង់នៃចំនួនកុំផ្លិច $\dfrac{Z'}{Z}$ ។

IV. (១៥ពិន្ទុ)

១. ដោះស្រាយសមីការ $(E):\ y''+5y'+6y=0$ ។

២. កំណត់ចម្លើយមួយនៃសមីការ$(E)$ បើគេដឹងថាបន្ទាត់ $D: y=x-1$ ប៉ះក្រាបនៃចម្លើយត្រង់ $x=0$។

V. (៣០ពិន្ទុ) ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $\left(O,\vec{i},\vec{j},\vec{k}\right)$ មួយគេមានចំណុច $A(-1,1,0)$; $B(2,0,1)$; $C(1,2,2)$; $D(0,1,-2)$ និង $M(x,y,z)$ ។

១. រកទំនាក់ទំនងរវាង $x,y$ និង $z$ ដើម្បីឲ្យ $\overrightarrow{AM}$ កែងនឹង $\overrightarrow{BM}$ ។ តើសំណុំចំណុចនៃចំណុច $M$ ជាអ្វី?

២. គណនា $\vec{n}=\overrightarrow{BC}\times\overrightarrow{BD}$ ។ រកចំនួនពិត $m$ ដើម្បីឲ្យផ្ទៃក្រឡា $S$ នៃ $\Delta BCD$ ផ្ទៀងផ្ទាត់សមភាព $S=\sqrt[3]{e^m}$ ។

៣. រកសមីការប្លង់ BCD ។ រកកូអរដោនេនៃចំណុចប្រសព្វ N រវាងប្លង់ BCD និងបន្ទាត់ $L: \frac{x-1}{1} = \frac{y+1}{-1} = \frac{z}{1}$ ។

៤. គណនាចម្ងាយពីចំណុច A ទៅប្លង់ BCD ។ រួចទាញរកមាឌនៃតេត្រាអ៊ែត ABCD ។

VI. (៣៥ពិន្ទុ) f ជាអនុគមន៍កំណត់ចំពោះ $x \in D = (-\infty, 0) \cup (1, +\infty)$ ដោយ $y = f(x) = -\frac{x}{2} + \ln\left(\frac{x-1}{x}\right)$ ហើយមានខ្សែកោង C នៅក្នុងតម្រុយអរតូណរម៉ាល់មួយ។

១. គណនា $\lim_{x\to-\infty} f(x)$, $\lim_{x\to+\infty} f(x)$. $\lim_{x\to 0^-} f(x)$ និង $\lim_{x\to 1^+} f(x)$។
រកសមីការអាស៊ីមតូតឈរទាំងពីរនៃក្រាប C ។

២. គណនា និងសិក្សាសញ្ញានៃ $f'(x)$ បើដឹងថា $x(x-1) > 0$ ចំពោះគ្រប់ $x \in D$ ។
គណនាតម្លៃអប្បបរមា និងអតិបរមានៃអនុគមន៍ f ។ សង់តារាងអថេរភាពនៃ f។

៣. បង្ហាញថាបន្ទាត់ $L: \ y = -\frac{x}{2}$ ជាអាស៊ីមតូតទ្រេតនៃខ្សែកោង C ។

៤. សង់អាស៊ីមតូតទាំងអស់ និងក្រាប C (គេយក $\ln 2 = 0.7$, $\ln\left(\frac{1}{2}\right) = -\ln 2 = -0.7$ )
ក្នុងតម្រុយអរតូណរម៉ាល់មួយ។ រកតម្លៃ a ដើម្បីឲ្យសមីការ $-\frac{x}{2} + \ln\left(\frac{x-1}{x}\right) = a$ មានឫសអវិជ្ជមានពីរផ្សេងគ្នា ដោយប្រើខ្សែកោង C។

លឹម សុីហា

## [ដំណោះស្រាយ]

I. ១. រកប្រូបាប A : «សិស្សយកបានខ្មៅដៃពណ៌ខៀវ 2 ដើម និង ខ្មៅដៃពណ៌ក្រហម 1 ដើម»

តាមរូបមន្ត $P(A)=\dfrac{n(A)}{n(S)}$ ដោយ $n(A)=C(5,2)C(4,1)=\dfrac{5!}{3!2!}\cdot\dfrac{4!}{3!1!}=\dfrac{5\times 4}{2}\cdot\dfrac{4}{1}=40$

$$n(S)=C(9,3)=\frac{9!}{6!3!}=\frac{9\times 8\times 7}{3\times 2\times 1}=84$$

គេបាន $P(A)=\dfrac{40}{84}=\dfrac{10}{21}$ ដូចនេះ $\boxed{P(A)=\dfrac{10}{21}}$

២. រកប្រូបាប B : «សិស្សយកបានខ្មៅដៃពណ៌ដូចគ្នា»

តាមរូបមន្ត $P(B)=\dfrac{n(B)}{n(S)}$ ដោយ $n(B)=C(5,3)+C(4,3)=\dfrac{5!}{2!3!}+\dfrac{4!}{1!3!}=14$

$$n(S)=84$$

គេបាន $P(B)=\dfrac{14}{84}=\dfrac{1}{6}$ ដូចនេះ $\boxed{P(B)=\dfrac{1}{6}}$

II. គណនាលីមីត៖

ក. $\lim\limits_{x\to 1}\dfrac{x^3-x^2+x-1}{x-1}$ (មានរាងមិនកំណត់$\frac{0}{0}$)

$$=\lim_{x\to 1}\frac{(x-1)x^2+(x-1)}{(x-1)}=\lim_{x\to 1}\frac{(x-1)(x^2+1)}{(x-1)}=\lim_{x\to 1}(x^2+1)=1^2+1=2$$

$$\boxed{\lim_{x\to 1}\frac{x^3-x^2+x-1}{x-1}=2}$$

ខ. $\lim\limits_{x\to -\frac{\pi}{2}}\dfrac{\sin^2 x-1}{1+\sin x}$ (មានរាងមិនកំណត់$\frac{0}{0}$)

$$=\lim_{x\to -\frac{\pi}{2}}\frac{(\sin x-1)(\sin x+1)}{\sin x+1}=\lim_{x\to -\frac{\pi}{2}}(\sin x-1)=\sin\left(-\frac{\pi}{2}\right)-1=-1-1=-2$$

$$\boxed{\lim_{x\to -\frac{\pi}{2}}\frac{\sin^2 x-1}{1+\sin x}=-2}$$

លឹម សីហា

គ. $\lim\limits_{x\to+\infty}\left(\sqrt{x^2+x}-x\right)$ (មានរាងមិនកំណត់ $+\infty-\infty$)

$$=\lim_{x\to+\infty}\frac{\left(\sqrt{x^2+x}-x\right)\left(\sqrt{x^2+x}+x\right)}{\left(\sqrt{x^2+x}+x\right)}=\lim_{x\to+\infty}\frac{x^2+x-x^2}{x\sqrt{1+\frac{1}{x}}+x}$$

$$=\lim_{x\to+\infty}\frac{x}{x\left(\sqrt{1+\frac{1}{x}}+1\right)}=\lim_{x\to+\infty}\frac{1}{\sqrt{1+\frac{1}{x}}+1}=\frac{1}{1+1}=\frac{1}{2}$$

$$\boxed{\lim_{x\to+\infty}\left(\sqrt{x^2+x}-x\right)=\frac{1}{2}}$$

ឃ. $\lim\limits_{x\to0}\dfrac{(e^{-x}+e^{x})\sin^2x}{2x^2}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to0}\frac{e^{-x}+e^{x}}{2}\cdot\frac{\sin^2x}{x^2}=\frac{e^0+e^0}{2}\times1=\frac{2}{2}=1\qquad\boxed{\lim_{x\to0}\frac{(e^{-x}+e^{x})\sin^2x}{2x^2}=1}$$

ង. $\lim\limits_{x\to+\infty}\left(\ln(x+2)-\ln x-\dfrac{2}{x+2}+\dfrac{1}{4}\right)=\lim\limits_{x\to+\infty}\left(\ln\dfrac{x+2}{x}-\dfrac{2}{x+2}+\dfrac{1}{4}\right)$

$$=\lim_{x\to+\infty}\left(\ln\left(1+\frac{2}{x}\right)-\frac{2}{x+2}+\frac{1}{4}\right)$$

$$=\ln1-0+\frac{1}{4}=\frac{1}{4}$$

$$\boxed{\lim_{x\to+\infty}\left(\ln(x+2)-\ln x-\frac{2}{x+2}+\frac{1}{4}\right)=\frac{1}{4}}$$

លីម សីហា

III. ១. សរសេរ $Z$ ជាទម្រង់ពីជគណិត រួចជាទម្រង់ត្រីកោណមាត្រ

$$Z=\frac{2\left(-1+i\sqrt{3}\right)}{1+i\sqrt{3}}=\frac{-2+i2\sqrt{3}}{1+i\sqrt{3}}\times\frac{1-i\sqrt{3}}{1-i\sqrt{3}}=\frac{-2+i2\sqrt{3}+i2\sqrt{3}-i^22\sqrt{3}^2}{1-i^2\sqrt{3}^2}$$

$$=\frac{4+i4\sqrt{3}}{4}=1+i\sqrt{3}$$

ដូចនេះ $\boxed{\text{ទម្រង់ពិជគណិតគឺ } Z=1+i\sqrt{3}}$

$$Z=1+i\sqrt{3}=2\left(\frac{1}{2}+i\frac{\sqrt{3}}{2}\right)=2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)$$

ដូចនេះ $\boxed{\text{ទម្រង់ត្រីកោណមាត្រគឺ } Z=2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)}$

២. សរសេរ $Z' = 1 + i$ ជាទម្រង់ត្រីកោណមាត្រ

$$Z' = 1 + i = \sqrt{2}\left(\frac{1}{\sqrt{2}} + i\frac{1}{\sqrt{2}}\right) = \sqrt{2}\left(\frac{\sqrt{2}}{2} + i\frac{\sqrt{2}}{2}\right) = \sqrt{2}\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)$$

ដូចនេះ $\boxed{Z' = \sqrt{2}\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)}$

ទាញរកម៉ូឌុល និងអាគុយម៉ង់នៃចំនួនកុំផ្លិច $\frac{Z'}{Z}$

$$\frac{Z'}{Z} = \frac{\sqrt{2}\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)}{2\left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right)} = \frac{\sqrt{2}}{2}\left[\cos\left(\frac{\pi}{4} - \frac{\pi}{3}\right) + i\sin\left(\frac{\pi}{4} - \frac{\pi}{3}\right)\right]$$

$$= \frac{\sqrt{2}}{2}\left(\cos\frac{-\pi}{12} + i\sin\frac{-\pi}{12}\right)$$

ដូចនេះ $\boxed{\text{ម៉ូឌុល } r = \frac{\sqrt{2}}{2} \quad \text{អាគុយម៉ង់ } \theta = -\frac{\pi}{12} \text{ ឬ } \theta = -\frac{\pi}{12} + 2k\pi \quad ; k \in \mathbb{Z}}$

IV. ១. ដោះស្រាយសមីការ (E) : $y'' + 5y' + 6y = 0$

(E) មានសមីការសម្គាល់ $r^2 + 5r + 6 = 0$ មានឫស $r_1 = -2$ ; $r_2 = -3$

ដូចនេះ $\boxed{\text{ចម្លើយនៃសមីការ (E) គឺ } y = Ae^{-2x} + Be^{-3x} \quad ; A, B \in \mathbb{R}}$

២. កំណត់ចម្លើយមួយនៃសមីការ(E) បើគេដឹងថាបន្ទាត់ $D : y = x - 1$ ប៉ះក្រាបនៃចម្លើយត្រង់ $x = 0$

យើងមាន ចម្លើយនៃសមីការ (E) គឺ $y = f(x) = Ae^{-2x} + Be^{-3x} \quad ; A, B \in \mathbb{R}$

- ដោយ $D : y = x - 1$ ប៉ះ (E) ត្រង់ $x = 0 \Rightarrow \quad f'(0) = 1$ ហើយ $f(0) = -1$
- $f'(x) = \left(Ae^{-2x} + Be^{-3x}\right)' = -2Ae^{2x} - 3Be^{2x} \Rightarrow f'(0) = -1 \quad \Leftrightarrow -2A - 3B = 1 \; (1)$
- $f(0) = -1 \quad \Leftrightarrow A + B = -1 \quad \Rightarrow A = -1 - B$

យក $A = -1 - B$ ជំនួសក្នុងសមីការ (1) យើងបាន $-2(-1 - B) - 3B = 1 \Rightarrow B = 1$

$\Rightarrow \quad A = -1 - 1 = -2$

ដូចនេះ $\boxed{\text{ចម្លើយមួយនៃ (E) គឺ } y = -2e^{-2x} + e^{-3x}}$

លីម សីហា

V. ១. រកទំនាក់ទំនងរវាង $x, y$ និង $z$ ដើម្បីឲ្យ $\overrightarrow{AM}$ កែងនឹង $\overrightarrow{BM}$

$$\overrightarrow{AM}\perp\overrightarrow{BM} \iff \overrightarrow{AM}\cdot\overrightarrow{BM}=0$$

$A(-1,1,0);\ B(2,0,1);\ M(x,y,z)$

- $\overrightarrow{AM}(x+1, y-1, z-0) \Rightarrow \overrightarrow{AM}(x+1, y-1, z)$
- $\overrightarrow{BM}(x-2, y-0, z-1) \Rightarrow \overrightarrow{BM}(x-2, y, z-1)$

$$\begin{aligned}\overrightarrow{AM}\cdot\overrightarrow{BM} &= (x+1)(x-2)+(y-1)y+z(z-1)\\ &= x^2-2x+x-2+y^2-y+z^2-z\\ &= x^2-x+y^2-y+z^2-z-2\\ &= \left(x-\tfrac{1}{2}\right)^2-\left(\tfrac{1}{2}\right)^2+\left(y-\tfrac{1}{2}\right)^2-\left(\tfrac{1}{2}\right)^2+\left(z-\tfrac{1}{2}\right)^2-\left(\tfrac{1}{2}\right)^2-2\\ &= \left(x-\tfrac{1}{2}\right)^2+\left(y-\tfrac{1}{2}\right)^2+\left(z-\tfrac{1}{2}\right)^2-2-\tfrac{3}{4}\\ &= \left(x-\tfrac{1}{2}\right)^2+\left(y-\tfrac{1}{2}\right)^2+\left(z-\tfrac{1}{2}\right)^2-\tfrac{11}{4}\end{aligned}$$

$$\overrightarrow{AM}\cdot\overrightarrow{BM}=0 \Leftrightarrow \left(x-\tfrac{1}{2}\right)^2+\left(y-\tfrac{1}{2}\right)^2+\left(z-\tfrac{1}{2}\right)^2-\tfrac{11}{4}=0$$

ដូចនេះ ទំនាក់ទំនងរវាង $x, y$ និង $z$ ដើម្បីឲ្យ $\overrightarrow{AM}$ កែងនឹង $\overrightarrow{BM}$ គឺ

$$\boxed{\left(x-\tfrac{1}{2}\right)^2+\left(y-\tfrac{1}{2}\right)^2+\left(z-\tfrac{1}{2}\right)^2=\tfrac{11}{4}}$$

តើសំណុំចំណុចនៃចំណុច $M$ ជាអ្វី?

តាមទំនាក់ទំនង $\left(x-\tfrac{1}{2}\right)^2+\left(y-\tfrac{1}{2}\right)^2+\left(z-\tfrac{1}{2}\right)^2=\tfrac{11}{4}$

យើងបាន | សំណុំចំនុច $M(x,y,z)$ គឺជារង្វង់ដែលមានផ្ចិត $\left(\frac{1}{2},\frac{1}{2},\frac{1}{2}\right)$ និងកាំ $r=\sqrt{\frac{11}{4}}=\frac{\sqrt{11}}{2}$ |

២. គណនា $\overrightarrow{n}=\overrightarrow{BC}\times\overrightarrow{BD}$

$B(2,0,1);\ C(1,2,2);\ D(0,1,-2)$

- $\overrightarrow{BC}(1-2, 2-0, 2-1) \Rightarrow \overrightarrow{BC}(-1,2,1)$
- $\overrightarrow{BD}(0-2, 1-0, -2-1) \Rightarrow \overrightarrow{BD}(-2,1,-3)$

$$\vec{n} = \left|\overrightarrow{BC} \times \overrightarrow{BD}\right| = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -1 & 2 & 1 \\ -2 & 1 & -3 \end{vmatrix} = (-6-1)\,\vec{i} - (3+2)\,\vec{j} + (-1+4)\,\vec{k}$$

$$= -7\vec{i} - 5\vec{j} + 3\vec{k}$$

ដូចនេះ $\boxed{\vec{n}\,(-7,-5,3)}$

រកចំនួនពិត m ដើម្បីឲ្យផ្ទៃក្រឡា S នៃ $\Delta BCD$ ផ្ទៀងផ្ទាត់សមភាព $S = \sqrt[3]{e^m}$

$$S_{\Delta BCD} = \frac{1}{2}\left|\overrightarrow{BC} \times \overrightarrow{BD}\right| = \frac{1}{2}\sqrt{(-7)^2 + (-5)^2 + 3^2} = \frac{1}{2}\sqrt{83}$$

$$S_{\Delta BCD} = \sqrt[3]{e^m} \Rightarrow \sqrt[3]{e^m} = \frac{\sqrt{83}}{2} \Leftrightarrow e^{\frac{m}{3}} = \left(\frac{83}{4}\right)^{\frac{1}{2}}$$

$$\Rightarrow \frac{m}{3} = \ln\left(\frac{83}{4}\right)^{\frac{1}{2}}$$

$$\Rightarrow m = \frac{3}{2}\ln\frac{83}{4}$$

លឹម សីហា

ដូចនេះ $\boxed{m = \frac{3}{2}\ln\frac{83}{4}}$

៣. រកសមីការប្លង់ BCD

ប្លង់BCD : $a(x-x_o) + b(y-y_o) + c(z-z_o) = 0$

- ប្លង់BCD កាត់តាមចំណុច $B(2,0,1)$
- វ៉ិចទ័រ $\vec{n}\,(-7,-5,3)$ ជាវ៉ិចទ័រណរម៉ាល់នៃ ប្លង់BCD

នាំឲ្យសមីការប្លង់ BCD : $-7(x-2) - 5(y-0) + 3(z-1) = 0$

$$-7x - 5y + 3z + 11 = 0$$

ដូចនេះ $\boxed{\text{សមីការប្លង់BCD} : -7x - 5y + 3z + 11 = 0}$

រកកូអរដោនេនៃចំណុចប្រសព្វ N រវាងប្លង់ BCD និងបន្ទាត់ L

- BCD : $-7x - 5y + 3z + 11 = 0 \quad (1)$
- L : $\frac{x-1}{1} = \frac{y+1}{-1} = \frac{z}{1}$

☞ $\dfrac{x-1}{1}=\dfrac{z}{1} \quad \Rightarrow \quad x=z+1 \quad (2)$

☞ $\dfrac{y+1}{-1}=\dfrac{z}{1} \quad \Rightarrow \quad y=-z-1 \quad (3)$

យក $(2),(3)$ ជួសក្នុងសមីការ $(1)$ យើងបាន $-7(z+1)-5(-z-1)+3z+11=0 \Rightarrow z=-9$

$\Rightarrow x=-9+1=-8 \quad ; \quad y=-(-9)-1=8$

ដូចនេះ $\boxed{\text{ចំណុច} N(-8,7,-9)}$

៤. គណនាចម្ងាយពីចំណុច A ទៅប្លង់ BCD

- $A(-1,1,0)$
- $BCD:\ -7x-5y+3z+11=0$

$$D(A,(BCD))=\frac{|-7(-1)-5(1)+3(0)+11|}{\sqrt{(-7)^2+(-5)^2+3^2}}=\frac{13}{\sqrt{83}}\times\frac{\sqrt{83}}{\sqrt{83}}=\frac{13\sqrt{83}}{83}$$

ដូចនេះ $\boxed{D(A,(BCD))=\dfrac{13\sqrt{83}}{83}\ \text{ឯកតាប្រវែង}}$

លឹម សីហា

ទាញរកមាឌនៃតេត្រាអ៊ែត ABCD

$$V_{ABCD}=\frac{1}{3}\cdot S_{\Delta BCD}\cdot h \qquad ; h=D(A,(BCD))$$

$$=\frac{1}{3}\times\frac{\sqrt{83}}{2}\times\frac{13\sqrt{83}}{83}=\frac{13}{6}$$

ដូចនេះ $\boxed{V_{ABCD}=\dfrac{13}{6}\ \text{ឯកតាមាឌ}}$

VI. ១. គណនា $\lim\limits_{x\to-\infty}f(x),\ \lim\limits_{x\to+\infty}f(x),\ \lim\limits_{x\to0^-}f(x)$ និង $\lim\limits_{x\to1^+}f(x)$

$$y=f(x)=-\frac{x}{2}+\ln\left(\frac{x-1}{x}\right)$$

$$\lim_{x\to-\infty}f(x)=\lim_{x\to-\infty}\left(-\frac{x}{2}+\ln\left(\frac{x-1}{x}\right)\right)=\lim_{x\to-\infty}\left(-\frac{x}{2}+\ln\left(1-\frac{1}{x}\right)\right)=-\frac{-\infty}{2}+\ln 1=+\infty$$

ដូចនេះ $\boxed{\lim\limits_{x\to-\infty}f(x)=+\infty}$

$$\lim_{x\to+\infty} f(x) = \lim_{x\to+\infty}\left(-\frac{x}{2}+\ln\left(\frac{x-1}{x}\right)\right) = \lim_{x\to+\infty}\left(-\frac{x}{2}+\ln\left(1-\frac{1}{x}\right)\right) = -\infty$$

ដូចនេះ $\boxed{\lim_{x\to+\infty} f(x) = -\infty}$

$$\lim_{x\to0^-} f(x) = \lim_{x\to0^-}\left(-\frac{x}{2}+\ln\left(\frac{x-1}{x}\right)\right) = 0+\ln(+\infty) = +\infty \qquad \boxed{\lim_{x\to0^-} f(x) = +\infty}$$

$$\lim_{x\to1^+} f(x) = \lim_{x\to1^+}\left(-\frac{x}{2}+\ln\left(\frac{x-1}{x}\right)\right) = -\frac{1}{2}+\ln\left(0^+\right) = -\infty \qquad \boxed{\lim_{x\to1^+} f(x) = -\infty}$$

រកសមីការអាស៊ីមតូតឈរទាំងពីរនៃក្រាប C

- ដោយ $\lim_{x\to1^+} f(x) = -\infty \quad ; \quad \lim_{x\to0^-} f(x) = +\infty$

ដូចនេះ បន្ទាត់ $x = 1, x = 0$ ជាអាស៊ីមតូតឈរ

២. គណនា និងសិក្សាសញ្ញានៃ $f'(x)$ បើដឹងថា $x(x-1) > 0$ ចំពោះគ្រប់ $x \in D$

$$f'(x) = \left(-\frac{x}{2}+\ln\left(\frac{x-1}{x}\right)\right)' = -\frac{1}{2}+\frac{\left(\frac{x-1}{x}\right)'}{\left(\frac{x-1}{x}\right)} = -\frac{1}{2}+\frac{\frac{x-(x-1)}{x^2}}{\frac{x-1}{x}} = -\frac{1}{2}+\frac{1}{x(x-1)}$$

ដូចនេះ $\boxed{f'(x) = -\frac{1}{2}+\frac{1}{x(x-1)}}$

លឹម សីហា

$$f'(x) = -\frac{1}{2}+\frac{1}{x(x-1)} = \frac{-x(x-1)+2}{x(x-1)} = \frac{-x^2+x+2}{x(x-1)}$$

ដោយ $x(x-1) > 0$ ចំពោះគ្រប់ $x \in D$ យើងបាន $f'(x)$ មានសញ្ញាដូចភាគយក $-x^2+x+2$

$$f'(x) = 0 \Leftrightarrow \quad -x^2+x+2 = 0$$

$$\Delta = b^2-4ac = 1^2-4(-1)2 = 9 \quad \Rightarrow \sqrt{\Delta} = 3$$

$$x_1 = \frac{-b-\sqrt{\Delta}}{2a} = \frac{-1-3}{2(-1)} = 2$$

$$x_2 = \frac{-b+\sqrt{\Delta}}{2a} = \frac{-1+3}{2(-1)} = -1$$

តារាងសញ្ញានៃ $f'(x)$

| $x$ | $-\infty$ | | $-1$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | ‖ | ////// | ‖ | $+$ | $0$ | $-$ | |

- $f'(x) < 0$ ពេល $x \in (-\infty, -1) \cup (2, +\infty)$
- $f'(x) > 0$ ពេល $x \in (-1, 0) \cup (1, 2)$

គណនាតម្លៃអប្បបរមា និងអតិបរមានៃអនុគមន៍ f

- ត្រង់ $x = -1; f'(x) = 0$ ហើយប្តូរសញ្ញាពី $-$ ទៅ $+$ យើងបាន f មានអប្បបរមាធៀបមួយ គឺ
  $f(-1) = \frac{1}{2} + \ln 2 = 0.5 + 0.7 = 1.2$ **តម្លៃអប្បបរមាគឺ $f(-1) = 1.2$**
- ត្រង់ $x = 2; f'(x) = 0$ ហើយប្តូរសញ្ញាពី $+$ ទៅ $-$ យើងបាន f មានអប្បបរមាធៀបមួយ គឺ
  $f(2) = -1 + \ln\frac{1}{2} = -1 - \ln 2 = -1 - 0.7$ **តម្លៃអតិបរមាគឺ $f(2) = -1.7$**

សង់តារាងអថេរភាពនៃ f

| $x$ | $-\infty$ | | $-1$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | ‖ | | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $+\infty$ | ↘ | $1.2$ | ↗ | $+\infty$ ‖ | | ‖ $-\infty$ | ↗ | $-1.7$ | ↘ | $-\infty$ |

៣. បង្ហាញថាបន្ទាត់ $L:\ y = -\frac{x}{2}$ ជាអាស៊ីមតូតទ្រេតនៃខ្សែកោង C

$$y = f(x) = -\frac{x}{2} + \ln\left(\frac{x-1}{x}\right)$$

ដោយ $\lim_{x\to\pm\infty} \ln\left(\frac{x-1}{x}\right) = \lim_{x\to\pm\infty} \ln\left(1 - \frac{1}{x}\right) = \ln 1 = 0$

ដូចនេះ **បន្ទាត់ $y = -\frac{x}{2}$ ជាអាស៊ីមតូតទ្រេតនៃក្រាប**

៤. សង់អាស៊ីមតូតទាំងអស់ និងក្រាប C




រកតម្លៃ a ដើម្បីឲ្យសមីការ $-\frac{x}{2}+\ln\left(\frac{x-1}{x}\right)=a$ មានឫសអវិជ្ជមានពីរផ្សេងគ្នា

$-\frac{x}{2}+\ln\left(\frac{x-1}{x}\right)=a$ គឺជាសមីការអាប់ស៊ីសរវាងក្រាប C និងបន្ទាត់ $y=a$

តាមក្រាបយើងបាន

- សមីការមានឫសអវិជ្ជមានពីរផ្សេងគ្នាលុះត្រាតែ $a \in (1.2, +\infty)$

ដូចនេះ $\boxed{a \in (1.2, +\infty)}$

លីម សីហា

# វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡង
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨

## វិញ្ញាសាទី៨

I. (១០ពិន្ទុ)

១. កំណត់ចំនួនពិត a និង b ដើម្បីឲ្យ $x_1 = 1 + i\sqrt{3}$ ជាឫសមួយនៃសមីការ $x^2 + ax + b = 0$ ។

២. រកឫស $x_2$ មួយទៀតនៃសមីការ។ សរសេរ $Z = \left(\frac{x_1}{x_2}\right)^2$ ជាទម្រង់ត្រីកោណមាត្រ។

II. (១៥ពិន្ទុ) គេចង់បង្កើតចំនួនមានលេខ 3 ខ្ទង់ដែលខ្ទង់ទាំងបីមានលេខខុសៗគ្នា ដោយយកចេញពីលេខ $1, 2, 3, 4, 5, 6, 7, 8, 9$ ។

១. រកចំនួនករណីអាច ។

២. រកប្រូបាប ដែលចំនួនមានលេខ 3 ខ្ទង់នោះ ជាពហុគុណនៃ 5 ។

៣. រកប្រូបាប ដែលចំនួនមានលេខ 3 ខ្ទង់នោះ ជាចំនួនគូ។

III. (១៥ពិន្ទុ) គេឲ្យសមីការឌីផេរ៉ង់ស្យែល $(E) : \; y'' - 3y' + 2y = 2x + 1$ ។

១. ដោះស្រាយសមីការ$(E_1) : \; y'' - 3y' + 2y = 0$ ។កំណត់ចម្លើយ f នៃ $(E_1)$ ដែល $f(0) = 3$ និង $f'(0) = 4$ ។

២. កំណត់ចំនួនពិត a និង b ដើម្បីឲ្យ $g(x) = ax + b$ ជាចម្លើយនៃ (E) ។

IV. (១៥ពិន្ទុ) អេលីប E មួយមានសមីការទូទៅ៖ $9x^2 + 4y^2 + 18x - 24y + 9 = 0$ ។

១. រកសមីការស្តង់ដានៃអេលីប E ។

២. រកប្រវែងអ័ក្សធំ និង អ័ក្សតូច ហើយរកកូអរដោនេនៃ ផ្ចិត កំពូល និង កំណុំនៃអេលីប E ។

V. (៣០ពិន្ទុ) គេមានអនុគមន៍ f កំណត់លើ $\mathbb{R}$ ដោយ $f(x) = \frac{1}{1 + e^x} + \frac{2}{9}x$ និង C តាងក្រាបរបស់ f ។

1. អនុគមន៍ g កំណត់លើ $\mathbb{R}$ ដោយ $g(x) = 2e^{2x} - 5e^x + 2$ ។

ក. ផ្ទៀងផ្ទាត់ថា $g(x) = (2e^x - 1)(e^x - 2)$ ។

ខ. ទាញយកតាមតម្លៃនៃ x ចំពោះសញ្ញានៃ $g(x)$ ។

លីម ស៊ីហា

2. ក. រក $\lim_{x\to+\infty} f(x)$ និង $\lim_{x\to-\infty} f(x)$ ។

ខ. អនុគមន៍ $f$ មានដេរីវេ $f'$ ។
បង្ហាញថាចំពោះគ្រប់ចំនួនពិត $x$ គេបាន $f'(x)$ និង $g(x)$ មានសញ្ញាដូចគ្នា។

គ. សិក្សាអថេរភាពនៃអនុគមន៍ $f$ លើ $\mathbb{R}$ ។

VI. (៤០ពិន្ទុ) $f$ ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដោយ $f(x) = 4 - x - 2e^{-x}$ ។គេតាងដោយ $C$ ជាក្រាបរបស់វា ។

១. ក. រក $\lim_{x\to+\infty} f(x)$ ។

ខ. បង្ហាញថាបន្ទាត់ $D$ មានសមីការ $y = -x + 4$ ជាអាស៊ីមតូតនៃខ្សែកោង $C$ ។

គ. តើខ្សែកោង $C$ នៅលើឬក្រោមបន្ទាត់ $D$ ចូរបញ្ជាក់។

ឃ. ផ្ទៀងផ្ទាត់ថាគ្រប់ចំនួនពិត $x$ ; $f(x) = \dfrac{4e^x - xe^x - 2}{e^x}$ ។

ង. រក $\lim_{x\to-\infty} f(x)$ (ប្រើលទ្ធផល $\lim_{x\to-\infty} xe^x = 0$ )។

២. ក. គណនា $f'(x)$ ។ សិក្សាអថេរភាពនៃ $f$ ។ កំណត់តម្លៃពិតនៃអតិបរមារបស់ $f$ ។

ខ. $A$ ជាចំណុចនៅលើខ្សែកោង $C$ ដែលមានអាប់ស៊ីស $0$ ។ កំណត់សមីការបន្ទាត់ប៉ះខ្សែកោង $C$ ត្រង់ចំណុច $A$ ។

គ. បង្ហាញថាសមីការ $f(x) = 0$ មានចម្លើយតែមួយគត់ដែលគេតាងដោយ $\beta$ នៅក្នុងចន្លោះ$[-1, 0]$។

លឹម សីហា

## [ដំណោះស្រាយ]

I. ១. កំណត់ចំនួនពិត a និង b

ដើម្បីឲ្យ $x_1 = 1 + i\sqrt{3}$ ជាឫសមួយនៃសមីការ $x^2 + ax + b = 0$

លុះត្រាតែ $x_1^2 + ax_1 + b = 0 \quad \Leftrightarrow \quad \left(1 + i\sqrt{3}\right)^2 + a\left(1 + i\sqrt{3}\right) + b = 0$

$$1 + 2i\sqrt{3} - 3 + a + ai\sqrt{3} + b = 0$$

$$(-2 + a + b) + \left(2\sqrt{3} + a\sqrt{3}\right)i = 0 + 0i$$

$$\Rightarrow \begin{cases} -2 + a + b = 0 & (1) \\ 2\sqrt{3} + a\sqrt{3} = 0 & (2) \end{cases}$$

$(2): \ 2\sqrt{3} + a\sqrt{3} = 0 \Rightarrow a = -2$

$(1): \ -2 + a + b = 0 \Rightarrow -2 - 2 + b = 0 \quad \Rightarrow b = 4$

ដូចនេះ $\boxed{a = -2, b = 4}$

២. រកឫស $x_2$ មួយទៀតនៃសមីការ

សមីការ $x^2 + ax + b = 0 \quad \Rightarrow x^2 - 2x + 4 = 0$

មាន ឫសជាចំនួនកុំផ្លិច $x_1 = 1 + i\sqrt{3} \quad \Rightarrow x_2 = 1 - i\sqrt{3}$

ដូចនេះ $\boxed{x_2 = 1 - i\sqrt{3}}$

សរសេរ $Z = \left(\dfrac{x_1}{x_2}\right)^2$ ជាទម្រង់ត្រីកោណមាត្រ

- $x_1 = 1 + i\sqrt{3} = 2\left(\dfrac{1}{2} + i\dfrac{\sqrt{3}}{2}\right) = 2\left(\cos\dfrac{\pi}{3} + i\sin\dfrac{\pi}{3}\right)$
- $x_2 = 1 - i\sqrt{3} = 2\left(\dfrac{1}{2} - i\dfrac{\sqrt{3}}{2}\right) = 2\left(\cos\dfrac{-\pi}{3} + i\sin\dfrac{-\pi}{3}\right)$

$$Z = \left(\frac{x_1}{x_2}\right)^2 = \left(\frac{2\left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right)}{2\left(\cos\frac{-\pi}{3} + i\sin\frac{-\pi}{3}\right)}\right)^2 = \left(\cos\left(\frac{\pi}{3} - \frac{-\pi}{3}\right) + i\sin\left(\frac{\pi}{3} - \frac{-\pi}{3}\right)\right)^2$$

$$= \left(\cos\frac{2\pi}{3} + i\sin\frac{2\pi}{3}\right)^2 = \cos\frac{4\pi}{3} + i\sin\frac{4\pi}{3}$$

ដូចនេះ $\boxed{Z = \cos\dfrac{4\pi}{3} + i\sin\dfrac{4\pi}{3}}$

II. ១. រកចំនួនករណីអាច

ដោយ ការបង្កើតចំនួនមានលេខ3ខ្ទង់ (គិតលំដាប់) ដែលខ្ទង់ទាំងបីមានលេខខុសៗគ្នា (គឺមិនច្រំដែល) ហើយយកចេញពីលេខ $1, 2, 3, 4, 5, 6, 7, 8, 9$

គេបាន ចំនួនករណីអាចគឺ $n(S) = P(9,3) = \dfrac{9!}{(9-3)!} = \dfrac{9\times8\times7\times6!}{6!} = 504$

ដូចនេះ ចំនួនករណីអាចគឺ $n(S) = 504$ ករណី

២. រកប្រូបាប A : « ចំនួនមានលេខ 3 ខ្ទង់នោះ ជាពហុគុណនៃ 5 »

តាមរូបមន្ត $P(A) = \dfrac{n(A)}{n(S)}$

ដោយ A : « ចំនួនមានលេខ 3 ខ្ទង់នោះ ជាពហុគុណនៃ 5 »

គេបាន លេខបីខ្ទង់ទាំងនោះត្រូវមានលេខខាងចុងគឺ លេខ 5

$\Rightarrow n(A) = P(8,2)\times P(1,1) = P(8,2) = \dfrac{8!}{6!} = 56$

គេបាន $P(A) = \dfrac{56}{504} = \dfrac{1}{9}$ ដូចនេះ $P(A) = \dfrac{1}{9}$

៣. រកប្រូបាប B : «ចំនួនមានលេខ 3 ខ្ទង់នោះ ជាចំនួនគូ»

តាមរូបមន្ត $P(B) = \dfrac{n(B)}{n(S)}$

ដោយ B : «ចំនួនមានលេខ 3 ខ្ទង់នោះ ជាចំនួនគូ»

គេបាន លេខបីខ្ទង់ទាំងនោះត្រូវមានលេខខាងចុង ជាលេខគូ គឺ 2 ឬ 4 ឬ 6 ឬ 8

$\Rightarrow P(B) = P(8,2)P(1,1) + P(8,2)P(1,1) + P(8,2)P(1,1) = 4\times8\times7 = 224$

គេបាន $P(B) = \dfrac{224}{504} = \dfrac{4}{9}$ ដូចនេះ $P(B) = \dfrac{4}{9}$

III. សមីការឌីផេរ៉ង់ស្យែល (E) : $y'' - 3y' + 2y = 2x + 1$

១. ដោះស្រាយសមីការ$(E_1)$ : $y'' - 3y' + 2y = 0$

$(E_1)$ មានសមីការសម្គាល់ $r^2 - 3r + 2 = 0$ មានឫស $r_1 = 1,\ r_2 = 2$

ដូចនេះ ចម្លើយនៃសមីការ $(E_1)$ គឺ $y = Ae^x + Be^{2x}$ ; $A, B \in \mathbb{R}$

កំណត់ចម្លើយ f នៃ $(E_1)$ ដែល $f(0) = 3$ និង $f'(0) = 4$

ចម្លើយនៃ$(E_1)$ គឺ $y = f(x) = Ae^x + Be^{2x}$ $\Rightarrow f'(x) = Ae^x + 2Be^{2x}$

- $f(0) = 3 \quad \Rightarrow Ae^0 + Be^0 = 3 \quad \Rightarrow A + B = 3\ (1)$

- $f'(0) = 4 \quad \Rightarrow Ae^0 + 2Be^0 = 4 \quad \Rightarrow A + 2B = 4 \ (2)$

$(1): \ A + B = 3 \quad \Rightarrow A = 3 - B$ ជំនួសក្នុង $(2)$

យើងបាន $3 - B + 2B = 4 \quad \Rightarrow B = 1 \quad ; \ A + B = 3 \quad \Rightarrow A = 2$

ដូចនេះ ចម្លើយ $f$ នៃ$(E_1)$ គឺ $y = f(x) = 2e^x + e^{2x}$

២. កំណត់ចំនួនពិត a និង b ដើម្បីឲ្យ $g(x) = ax + b$ ជាចម្លើយនៃ $(E)$

$g(x)$ ជាចម្លើយនៃ $(E)$ លុះត្រាតែ $g''(x) - 3g'(x) + 2g(x) = 2x + 1$

$g(x) = ax + b \quad \Rightarrow g'(x) = a$

$\Rightarrow g''(x) = 0$

យើងបាន $0 - 3a + 2(ax + b) = 2x + 1$

$-3a + 2ax + 2b = 2x + 1$

$2ax + (2b - 3a) = 2x + 1$

$$\Rightarrow \begin{cases} 2a = 2 & \Rightarrow a = 1 \\ 2b - 3a = 1 & \Rightarrow 2b - 3 = 1 \Rightarrow b = 2 \end{cases}$$

ដូចនេះ $a = 1, b = 2$

លីម សីហា

IV. ១. រកសមីការស្តង់ដានៃអេលីប E

$(E): \ 9x^2 + 4y^2 + 18x - 24y + 9 = 0$

$$\Leftrightarrow \ 9\left(x^2 + 2x + 1\right) - 9 + 4\left(y^2 - 6y + 9\right) - 4(9) + 9 = 0$$

$$\Leftrightarrow \ 9(x+1)^2 + 4(y-3)^2 = 36$$

$$\Leftrightarrow \ \frac{9(x+1)^2}{36} + \frac{4(y-3)^2}{36} = \frac{36}{36}$$

$$\Leftrightarrow \frac{(x+1)^2}{4} + \frac{(y-3)^2}{9} = 1$$

$$\Leftrightarrow \ \frac{(x+1)^2}{2^2} + \frac{(y-3)^2}{3^2} = 1$$

ដូចនេះ សមីការស្តង់ដានៃ$(E)$ គឺ $\dfrac{(x+1)^2}{2^2} + \dfrac{(y-3)^2}{3^2} = 1$

២. រកប្រវែងអ័ក្សធំ និង អ័ក្សតូច ហើយរកកូអរដោនេនៃ ផ្ចិត កំពូល និង កំណុំនៃអេលីប E

ដោយ សមីការស្តង់ដានៃ(E) គឺ $\frac{(x+1)^2}{2^2}+\frac{(y-3)^2}{3^2}=1$ គេបាន

- អ័ក្សធំជាអ័ក្សឈរ
- $h=-1, k=3; \quad a=3, b=2; \quad c^2=a^2-b^2=9-4=5 \quad \Rightarrow \quad c=\sqrt{5}$

ដូចនេះ យើងបាន

- ប្រវែងអ័ក្សធំគឺ $2a=2(3)=6 \quad \Rightarrow$ [ប្រវែងអក្សធំស្មើ 6 ឯកតាប្រវែង]
- ប្រវែងអ័ក្សតូចគឺ $2b=2(2)=4 \quad \Rightarrow$ [ប្រវែងអ័ក្សតូចស្មើ 4 ឯកតាប្រវែង]
- ផ្ចិត$(h,k) \quad \Rightarrow$ [ផ្ចិត$(-1,3)$]
- កំពូល $V_1(h,k-a);\ V_2(h,k+a) \quad \Rightarrow$ [$V_1(-1,0);\ V_2(-1,6)$]
- កំណុំ $F_1(h,k-c);\ F_2(h,k+c) \quad \Rightarrow$ [$F_1(-1,3-\sqrt{5});\ F_2(-1,3+\sqrt{5})$]

V. 1. ក. $g(x)=2e^{2x}-5e^x+2$ ផ្ទៀងផ្ទាត់ថា $g(x)=(2e^x-1)(e^x-2)$

ដោយ $(2e^x-1)(e^x-2)=2e^x\cdot e^x-4e^x-e^x+2=2e^{2x}-5e^x+2=g(x)$

ដូចនេះ [$g(x)=(2e^x-1)(e^x-2)$]

លឹម សីហា

ខ. ទាញយកតាមតម្លៃនៃ x ចំពោះសញ្ញានៃ g(x)

បើ $g(x)=0 \quad \Leftrightarrow \quad (2e^x-1)(e^x-2)=0$

$$\Rightarrow \left[\begin{array}{lll} 2e^x-1=0 & \Leftrightarrow\ e^x=\frac{1}{2} & \Leftrightarrow\ x=-\ln 2 \\ e^x-2=0 & \Leftrightarrow\ e^x=2 & \Leftrightarrow\ x=\ln 2 \end{array}\right.$$

តារាងសញ្ញា g(x)

| $x$ | $-\infty$ | | $-\ln 2$ | | $\ln 2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $g(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |

[$g(x)>0$ ពេល $x\in(-\infty,-\ln 2)\cup(\ln 2,+\infty)$; $\quad g(x)<0$ ពេល $x\in(-\ln 2,\ln 2)$]

2. ក. រក $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to-\infty} f(x)$

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\left(\frac{1}{1+e^x}+\frac{2}{9}x\right)=0+\frac{2}{9}(+\infty)$$ ដូចនេះ $\boxed{\lim\limits_{x\to+\infty} f(x)=+\infty}$

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\left(\frac{1}{1+e^x}+\frac{2}{9}x\right)=\frac{1}{1+0}+\frac{2}{9}(-\infty)=-\infty$$

ដូចនេះ $\boxed{\lim\limits_{x\to-\infty} f(x)=-\infty}$

ខ. បង្ហាញថាចំពោះគ្រប់ចំនួនពិត $x$ គេបាន $f'(x)$ និង $g(x)$ មានសញ្ញាដូចគ្នា

$$f'(x)=\left(\frac{1}{1+e^x}+\frac{2}{9}x\right)'=-\frac{e^x}{(1+e^x)^2}+\frac{2}{9}=\frac{-9e^x+2(1+e^x)^2}{9(1+e^x)^2}$$
$$=\frac{-9e^x+2+4e^x+2e^{2x}}{9(1+e^x)^2}=\frac{2e^{2x}-5e^x+2}{9(1+e^x)^2}=\frac{g(x)}{9(1+e^x)^2}$$

ដោយ $9(1+e^x)^2>0;\ \forall x\in\mathbb{R}$ គេបាន $f'(x)$មានសញ្ញាតាម $g(x)$

ដូចនេះ $\boxed{f'(x) \text{ និង } g(x) \text{ មានសញ្ញាដូចគ្នា}}$

លឹម សីហា

គ. សិក្សាអថេរភាពនៃអនុគមន៍ $f$ លើ $\mathbb{R}$

ដោយ $f'(x)$ និង $g(x)$ មានសញ្ញាដូចគ្នា គេបាន តារាងសញ្ញា $f'(x)$ គឺ

| $x$ | $-\infty$ | | $-\ln 2$ | | $\ln 2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |

• ត្រង់ $x=-\ln 2;\ f'(x)=0$ ហើយប្តូរសញ្ញាពី $+$ ទៅ $-$ គេបាន $f$ មានអតិបរមាធៀបមួយគឺ

$$f(-\ln 2)=\frac{1}{1+\frac{1}{2}}-\frac{2\ln 2}{9}=\frac{2}{3}-\frac{2\ln 2}{9}=\frac{6-\ln 4}{9}$$

• ត្រង់ $x=\ln 2;\ f'(x)=0$ ហើយប្តូរសញ្ញាពី $-$ ទៅ $+$ គេបាន $f$ មានអប្បបរមាធៀបមួយគឺ

$$f(\ln 2)=\frac{1}{1+2}+\frac{2\ln 2}{9}=\frac{1}{3}+\frac{2\ln 2}{9}=\frac{3+\ln 4}{9}$$

គេបាន តារាងអថេរភាពនៃ f គឺ

| $x$ | $-\infty$ | | $-\ln 2$ | | $\ln 2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $\frac{6-\ln 4}{9}$ | $\searrow$ | $\frac{3+\ln 4}{9}$ | $\nearrow$ | $+\infty$ |

តាមតារាងអថេរភាពគេបាន

- អនុគមន៍ f កើនលើចន្លោះ $x \in (-\infty, -\ln 2) \cup (\ln 2, +\infty)$
- អនុគមន៍ f ចុះលើចន្លោះ $x \in (-\ln 2, \ln 2)$

VI. អនុគមន៍ $f(x) = 4 - x - 2e^{-x}$

១. ក. រក $\lim\limits_{x\to+\infty} f(x)$

$$\lim_{x\to+\infty} f(x) = \lim_{x\to+\infty} (4 - x - 2e^{-x}) = 4 - (+\infty) - 0 = -\infty \quad \boxed{\lim_{x\to+\infty} f(x) = -\infty}$$

លីម សីហា

ខ. បង្ហាញថាបន្ទាត់ D មានសមីការ $y = -x + 4$ ជាអាស៊ីមតូតនៃខ្សែកោង C

យើងមាន $f(x) = 4 - x - 2e^{-x}$

ដោយ $\lim\limits_{x\to+\infty} [f(x) - (-x + 4)] = \lim\limits_{x\to+\infty} -2e^{-x} = 0$

ដូចនេះ $\boxed{\text{បន្ទាត់ } D : \ y = -x + 4 \text{ ជាអាស៊ីមតូតនៃ} C}$

គ. សិក្សាទីតាំងរវាងខ្សែកោង C និងបន្ទាត់ D

យើងមាន $(C): \ y_c = 4 - x - 2e^{-x}; \quad (D): \ y_d = -x + 4$

គេបាន $y_c - y_d = -2e^{-x} < 0 \quad \forall x \in \mathbb{R}$

ដូចនេះ $\boxed{\text{ក្រាប } C \text{ ស្ថិតក្រោមបន្ទាត់} D \text{ គ្រប់តម្លៃ} x \in \mathbb{R}}$

ឃ. ផ្ទៀងផ្ទាត់ថាគ្រប់ចំនួនពិត $x$ ; $f(x) = \dfrac{4e^x - xe^x - 2}{e^x}$

យើងមាន $f(x) = 4 - x - 2e^{-x} = 4 - x - \dfrac{2}{e^x} = \dfrac{4e^x - xe^x - 2}{e^x}$ ពិត

ដូចនេះ $\boxed{f(x) = \dfrac{4e^x - xe^x - 2}{e^x}}$

ឃ. រក $\lim\limits_{x\to-\infty} f(x)$ (ប្រើលទ្ធផល $\lim\limits_{x\to-\infty} xe^x = 0$ )

$$\lim_{x\to-\infty} f(x) = \lim_{x\to-\infty}\left(\frac{4e^x - xe^x - 2}{e^x}\right) = \lim_{x\to-\infty}\left(\frac{4e^x}{e^x} - \frac{2}{e^x}\right) = \lim_{x\to-\infty}\left(4 - \frac{2}{e^x}\right) = -\infty$$

ដូចនេះ $\boxed{\lim\limits_{x\to-\infty} f(x) = -\infty}$

២. ក. គណនា $f'(x)$

$f'(x) = (4 - x - 2e^{-x})' = -1 + 2e^{-x}$ $\boxed{f'(x) = 2e^{-x} - 1}$

សិក្សាអថេរភាពនៃ f

- $f'(x) = 0 \quad \Leftrightarrow \; 2e^{-x} - 1 = 0 \Leftrightarrow \; e^{-x} = \frac{1}{2} \Rightarrow \; -x = \ln\frac{1}{2} \Rightarrow x = -\ln\frac{1}{2} = \ln 2$
- $f'(x) > 0 \quad \Leftrightarrow \; 2e^{-x} - 1 > 0 \Leftrightarrow \; e^{-x} > \frac{1}{2} \Rightarrow \; -x > \ln\frac{1}{2} \Rightarrow x < \ln 2$
- $f'(x) < 0 \quad \Leftrightarrow \; 2e^{-x} - 1 = 0 \Leftrightarrow \; e^{-x} < \frac{1}{2} \Rightarrow \; -x < \ln\frac{1}{2} \Rightarrow x > \ln 2$

យើងបានតារាងអថេរភាពនៃ f(x) គឺ

លឹម សីហា

ចំពោះ $x = \ln 2$ គេបាន $f(\ln 2) = 4 - \ln 2 - 2e^{-\ln 2} = 4 - \ln 2 - 2(2^{-1}) = 3 - \ln 2$

| $x$ | $-\infty$ | | $\ln 2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | ↗ | $3 - \ln 2$ | ↘ | $-\infty$ |

- f កើនលើចន្លោះ $x \in (0, \ln 2)$
- f ចុះលើចន្លោះ $x \in (\ln 2, +\infty)$

កំណត់តម្លៃពិតនៃអតិបរមារបស់ f

តាមតារាងអថេរភាព

f មានតម្លៃអតិបរមាត្រង់ចំណុច $x = \ln 2$ ហើយតម្លៃអតិបរមានៃf គឺ $3 - \ln 2$

ខ. កំណត់សមីការបន្ទាត់ប៉ះខ្សែកោង C ត្រង់ A

រូបមន្ត សមីការបន្ទាត់ប៉ះគឺ $y = f'(x_o)(x - x_o) + f(x_o)$

ដោយ A មានអាប់ស៊ីសសូន្យ គេបាន $x_o = 0$

គេបាន $f(x_o) = f(0) = 4 - 0 - 2 = 2$ ; $f'(x_o) = f'(0) = 2 - 1 = 1$

នាំឲ្យ $y = 1(x - 0) + 2$

ដូចនេះ | សមីការបន្ទាត់ប៉ះគឺ $y = x + 2$ |

គ. បង្ហាញថាសមីការ $f(x) = 0$ មានចម្លើយតែមួយគត់ដែលគេតាងដោយ $\beta$ នៅក្នុងចន្លោះ $[-1, 0]$

យើងមាន

- $f(-1) = 4 - (-1) - 2e^{-(-1)} = 5 - 2e < 0$
- $f(0) = 2 > 0$
- គេបាន $f(-1) \times f(0) = 2(5 - 2e) < 0$

តាមទ្រឹស្តីបទតម្លៃកណ្តាល មានឫស $\beta$ មួយយ៉ាងតិចនៅចន្លោះ $[-1, 0]$ ដែល $f(\beta) = 0$

តែ f កើន លើចន្លោះ $[-1, 0]$

ដូចនេះ | មានឫស $\beta$ តែមួយគត់ដែលនៅចន្លោះ $[-1, 0]$ ធ្វើឲ្យ $f(x) = 0$ |

លឹម សីហា

# វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡង
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨

## [វិញ្ញាសាទី៦]

I. (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to 2}\dfrac{x^3-8}{\sqrt{x+2}-2}$  ខ. $\lim\limits_{x\to 0}\dfrac{\cos x-1}{\sin^2 x}$  គ. $\lim\limits_{x\to 0}\dfrac{3\sin 3x}{x}$

II. (១០ពិន្ទុ) គេឲ្យចំនួនកុំផ្លិច $A=\left(\sqrt{3}-1\right)+i\left(\sqrt{3}+1\right)$ និង $B=\dfrac{x+iy}{1+i}$ ដែល $x, y$ ជាចំនួនពិត។

១. សរសេរ $A^2$ ជាទម្រង់ពិជគណិត ហើយជាទម្រង់ត្រីកោណមាត្រ។

២. សរសេរ B ជាទម្រង់ពីជគណិត។ រក x និង y ដោយដឹងថា $2\overline{B}-A^2=0$

( $\overline{B}$ ជាចំនួនកុំផ្លិចឆ្លាស់នៃ B )។

III. (២០ពិន្ទុ) គេឲ្យសមីការឌីផេរ៉ង់ស្យែល $(E_1):\ -y''-y'+6y=6x^2-2x+4$ ។

១. ដោះស្រាយសមីការ $(E_2):\ -y''-y'+6y=0$ ។

២. រកពហុធា $p(x)=ax^2+bx+c$ ដែលជាចម្លើយមួយនៃសមីការ $(E_1)$។

ទាញរកចម្លើយទូទៅនៃ $(E_1)$ ។

IV. (១៥ពិន្ទុ) គេឲ្យអនុគមន៍ $y=g(x)=\dfrac{2x-3}{(x-3)^2}$ ។

១. រកចំនួនពិត a និង b ដើម្បីឲ្យ $g(x)=\dfrac{a}{x-3}+\dfrac{b}{(x-3)^2}$ ។

២. គណនា $F(x)=\displaystyle\int g(x)dx$ ដោយដឹងថា $F(4)=0$ ។

V. (៣០ពិន្ទុ)

១. នៅក្នុងតម្រុយអរតូណរម៉ាល់ $\left(O,\ \vec{i},\ \vec{j},\ \vec{k}\right)$ ដែលមានទិសដៅវិជ្ជមាន (ឯកតាលើអ័ក្សស្មើនឹង1cm)

ចូរដៅចំណុច $A(2,\ 0,\ 2);\ B(1,\ 2,\ 0)$ និង $C(0,\ 2,\ 3)$ ។

២. សរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ D ដែលកាត់តាម A ហើយស្របនឹង $\overrightarrow{BC}$ ។

៣. គណនា $\left|\overrightarrow{AB}\right|$ និង $\left|\overrightarrow{AC}\right|$ ។ ប្រាប់ប្រភេទនៃត្រីកោណ ABC ។

៤. គណនា $\overrightarrow{AB}\times\overrightarrow{AC}$។ ទាញថាចំណុច $A, B, C$ មិនឋិតនៅលើបន្ទាត់តែមួយ។ រកសមីការប្លង់ABC។

គណនាផ្ទៃក្រឡានៃត្រីកោណ ABC ។

លឹម សីហា

៥. រកមាឌតេត្រាអ៊ែត OABC ។ ទាញរកចម្ងាយពី O ទៅប្លង់ ABC ។

VI. (៣៥ពិន្ទុ) f ជាអនុគមន៍កំណត់ចំពោះ $x > 0$ ដោយ $f(x) = 2\left(1 - \frac{\ln x}{x}\right)$ ហើយមានក្រាប C ។

១. គណនា $\lim_{x \to 0^+} f(x)$ និង $\lim_{x \to +\infty} f(x)$ ។
កំណត់សមីការអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប C ។

២. គណនាដេរីវេ $f'(x)$ និងសិក្សាសញ្ញា $f'(x)$ ។ កំណត់តម្លៃបរមានៃ f ។ សង់តារាងអថេរភាពនៃ f ។

៣. កំណត់កូអរដោនេនៃចំណុចប្រសព្វ M រវាងក្រាប C និងអាស៊ីមតូតដេករបស់វា ។
កំណត់សមីការបន្ទាត់ L ដែលប៉ះនឹងក្រាប C ត្រង់ចំណុច M ។

៤. សង់បន្ទាត់ L និងក្រាប C នៅក្នុងតម្រុយតែមួយ (គេយក $e = 2.7,\ \frac{2}{e} = 0.7$ )។

៥. កំណត់តម្លៃនៃចំនួនពិត k ដោយប្រើក្រាប C ដើម្បីឲ្យសមីការ $2\left(1 - \frac{\ln x}{x}\right) = k$ មានឬស។
គណនាផ្ទៃក្រឡាផ្ទៃកប្លង់ដែលកំណត់ដោយក្រាប C អ័ក្ស $x'Ox$ បន្ទាត់ឈរ $x = 1$ និង $x = e$ ។

លឹម សីហា

I. គណនាលីមីត៖

ក. $\lim\limits_{x\to 2}\dfrac{x^3-8}{\sqrt{x+2}-2}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to 2}\frac{\left(x^3-8\right)\left(\sqrt{x+2}+2\right)}{\left(\sqrt{x+2}-2\right)\left(\sqrt{x+2}+2\right)}=\lim_{x\to 2}\frac{(x-2)\left(x^2+2x+4\right)\left(\sqrt{x+2}+2\right)}{x+2-4}$$

$$=\lim_{x\to 2}\left(x^2+2x+4\right)\left(\sqrt{x+2}+2\right)=12\times 4=48$$

ដូចនេះ $\boxed{\lim\limits_{x\to 2}\dfrac{x^3-8}{\sqrt{x+2}-2}=48}$

ខ. $\lim\limits_{x\to 0}\dfrac{\cos x-1}{\sin^2 x}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to 0}\frac{1-2\sin^2\frac{x}{2}-1}{\sin^2 x}=\lim_{x\to 0}\frac{-2\cdot\left(\frac{x}{2}\right)^2\cdot\left(\dfrac{\sin^2\frac{x}{2}}{\left(\frac{x}{2}\right)^2}\right)}{x^2\cdot\dfrac{\sin^2 x}{x^2}}=\frac{-2\times\frac{1}{4}\times 1}{1}=-\frac{1}{2}$$

លីម សីហា

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{\cos x-1}{\sin^2 x}=-\dfrac{1}{2}}$

គ. $\lim\limits_{x\to 0}\dfrac{3\sin 3x}{x}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to 0}9\cdot\frac{\sin 3x}{3x}=9\times 1=9$$ ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{3\sin 3x}{x}=9}$

II. ១. សរសេរ $A^2$ ជាទម្រង់ពិជគណិត

យើងមាន $A=\left(\sqrt{3}-1\right)+i\left(\sqrt{3}+1\right)$ យើងបាន

$$A^2=\left(\left(\sqrt{3}-1\right)+i\left(\sqrt{3}+1\right)\right)^2$$

$$=\left(\sqrt{3}-1\right)^2+2\left(\sqrt{3}-1\right)\left(\sqrt{3}+1\right)i+i^2\left(\sqrt{3}+1\right)^2$$

$$=3-2\sqrt{3}+1+2(3)i-2(1)i-\left(3+2\sqrt{3}+1\right)$$

$$=-4\sqrt{3}+4i$$

ដូចនេះ $\boxed{\text{ទម្រង់ពិជគណិតនៃ}A^2 \text{ គឺ } A^2=-4\sqrt{3}+4i}$

សរសេរ $A^2$ ជាទម្រង់ត្រីកោណមាត្រ

$$A^2=-4\sqrt{3}+4i=8\left(-\frac{\sqrt{3}}{2}+\frac{1}{2}i\right)=8\left(\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}\right)$$

ដូចនេះ $\boxed{\text{ទម្រង់ត្រីកោណមាត្រនៃ } A^2 \text{ គឺ } A^2=8\left(\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}\right)}$

២. សរសេរ B ជាទម្រង់ពីជគណិត

យើងមាន $B=\dfrac{x+iy}{1+i}$ យើងបាន

$$B=\frac{x+iy}{1+i}=\frac{(x+iy)(1-i)}{(1+i)(1-i)}=\frac{x-xi+iy-i^2y}{1^2-i^2}=\frac{x+y+(y-x)i}{1+1}$$

$$=\frac{x+y}{2}+\frac{y-x}{2}i$$

ដូចនេះ $\boxed{\text{ទម្រង់ពីជគណិតនៃ}B \text{ គឺ } B=\frac{x+y}{2}+\frac{y-x}{2}i}$

រក x និង y ដោយដឹងថា $2\overline{B}-A^2=0$ ( $\overline{B}$ ជាចំនួនកុំផ្លិចឆ្លាស់នៃ B )

$$B=\frac{x+y}{2}+\frac{y-x}{2}i \quad\Rightarrow\quad \overline{B}=\frac{x+y}{2}-\frac{y-x}{2}i$$ យើងបាន

$$2\overline{B}-A^2=0 \quad\Leftrightarrow\quad 2\left(\frac{x+y}{2}-\frac{y-x}{2}i\right)-\left(-4\sqrt{3}+4i\right)=0$$

$$x+y-yi+xi+4\sqrt{3}=0$$

$$(x+y)+(-y+x)i=-4\sqrt{3}+4i$$

$$\Longrightarrow \begin{cases} x+y=-4\sqrt{3} & (1) \\ -y+x=4 & \Rightarrow x=y+4\text{ជំនួសក្នុង}(1) \end{cases}$$

យើងបាន $y+4+y=-4\sqrt{3} \quad\Rightarrow y=-2\sqrt{3}-2 \Rightarrow x=-2\sqrt{3}+2$

ដូចនេះ $\boxed{x=-2\sqrt{3}+2,\ y=-2\sqrt{3}-2}$

III. សមីការឌីផេរ៉ង់ស្យែល $(E_1): \; -y'' - y' + 6y = 6x^2 - 2x + 4$

១. ដោះស្រាយសមីការ $(E_2): \; -y'' - y' + 6y = 0$

$(E_2)$ មានសមីការសម្គាល់ $-r^2 - r + 6 = 0$ មានឫស $r_1 = -3, \;\; r_2 = 2$

ដូចនេះ | ចម្លើយនៃ $(E_2)$ គឺ $y = Ae^{-3x} + Be^{2x} \quad ; \; A, B \in \mathbb{R}$ |

២. រកពហុធា $p(x) = ax^2 + bx + c$ ដែលជាចម្លើយមួយនៃសមីការ $(E_1)$

$p(x) = ax^2 + bx + c$ ដែលជាចម្លើយមួយនៃសមីការ $(E_1)$ លុះត្រាតែ

$-p''(x) - p'(x) + 6p(x) = 6x^2 - 2x + 4$

ដោយ $p(x) = ax^2 + bx + c \quad \Rightarrow p'(x) = 2ax + b$

$$\Rightarrow P''(x) = 2a$$

គេបាន $\quad -(2a) - (2ax + b) + 6\left(ax^2 + bx + c\right) = 6x^2 - 2x + 4$

$$\Leftrightarrow \quad -2a - 2ax - b + 6ax^2 + 6bx + 6c = 6x^2 - 2x + 4$$

$$\Leftrightarrow \quad 6ax^2 + (-2a + 6b)x + (-2a - b + 6c) = 6x^2 - 2x + 4$$

ដោយផ្ទឹមមេគុណយើងបាន $\begin{cases} 6a = 6 & (1) \\ -2a + 6b = -2 & (2) \\ -2a - b + 6c = 4 & (3) \end{cases}$

$(1): \; 6a = 6 \quad \Rightarrow a = 1$ ជំនួសក្នុង $(2)$ គេបាន $-2(1) + 6b = -2 \quad \Rightarrow b = 0$

យក $a = 1, b = 0$ ជួសក្នុង $(3)$ គេបាន $-2(1) - 0 + 6c = 4 \quad \Rightarrow c = 1$

ដូចនេះ | $p(x) = x^2 + 1$ |

ទាញរកចម្លើយទូទៅនៃ $(E_1)$

ចម្លើយទូទៅនៃ $(E_1)$ គឺ $y = y_c + y_p = Ae^{-3x} + Be^{2x} + x^2 + 1 \quad ; \; A, B \in \mathbb{R}$

ដូចនេះ | ចម្លើយទូទៅនៃ $(E_1)$ គឺ $y = Ae^{-3x} + Be^{2x} + x^2 + 1 \quad ; \; A, B \in \mathbb{R}$ |

IV. ១. រកចំនួនពិត a និង b

យើងមាន $y = g(x) = \dfrac{2x - 3}{(x - 3)^2}$ គេបាន $g(x) = \dfrac{a}{x - 3} + \dfrac{b}{(x - 3)^2}$ លុះត្រាតែ

$$\frac{2x - 3}{(x - 3)^2} = \frac{a}{x - 3} + \frac{b}{(x - 3)^2} \quad \Leftrightarrow \quad \frac{2x - 3}{(x - 3)^2} = \frac{a(x - 3) + b}{(x - 3)^2}$$

លឹម សីហា

$$\Leftrightarrow \quad \frac{2x-3}{(x-3)^2} = \frac{ax-3a+b}{(x-3)^2}$$

ផ្ទឹមមេគុណយើងបាន $a = 2$ ; $\quad -3a+b = -3 \Rightarrow -3(2)+b = -3 \quad \Rightarrow \; b = 3$

ដូចនេះ $\boxed{a = 2 \;;\; b = 3}$

២. គណនា $F(x) = \int g(x)dx$ ដោយដឹងថា $F(4) = 0$

ដោយ $g(x) = \dfrac{a}{x-3} + \dfrac{b}{(x-3)^2} = \dfrac{2}{x-3} + \dfrac{3}{(x-3)^2}$ គេបាន

$$F(x) = \int g(x)dx = \int \left(\frac{2}{x-3} + \frac{3}{(x-3)^2}\right)dx$$

$$= \int \left(\frac{2(x-3)'}{x-3} + \frac{3(x-3)'}{(x-3)^2}\right)dx$$

$$= 2\ln|x-3| + \frac{-3}{x-3} + C \quad ; \quad C \in \mathbb{R}$$

ដោយ $F(4) = 0$ គេបាន $2\ln|4-3| - \dfrac{3}{4-3} + C = 0 \quad \Rightarrow \; C = 3$

ដូចនេះ $\boxed{F(x) = 2\ln|x-3| - \dfrac{3}{x-3} + 3}$

V. ១. ដៅចំណុច $A(2,\ 0,\ 2)$; $B(1,\ 2,\ 0)$ និង $C(0,\ 2,\ 3)$



២. សរសេរសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ D

សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ D គឺ $\begin{cases} x = x_o + at \\ y = x_o + bt \\ z = z_o + ct \end{cases} \quad ; t \in \mathbb{R}$

- (D) កាត់តាម $A(2, 0, 2)$
- $(D) // \overrightarrow{BC}(-1, 0, 3)$

ដូចនេះ **សមីការប៉ារ៉ាម៉ែតនៃបន្ទាត់D គឺ $\begin{cases} x = 2 - t \\ y = 0 \\ z = 2 + 3t \end{cases} \quad ; t \in \mathbb{R}$**

៣. គណនា $\left|\overrightarrow{AB}\right|$ និង $\left|\overrightarrow{AC}\right|$

$A(2,\ 0,\ 2);\ B(1,\ 2,\ 0)\ ;\ C(0,\ 2,\ 3)$

- $\overrightarrow{AB}(-1, 2, -2) \quad \Rightarrow \left|\overrightarrow{AB}\right| = \sqrt{(-1)^2 + 2^2 + (-2)^2} = 3 \quad \boxed{\left|\overrightarrow{AB}\right| = 3cm}$
- $\overrightarrow{AC}(-2, 2, 1) \quad \Rightarrow \left|\overrightarrow{AC}\right| = \sqrt{(-2)^2 + 2^2 + (1)^2} = 3 \quad \boxed{\left|\overrightarrow{AC}\right| = 3cm}$

ប្រាប់ប្រភេទនៃត្រីកោណ ABC

ដោយ $\left|\overrightarrow{AB}\right| = \left|\overrightarrow{AC}\right| = 3cm$

ដូចនេះ **$\Delta ABC$ ជាត្រីកោណសមបាត**

៤. គណនា $\overrightarrow{AB} \times \overrightarrow{AC}$

$$\overrightarrow{AB} \times \overrightarrow{AC} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -1 & 2 & -2 \\ -2 & 2 & 1 \end{vmatrix} = (2+4)\,\vec{i} - (-1-4)\,\vec{j} + (-2+4)\,\vec{k}$$

$$= 6\,\vec{i} + 5\,\vec{j} + 2\,\vec{k}$$

ដូចនេះ $\boxed{\overrightarrow{AB} \times \overrightarrow{AC} = 6\,\vec{i} + 5\,\vec{j} + 2\,\vec{k}}$

ទាញថាចំណុច A, B, C មិនឋិតនៅលើបន្ទាត់តែមួយ

ដោយ $\overrightarrow{AB} \times \overrightarrow{AC} \neq 0 \quad \Rightarrow \overrightarrow{AB}$ និង $\overrightarrow{AC}$ មិនកូលីនេអ៊ែរគ្នា

ដូចនេះ | ចំណុច A, B, C មិនស្ថិតក្នុងប្លង់តែមួយ |

រកសមីការប្លង់ABC

ប្លង់ (ABC) : $a(x - x_o) + b(y - y_o) + c(z - z_o) = 0$

- ប្លង់ (ABC) កាត់តាម A(2, 0, 2)
- $\overrightarrow{AB} \times \overrightarrow{AC} = 6\vec{i} + 5\vec{j} + 2\vec{k}$ ជាវ៉ិចទ័រណរម៉ាល់នៃ ប្លង់(ABC)

$\Rightarrow$ (ABC) : $6(x-2) + 5(y-0) + 2(z-2) = 0$

$$6x + 5y + 2z - 16 = 0$$

ដូចនេះ | (ABC) : $6x + 5y + 2z - 16 = 0$ |

គណនាផ្ទៃក្រឡានៃត្រីកោណ ABC

$$S_{\Delta ABC} = \frac{1}{2}\left|\overrightarrow{AB} \times \overrightarrow{AC}\right| = \frac{1}{2}\sqrt{6^2 + 5^2 + 2^2} = \frac{1}{2}\sqrt{65}$$

ដូចនេះ | $S_{\Delta ABC} = \frac{\sqrt{65}}{2} cm^2$ |

លឹម សីហា

៥. រកមាឌតេត្រាអ៊ែត OABC

$$V_{OABC} = \frac{1}{6}\left|\left(\overrightarrow{OA} \times \overrightarrow{OB}\right) \cdot \overrightarrow{OC}\right|$$

O(0, 0, 0) ; A(2, 0, 2); B(1, 2, 0) ; C(0, 2, 3)

- $\overrightarrow{OA}(2, 0, 2)$
- $\overrightarrow{OB}(1, 2, 0)$
- $\overrightarrow{OC}(0, 2, 3)$

$$\overrightarrow{OA} \times \overrightarrow{OB} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 2 & 0 & 2 \\ 1 & 2 & 0 \end{vmatrix} = (0-4)\vec{i} - (0-2)\vec{j} + (4-0)\vec{k}$$

$$= -4\vec{i} + 2\vec{j} + 4\vec{k}$$

$$\left(\overrightarrow{OA} \times \overrightarrow{OB}\right) \cdot \overrightarrow{OC} = -4(0) + 2(2) + 4(3) = 16$$

$V_{OABC} = \frac{1}{6} \cdot 16 = \frac{8}{3}$ ដូចនេះ $\boxed{V_{OABC} = \frac{8}{3}\text{cm}^3}$

ទាញរកចម្ងាយពី O ទៅប្លង់ ABC

$$V_{OABC} = \frac{1}{3} S_{\Delta ABC} \cdot h \quad \Rightarrow h = \frac{3V_{OABC}}{S_{\Delta ABC}} = \frac{3 \cdot \frac{8}{3}}{\frac{\sqrt{65}}{2}} = \frac{16}{\sqrt{65}} = \frac{16\sqrt{65}}{65}$$

ដូចនេះ $\boxed{d(O, (ABC)) = h = \frac{16\sqrt{65}}{65}\text{cm}}$

VI. ១. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$

យើងមាន $f(x) = 2\left(1 - \frac{\ln x}{x}\right)$

- $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+} 2\left(1 - \frac{\ln x}{x}\right) = 2(1 - (-\infty)) = +\infty$ $\boxed{\lim\limits_{x\to 0^+} f(x) = +\infty}$
- $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty} 2\left(1 - \frac{\ln x}{x}\right) = 2(1 - (0)) = 2$ $\boxed{\lim\limits_{x\to +\infty} f(x) = 2}$

កំណត់សមីការអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប C

- ដោយ $\lim\limits_{x\to 0^+} f(x) = +\infty$ ដូចនេះ បន្ទាត់ $x = 0$ ជាអាស៊ីមតូតឈរ
- ដោយ $\lim\limits_{x\to +\infty} f(x) = +\infty$ ដូចនេះ បន្ទាត់ $y = 2$ ជាអាស៊ីមតូតដេក

២. គណនាដេរីវេ $f'(x)$

$$f'(x) = \left(2\left(1 - \frac{\ln x}{x}\right)\right)' = \left(2 - 2\frac{\ln x}{x}\right)' = 0 - 2\left(\frac{(\ln x)' x - x' \ln x}{x^2}\right)$$

$$= -2\left(\frac{\frac{1}{x} \cdot x - \ln x}{x^2}\right) = \frac{-2 + 2\ln x}{x^2}$$

ដូចនេះ $\boxed{f'(x) = \frac{-2 + 2\ln x}{x^2}}$

សិក្សាសញ្ញា $f'(x)$

ដោយ $x^2 > 0 \quad \forall x \in (0, +\infty) \quad \Rightarrow f'(x)$ មានសញ្ញាដូចភាគយក $-2 + 2\ln x$

- $f'(x) = 0 \quad \Leftrightarrow -2 + 2\ln x = 0 \quad \Rightarrow \ln x = 1 \quad \Rightarrow x = e$
- $f'(x) > 0 \quad \Leftrightarrow -2 + 2\ln x > 0 \quad \Rightarrow \ln x > 1 \quad \Rightarrow x > e$
- $f'(x) < 0 \quad \Leftrightarrow -2 + 2\ln x < 0 \quad \Rightarrow \ln x < 1 \quad \Rightarrow x < e$

យើងបាន តារាងសញ្ញា $f'(x)$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |

កំណត់តម្លៃបរមានៃ $f$

- ត្រង់ $x = e$; $f'(x) = 0$ ហើយប្តូរសញ្ញាពី $-$ ទៅ $+$ យើងបាន $f$ មានអប្បបរមាធៀបមួយ គឺ $f(e) = 2\left(1 - \frac{\ln e}{e}\right) = 2 - \frac{2}{e} = 2 - 0.7 = 1.3$

ដូចនេះ តម្លៃអប្បបរមាគឺ $f(e) = 1.3$

លឹម សីហា

សង់តារាងអថេរភាពនៃ $f$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | ‖ $+\infty$ | ↘ | $1.3$ | ↗ | $2$ |

៣. កំណត់កូអរដោនេនៃចំណុចប្រសព្វ M រវាងក្រាប C និងអាស៊ីមតូតដេករបស់វា

- $(C): \ y = 2\left(1 - \frac{\ln x}{x}\right)$
- $(T): \ y = 2$

$$(C)\cap(T) \quad \Leftrightarrow \quad 2\left(1-\frac{\ln x}{x}\right)=2$$
$$\Leftrightarrow \quad -2\ln x = 0$$
$$\Rightarrow \quad \ln x = 0 \quad \Rightarrow \quad x = 1$$

ដូចនេះ ចំណុចប្រសព្វ M គឺ $M(1,2)$

កំណត់សមីការបន្ទាត់ L ដែលប៉ះនឹងក្រាប C ត្រង់ចំណុច M

សមីការបន្ទាត់ L កំណត់ដោយ $(L):\ y = f'(x_o)(x-x_o)+f(x_o)$

- L ដែលប៉ះនឹងក្រាប C ត្រង់ចំណុច $M(1,2)$ $\Rightarrow x_o = 1,\ \ f(x_o)=2$
- $f'(x_o) = f'(1) = \dfrac{-2+2\ln 1}{1^2} = -2$

$\Rightarrow \quad (L):\ y = -2(x-1)+2 = -2x+4$

ដូចនេះ សមីការបន្ទាត់ប៉ះ គឺ $(L):\ y=-2x+4$

លីម សីហា

៤. សង់បន្ទាត់ L និងក្រាប C



៥. កំណត់តម្លៃនៃចំនួនពិត $k$

សមីការ $2\left(1-\frac{\ln x}{x}\right)=k$ ជាសមីការអាប់ស៊ីសនៃចំណុចប្រសព្វរវាងក្រាប $(C)$

និងបន្ទាត់ $(D): y=k$

តាមក្រាប សមីការ $2\left(1-\frac{\ln x}{x}\right)=k$ មានឫស លុះត្រាតែ $k\geq 1.3$

ដូចនេះ $\boxed{k\geq 1.3}$

គណនាផ្ទៃក្រឡាផ្ទៃកប្លង់ដែលកំណត់ដោយក្រាប $C$ អ័ក្ស $x'Ox$ បន្ទាត់ឈរ $x=1$ និង $x=e$

$$S=\int_1^e f(x)dx=\int_1^e 2\left(1-\frac{\ln x}{x}\right)dx=\int_1^e\left(2-2(\ln x)'\ln x\right)dx=\left[2x-\frac{2\ln^2 x}{2}\right]_1^e$$

$$=2e-\ln^2 e-\left(2-\ln^2 1\right)=2e-3$$

ដូចនេះ $\boxed{S=2e-3 \text{ ឯកតាផ្ទៃ}}$

លឹម សីហា

# វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡង
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨

## [វិញ្ញាសាទី៧]

I. (១០ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to-\infty}\dfrac{\left(2x^2-3\right)(1-x)}{(5+2x)\left(2-x^2\right)}$ ខ. $\lim\limits_{x\to1}\dfrac{2-\sqrt{x+3}}{x^2-1}$ គ. $\lim\limits_{x\to+\infty}\ln\dfrac{x+1}{x-1}$

II. (១៥ពិន្ទុ) ក្នុងប្រអប់មួយមានឃ្លីពណ៌ស $2$ គ្រាប់ដែលមានចុះលេខ $1, 2$ និងឃ្លីពណ៌ខ្មៅ $3$ គ្រាប់ ដែលមានចុះលេខ $1, 2, 3$ គេចាប់យកឃ្លី $2$ គ្រាប់ ព្រមគ្នាដោយចៃដន្យពីក្នុងប្រអប់នោះ។ រកប្រូបាបនៃព្រឹត្តិការណ៍

១. $A$ : «គេចាប់បានឃ្លីពណ៌ដូចគ្នា»។

២. $B$ : «គេចាប់បានឃ្លីមានផលបូកលេខស្មើ $3$ »។

៣. $C$ : «គេចាប់បានឃ្លីមានផលបូកលេខស្មើ $3$ ដោយបានដឹងថា វាមានពណ៌ដូចគ្នា»។

III. (១៥ពិន្ទុ) គេមានចំនួនកុំផ្លិច $z_1=\sqrt{3}-i$ ; $z_2=\left(1-\sqrt{3}\right)+\left(1-\sqrt{3}\right)i$ និង $z_3=-\dfrac{1}{2}$ ។

គណនា $z_1+z_2$ , $(z_1+z_2)\times z_3$ ។ សរសេរជាទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $Z=(z_1+z_2)\times z_3$ ។ ទាញរកតម្លៃនៃ $Z^3$ ។

IV. (១៥ពិន្ទុ) គេឲ្យ $g(x)=\dfrac{x^2+x-6}{x^2-2x-3}$ ។

១. កំណត់ចំនួនពិត $m, n$ និង $p$ ដើម្បីឲ្យបាន $g(x)=m+\dfrac{n}{x+1}+\dfrac{p}{x-3}$ ចំពោះគ្រប់ $x\in(-1,3)$។

២. គណនា $I=\displaystyle\int_0^2 g(x)dx$ ។

V. (៣៥ពិន្ទុ) នៅក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $\left(O,\vec{i},\vec{j},\vec{k}\right)$ មានចំណុច $A(-1,2,1)$; $B(1,-6,-1)$ និង $C(2,2,2)$ ។

១. គណនា $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$។ កំណត់សមីការប្លង់ $P$ ដែលកាត់តាមចំណុច $A, B$ និង $C$ ហើយមានវ៉ិចទ័រណរម៉ាល់ $\vec{n}$។ កំណត់សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $d$ កាត់តាមចំណុច $J(-2,0,0)$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{u}=(3,0,1)$ ។

២. រកកូអរដោនេនៃផ្ចិត $I$ និងកាំ $r$ នៃស្វ៊ែ $S$ ដែលមានសមីការ $x^2+y^2+z^2-2y+2z-2=0$។ រកកូអរដោនេនៃចំណុចប្រសព្វរវាងស្វ៊ែ $S$ និងបន្ទាត់ $d$។

៣. គណនាផ្ទៃក្រឡានៃត្រីកោណ ABC។ គណនាចម្ងាយពីចំណុច $D(0,1,-1)$ ទៅប្លង់ P។

VI. (៣៥ពិន្ទុ)

A គេមានអនុគមន៍ g កំណត់លើ $(0,+\infty)$ ដោយ $g(x) = x^2 + \ln x$ ។

១. ក. បង្ហាញថា g ជាអនុគមន៍កើនដាច់ខាតលើ $(0,+\infty)$ ។

ខ. គណនា $g(1)$ ។

២. ក. ទាញលទ្ធផលពីសំណួរទី១ បញ្ជាក់ថា ៖ បើ $x \geq 1$ នោះ $x^2 + \ln x \geq 1$ និងបើ $0 < x \leq 1$ នោះ $x^2 + \ln x \leq 1$ ។

ខ. កំណត់សញ្ញានៃកន្សោម $x^2 + \ln x - 1$ កាលណា x នៅលើចន្លោះ $(0,+\infty)$ ។

B គេមានអនុគមន៍ f កំណត់លើ $(0,+\infty)$ ដោយ $f(x) = x + 1 - \dfrac{\ln x}{x}$ និងតាងដោយ C ក្រាបរបស់វាក្នុងតម្រុយអរតូណរមេ $\left(O,\vec{i},\vec{j}\right)$ ។

១. សិក្សាលីមីតនៃអនុគមន៍ f ត្រង់ 0 និង $+\infty$ (យើងដឹងថា $\lim\limits_{x\to+\infty} \dfrac{\ln x}{x} = 0$ )។

២. បង្ហាញថាដេរីវេនៃអនុគមន៍ f គឺ $f'(x) = \dfrac{x^2 + \ln x - 1}{x^2}$ ។

៣. ប្រើលទ្ធផលនៃសំណួរ A សិក្សាសញ្ញានៃ $f'(x)$ និងសង់តារាងអថេរភាពនៃអនុគមន៍ f លើ$(0,+\infty)$។

៤. ក. បង្ហាញថាបន្ទាត់ $\Delta$ មានសមីការ $y = x + 1$ ជាអាសុីមតូតទៅនឹងក្រាប C ត្រង់ $+\infty$ ។

ខ. សិក្សាទីតាំង C ធៀបនឹង $\Delta$ និងបញ្ជាក់កូអរដោនេនៃចំណុចប្រសព្វ I រវាងក្រាប C និង $\Delta$ ។ សង់ $\Delta$ និងក្រាប C ។

## [ដំណោះស្រាយ]

I. គណនាលីមីត៖

ក. $\lim\limits_{x\to-\infty}\dfrac{\left(2x^2-3\right)(1-x)}{(5+2x)\left(2-x^2\right)}$ (មានរាងមិនកំណត់ $\frac{\infty}{\infty}$)

$$=\lim_{x\to-\infty}\frac{x^2\cdot x\left(2-\frac{3}{x^2}\right)\left(\frac{1}{x}-1\right)}{x\cdot x^2\left(\frac{5}{x}+2\right)\left(\frac{2}{x^2}-1\right)}=\frac{(2-0)(0-1)}{(0+2)(0-1)}=\frac{-2}{-2}=1$$

ដូចនេះ $\boxed{\lim\limits_{x\to-\infty}\dfrac{\left(2x^2-3\right)(1-x)}{(5+2x)\left(2-x^2\right)}=1}$

ខ. $\lim\limits_{x\to1}\dfrac{2-\sqrt{x+3}}{x^2-1}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to1}\frac{\left(2-\sqrt{x+3}\right)\left(2+\sqrt{x+3}\right)}{\left(x^2-1\right)\left(2+\sqrt{x+3}\right)}=\lim_{x\to1}\frac{4-(x+3)}{\left(x^2-1\right)\left(2+\sqrt{x+3}\right)}$$

$$=\lim_{x\to1}\frac{-(x-1)}{(x-1)(x+1)\left(2+\sqrt{x+3}\right)}=\frac{-1}{(1+1)\left(2+\sqrt{1+3}\right)}=\frac{-1}{2(4)}=-\frac{1}{8}$$

ដូចនេះ $\boxed{\lim\limits_{x\to1}\dfrac{2-\sqrt{x+3}}{x^2-1}=-\dfrac{1}{8}}$

គ. $\lim\limits_{x\to+\infty}\ln\dfrac{x+1}{x-1}=\lim\limits_{x\to+\infty}\ln\left(1+\dfrac{2}{x-1}\right)=\ln(1+0)=\ln 1=0$

ដូចនេះ $\boxed{\lim\limits_{x\to+\infty}\ln\dfrac{x+1}{x-1}=0}$

II. ១. រកប្រូបាបនៃព្រឹត្តិការណ៍ A : «គេចាប់បានឃ្លីពណ៌ដូចគ្នា»

តាមរូបមន្ត $p(A)=\dfrac{n(A)}{n(S)}$

ដោយ គេចាប់បានពណ៌ដូចគ្នាមានន័យ ថា អាចជា ឃ្លីសទាំងពីរ ឬ ឃ្លីខៀវទាំងពីរ

គេបាន $n(A)=C(2,2)+C(3,2)=1+3=4$

$$n(S)=C(5,2)=\frac{5!}{3!2!}=10$$

នាំឲ្យ $P(A)=\dfrac{4}{10}=\dfrac{2}{5}$ ដូចនេះ $\boxed{P(A)=\dfrac{2}{5}}$

២. រកប្រូបាបនៃព្រឹត្តិការណ៍ B : «គេចាប់បានឃ្លីមានផលបូកលេខស្មើ 3 »

តាមរូបមន្ត $P(B)=\dfrac{n(B)}{n(S)}$

ដោយ ផលបូកលេខស្មើ 3 គឺមាន 4 ករណី

$$\left\{(1_{\text{ពណ៌ខ្មៅ}}, 2_{\text{ពណ៌ខ្មៅ}}); (1_{\text{ពណ៌ខ្មៅ}}, 2_{\text{ពណ៌ស}}); (1_{\text{ពណ៌ស}}, 2_{\text{ពណ៌ខ្មៅ}}); (1_{\text{ពណ៌ស}}, 2_{\text{ពណ៌ស}})\right\}$$

គេបាន $n(B)=4\ ;\quad n(S)=10$

គេបាន $P(B)=\dfrac{4}{10}=\dfrac{2}{5}$ ដូចនេះ $\boxed{P(B)=\dfrac{2}{5}}$

៣. រកប្រូបាបនៃព្រឹត្តិការណ៍

C : «គេចាប់បានឃ្លីមានផលបូកលេខស្មើ 3 ដោយបានដឹងថា វាមានពណ៌ដូចគ្នា»

តាមរូបមន្ត $P(C)=P(B/A)=\dfrac{P(A\cap B)}{P(A)}$

ដោយ ផលបូកស្មើ3 ដែលមានលេខដូចគ្នា គឺ មាន 2 ករណី $\left\{(1_{\text{ពណ៌ខ្មៅ}}, 2_{\text{ពណ៌ខ្មៅ}}); (1_{\text{ពណ៌ស}}, 2_{\text{ពណ៌ស}})\right\}$

គេបាន $n(A\cap B)=2\ ;\quad n(S)=10 \quad\Rightarrow\quad P(A\cap B)=\dfrac{2}{10}=\dfrac{1}{5}$

នាំឲ្យ $P(C)=\dfrac{\frac{1}{5}}{\frac{2}{5}}=\dfrac{1}{2}$ ដូចនេះ $\boxed{P(C)=\dfrac{1}{2}}$

III. គណនា $z_1+z_2$ , $(z_1+z_2)\times z_3$

យើងមាន $z_1=\sqrt{3}-i\ ;\quad z_2=\left(1-\sqrt{3}\right)+\left(1-\sqrt{3}\right)i\ ;\quad z_3=-\dfrac{1}{2}$

$z_1+z_2=\sqrt{3}-i+1-\sqrt{3}+i-\sqrt{3}i=1-\sqrt{3}i$ ដូចនេះ $\boxed{z_1+z_2=1-\sqrt{3}i}$

$(z_1+z_2)\times z_3=\left(1-\sqrt{3}i\right)\left(-\dfrac{1}{2}\right)=-\dfrac{1}{2}+\dfrac{\sqrt{3}}{2}i$ ដូចនេះ $\boxed{(z_1+z_2)\times z_3=-\dfrac{1}{2}+\dfrac{\sqrt{3}}{2}i}$

សរសេរជាទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $Z=(z_1+z_2)\times z_3$

$$Z=(z_1+z_2)\times z_3=-\frac{1}{2}+\frac{\sqrt{3}}{2}i=\cos\frac{2\pi}{3}+i\sin\frac{2\pi}{3}$$

ដូចនេះ $\boxed{\text{ទម្រង់ត្រីកោណមាត្រនៃ } Z \text{ គឺ } Z=\cos\dfrac{2\pi}{3}+i\sin\dfrac{2\pi}{3}}$

ទាញរកតម្លៃនៃ $Z^3$

$$Z^3=\left(\cos\frac{2\pi}{3}+i\sin\frac{2\pi}{3}\right)^3=\cos\frac{3(2\pi)}{3}+i\sin\frac{3(2\pi)}{3}=\cos 2\pi+i\sin 2\pi=1+0i=1$$

ដូចនេះ $\boxed{Z^3=1}$

IV. ១. កំណត់ចំនួនពិត $m, n$ និង $p$

យើងមាន $g(x)=\dfrac{x^2+x-6}{x^2-2x-3}$

$$g(x)=m+\frac{n}{x+1}+\frac{p}{x-3}$$

$$\Leftrightarrow \frac{x^2+x-6}{x^2-2x-3}=\frac{m(x+1)(x-3)+n(x-3)+p(x+1)}{(x+1)(x-3)}$$

$$=\frac{mx^2-3mx+x-3+nx-3n+px+p}{x^2-3x+x-3}$$

$$=\frac{mx^2+(-3m+1+n+p)x+(p-3-3n)}{x^2-2x-3}$$

$$\Rightarrow \begin{cases} m=1 & (1)\\ -3m+1+n+p=1 & (2)\\ p-3-3n=-6 & (3)\end{cases}$$

$(1):\ m=1 \Rightarrow (2):\ -3+1+n+p=1 \Rightarrow n+p=3\ \ (4)$

$(3):\ p-3-3n=-6 \qquad \Rightarrow p-3n=-3\ \ (5)$

យក $(4)-(5)\Rightarrow n+3n=3+3 \quad \Rightarrow 4n=6 \quad \Rightarrow n=\dfrac{3}{2}$ ជំនួសក្នុង $(4)$

$\Rightarrow \dfrac{3}{2}+p=3 \qquad \Rightarrow p=\dfrac{3}{2}$

ដូចនេះ $\boxed{m=1,\ n=\dfrac{3}{2},\ p=\dfrac{3}{2}}$

២. គណនា $I=\displaystyle\int_0^2 g(x)dx$

$$g(x)=m+\frac{n}{x+1}+\frac{p}{x-3}=1+\frac{3}{2}\cdot\frac{1}{x+1}+\frac{3}{2}\cdot\frac{1}{x-3}$$

$$I=\int_0^2 g(x)dx=\int_0^2\left(1+\frac{3}{2}\cdot\frac{1}{x+1}+\frac{3}{2}\cdot\frac{1}{x-3}\right)dx$$

$$= \left[x + \frac{3}{2}\ln|x+1| + \frac{3}{2}\ln|x-3|\right]_0^2 = 2 + \frac{3}{2}\ln 3 + \frac{3}{2}\ln 1 - \left(0 + \frac{3}{2}\ln 1 + \frac{3}{2}\ln 3\right)$$

$$= 2$$

ដូចនេះ $\boxed{I = 2}$

V. ១. គណនា $\vec{n} = \overrightarrow{AB} \times \overrightarrow{AC}$

យើងមាន $A(-1, 2, 1)$; $B(1, -6, -1)$ ; $C(2, 2, 2)$ នាំឲ្យ

- $\overrightarrow{AB}(1-(-1), -6-2, -1-1) \quad \Rightarrow \quad \overrightarrow{AB}(2, -8, -2)$
- $\overrightarrow{AC}(2-(-1), 2-2, 2-1) \quad \Rightarrow \quad \overrightarrow{AC}(3, 0, 1)$

គេបាន $\vec{n} = \overrightarrow{AB} \times \overrightarrow{AC} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 2 & -8 & -2 \\ 3 & 0 & 1 \end{vmatrix}$

$$= (-8-0)\,\vec{i} - (2+6)\,\vec{j} + (0+24)\,\vec{k}$$

$$= -8\,\vec{i} - 8\,\vec{j} + 24\,\vec{k}$$

ដូចនេះ $\boxed{\vec{n}(-8, -8, 24)}$

លីម សីហា

កំណត់សមីការប្លង់ P

សមីការប្លង់(P) កំណត់ដោយ $(P):\ a(x-x_o) + b(y-y_o) + c(z-z_o) = 0$

ដោយ

- (P) កាត់តាម $A(-1, 2, 1)$
- ហើយមានវ៉ិចទ័រណរម៉ាល់ $\vec{n}(-8, -8, 24)$

យើងបាន $(P):\ -8(x+1) - 8(y-2) + 24(z-1) = 0$

$$-8x - 8 - 8y + 16 + 24z - 24 = 0$$

$$-8x - 8y + 24z - 16 = 0$$

$$-x - y + 3z - 2 = 0$$

ដូចនេះ $\boxed{(P):\ -x - y + 3z - 2 = 0}$

កំណត់សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ d

សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ d កំណត់ដោយ $\begin{cases} x = x_o + at \\ y = y_o + bt \\ z = z_o + ct \end{cases} \quad ; t \in \mathbb{R}$

ដោយ

- d កាត់តាមចំណុច $J(-2, 0, 0)$
- និងមានវ៉ិចទ័រប្រាប់ទិស $\vec{u} = (3, 0, 1)$

យើងបាន $\begin{cases} x = -2 + 3t \\ y = 0 + 0t \\ z = 0 + t \end{cases} \quad ; t \in \mathbb{R}$

ដូចនេះ សមីការប៉ារ៉ាម៉ែតនៃបន្ទាត់d គឺ $\begin{cases} x = -2 + 3t \\ y = 0 \\ z = t \end{cases} \quad ; t \in \mathbb{R}$

២. រកកូអរដោនេនៃផ្ចិត I និងកាំ r នៃស្វ៊ែ S

ដោយ ស្វ៊ែ S ដែលមានសមីការ

$$\begin{aligned} & x^2 + y^2 + z^2 - 2y + 2z - 2 = 0 \\ \Leftrightarrow\ & x^2 + y^2 - 2y + 1 - 1 + z^2 + 2z + 1 - 1 - 2 = 0 \\ \Leftrightarrow\ & (x-0)^2 + (y-1)^2 + (z+1)^2 = 4 \\ \Leftrightarrow\ & (x-0)^2 + (y-1)^2 + (z+1)^2 = 2^2 \end{aligned}$$

ដូចនេះ ផ្ចិត$I(0, 1, -1)$, កាំ $r = 2$

រកកូអរដោនេនៃចំណុចប្រសព្វរវាងស្វ៊ែ S និងបន្ទាត់ d

ចំណុចប្រសព្វរវាងស្វ៊ែ S និងបន្ទាត់ d គឺជាចម្លើយនៃប្រព័ន្ធសមីការ រវាង បន្ទាត់d និងស្វ៊ែS

$$\begin{cases} x = -2 + 3t & (1) \\ y = 0 & (2) \\ z = t & (3) \\ x^2 + y^2 + z^2 - 2y + 2z - 2 = 0 & (4) \end{cases}$$

យក (1), (2), (3) ជួសក្នុង (4) យើងបាន $(-2+3t)^2+0^2+t^2-2(0)+2t-2=0$

$$4-12t+9t^2+t^2+2t-2=0$$

$$10t^2-10t+2=0$$

$$5t^2-5t+1=0$$

$\Delta=b^2-4ac=25-20=5 \quad \Rightarrow \sqrt{\Delta}=\sqrt{5}$

$t=\dfrac{-b\pm\sqrt{\Delta}}{2a}=\dfrac{5\pm\sqrt{5}}{10}$ ជំនួសក្នុង (1), (2), (3) យើងបាន

- ចំពោះ $t=\dfrac{5+\sqrt{5}}{10} \quad \Rightarrow x=-2+3\left(\dfrac{5+\sqrt{5}}{10}\right)=\dfrac{-5+3\sqrt{5}}{10}$

$$y=0 \quad ; \; z=\dfrac{5+\sqrt{5}}{10}$$

ដូចនេះ $\boxed{\text{ចំណុចប្រសព្វ គឺ } \left(\dfrac{-5+3\sqrt{5}}{10},\; 0,\; \dfrac{5+\sqrt{5}}{10}\right)}$

- ចំពោះ $t=\dfrac{5-\sqrt{5}}{10} \quad \Rightarrow x=-2+3\left(\dfrac{5-\sqrt{5}}{10}\right)=\dfrac{-5-3\sqrt{5}}{10}$

$$y=0 \quad ; \; z=\dfrac{5-\sqrt{5}}{10}$$

ដូចនេះ $\boxed{\text{ចំណុចប្រសព្វ គឺ } \left(\dfrac{-5-3\sqrt{5}}{10},\; 0,\; \dfrac{5-\sqrt{5}}{10}\right)}$

លឹម សីហា

៣. គណនាផ្ទៃក្រឡានៃត្រីកោណ ABC

ដោយ $\overrightarrow{AB}\times\overrightarrow{AC}=-8\vec{i}-8\vec{j}+24\vec{k}$ យើងបាន

$$S_{ABC}=\frac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|=\frac{1}{2}\sqrt{(-8)^2+(-8)^2+24^2}=\frac{1}{2}\sqrt{64+64+576}=\frac{1}{2}\sqrt{704}$$

$$=\frac{\sqrt{64\times 11}}{2}=\frac{8\sqrt{11}}{2}=4\sqrt{11}$$

ដូចនេះ $\boxed{S_{ABC}=4\sqrt{11}\text{ ឯកតាផ្ទៃ}}$

គណនាចម្ងាយពីចំណុច $D(0,1,-1)$ ទៅប្លង់ P

តាមរូបមន្ត $D_{(D,P)}=\dfrac{|ax_o+by_o+cz_o+d|}{\sqrt{a^2+b^2+c^2}}$

ដោយ $D(0,1,-1)$ ; $(P):\ -x-y+3z-2=0$ យើងបាន

$$D_{(D,P)}=\frac{\left|-(0)-(1)+3(-1)-2\right|}{\sqrt{(-1)^2+(-1)^2+3^2}}=\frac{|-6|}{\sqrt{11}}\times\frac{\sqrt{11}}{\sqrt{11}}=\frac{6\sqrt{11}}{11}$$

ដូចនេះ $\boxed{\text{ចម្ងាយពីចំណុច } D \text{ ទៅប្លង់ } P \text{ គឺ } D_{(D,P)}=\dfrac{6\sqrt{11}}{11} \text{ ឯកតាប្រវែង}}$

VI. A អនុគមន៍ $g$ កំណត់លើ $(0,+\infty)$ ដោយ $g(x)=x^2+\ln x$

១. ក. បង្ហាញថា $g$ ជាអនុគមន៍កើនដាច់ខាតលើ $(0,+\infty)$

ដោយ $g'(x)=\left(x^2+\ln x\right)'=2x+\dfrac{1}{x}=\dfrac{2x^2+1}{x}>0 \quad \forall x\in(0,+\infty)$

**ដូចនេះ** $\boxed{g \text{ ជាអនុគមន៍កើនដាច់ខាតលើ } (0,+\infty)}$

ខ. គណនា $g(1)$

$g(1)=1^2+\ln 1=1$ **ដូចនេះ** $\boxed{g(1)=1}$

២. ក. ទាញលទ្ធផលពីសំណួរទី១ បញ្ជាក់ថា ៖

- បើ $x\geq 1$ នោះ $x^2+\ln x\geq 1$
- និង បើ $0<x\leq 1$ នោះ $x^2+\ln x\leq 1$

ដោយ $g(1)=1$ ហើយ $g$ ជាអនុគមន៍កើនដាច់ខាតលើ $(0,+\infty)$

នោះគេបាន

- បើ $x\geq 1$ នោះ $g(x)\geq 1 \Rightarrow x^2+\ln x\geq 1$
- បើ $0<x\leq 1$ នោះ $g(x)\leq 1 \Rightarrow x^2+\ln x\leq 1$

ខ. កំណត់សញ្ញានៃកន្សោម $x^2+\ln x-1$ កាលណា $x$ នៅលើចន្លោះ $(0,+\infty)$

- ពេល $x>1;\quad x^2+\ln x>1 \Rightarrow x^2+\ln x-1>0$
- ពេល $0<x<1;\quad x^2+\ln x\leq 1 \Rightarrow x^2+\ln x-1<0$
- ពេល $x=1;\quad x^2+\ln x=1 \Rightarrow x^2+\ln x-1=0$

B អនុគមន៍ $f$ កំណត់លើ $(0,+\infty)$ ដោយ $f(x)=x+1-\dfrac{\ln x}{x}$

១. សិក្សាលីមីតនៃអនុគមន៍ f ត្រង់ 0 និង $+\infty$ (យើងដឹងថា $\lim\limits_{x\to+\infty}\dfrac{\ln x}{x}=0$ )

$$\lim_{x\to0}f(x)=\lim_{x\to0}\left(x+1-\frac{\ln x}{x}\right)=0+1-(-\infty)=+\infty \qquad \boxed{\lim_{x\to0}f(x)=+\infty}$$

$$\lim_{x\to+\infty}f(x)=\lim_{x\to+\infty}\left(x+1-\frac{\ln x}{x}\right)=+\infty+1-0=+\infty \qquad \boxed{\lim_{x\to+\infty}f(x)=+\infty}$$

២. បង្ហាញថាដេរីវេនៃអនុគមន៍ f គឺ $f'(x)=\dfrac{x^2+\ln x-1}{x^2}$

$$f'(x)=\left(x+1-\frac{\ln x}{x}\right)'=1-\frac{(\ln x)'\,x-x'\ln x}{x^2}=1-\frac{\frac{1}{x}\cdot x-\ln x}{x^2}=\frac{x^2+\ln x-1}{x^2}$$

$$\boxed{f'(x)=\frac{x^2+\ln x-1}{x^2}}$$

៣. ប្រើលទ្ធផលនៃសំណួរ A សិក្សាសញ្ញានៃ $f'(x)$

ដោយ $f'(x)=\dfrac{x^2+\ln x-1}{x^2}$ មានសញ្ញាតាមភាគយក $x^2+\ln x-1$

គេបាន

- ពេល $x>1;\quad f'(x)>0$
- ពេល $0<x<1;\quad f'(x)<0$
- ពេល $x=1;\quad f'(x)=0$

សង់តារាងអថេរភាពនៃអនុគមន៍ f លើ$(0,+\infty)$

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | ‖ $+\infty$ | ↘ | $2$ | ↗ | $+\infty$ |

៤. ក. បង្ហាញថាបន្ទាត់ $\Delta:\ y=x+1$ ជាអាស៊ីមតូតទៅនឹងក្រាប $C$ ត្រង់ $+\infty$

បន្ទាត់ $\Delta:\ y=x+1$ ជាអាស៊ីមតូតទៅនឹងក្រាប $C$ ត្រង់ $+\infty$ លុះត្រាតែ

$\lim\limits_{x\to+\infty}[f(x)-(x+1)]=0$ ដោយ $(C):\ f(x)=x+1-\dfrac{\ln x}{x}$

គេបាន $\lim\limits_{x\to+\infty}[f(x)-(x+1)]=\lim\limits_{x\to+\infty}\left(-\dfrac{\ln x}{x}\right)=0$ ពិត

**ដូចនេះ** $\boxed{\Delta:\ y=x+1 \text{ ជាអាស៊ីមតូតនៃក្រាប} C}$

ខ. សិក្សាទីតាំង $C$ ធៀបនឹង $\Delta$

$(C):\ y_c=x+1-\dfrac{\ln x}{x};\quad (\Delta):\ y_\Delta=x+1 \quad\Rightarrow\ y_c-y_\Delta=-\dfrac{\ln x}{x}$

ដោយ $x\in(0,+\infty)$ គេបាន $y_c-y_\Delta$ មានសញ្ញាតាម $-\ln x$

- $y_c-y_\Delta=0 \quad\Leftrightarrow\ -\ln x=0\Leftrightarrow x=1$ គេបាន $(C)\cap(\Delta)$
- $y_c-y_\Delta>0 \quad\Leftrightarrow\ -\ln x>0\Leftrightarrow \ln x<0\Leftrightarrow x<1$ គេបាន $(C)$ ស្ថិតនៅលើ $(\Delta)$
- $y_c-y_\Delta<0 \quad\Leftrightarrow\ -\ln x<0\Leftrightarrow \ln x>0\Leftrightarrow x>1$ គេបាន $(C)$ ស្ថិនៅក្រោម $(\Delta)$

កូអរដោនេនៃចំណុចប្រសព្វ $I$ រវាងក្រាប $C$ និង $\Delta$ គឺ $x=1 \quad\Rightarrow y=1+1=2$

**ដូចនេះ** $\boxed{I(1,2)}$

លឹម សីហា

សង់ $\Delta$ និងក្រាប $C$

- $(\Delta):\ y=x+1$

| x | 0 | −1 |
|---|---|---|
| y | 1 | 0 |



# វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡង
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨

## [វិញ្ញាសាទី៨]

I. (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to 1}\dfrac{1-x^2}{x^3-x^2+x-1}$ ខ. $\lim\limits_{x\to 0}\dfrac{\sin 3x}{-x}$ គ. $\lim\limits_{x\to 0}\dfrac{\sqrt{2+x}-\sqrt{2-x}}{\sin x}$

II. (១៥ពិន្ទុ) គណនាអាំងតេក្រាល $I=\displaystyle\int_0^2\left(6x^2-3x-1\right)dx$ , $J=\displaystyle\int_0^{\frac{\pi}{4}}\left(1-2\sin^2 x\right)dx$ ។

គេមាន f កំណត់លើ $\mathbb{R}^*$ ដោយ $f(x)=-2\left(\dfrac{x+1}{x^2}\right)$ ។ បង្ហាញថា $f(x)=-\dfrac{2}{x}-\dfrac{2}{x^2}$ ។

គណនា $K=\displaystyle\int_1^e f(x)dx$ ។ $(\ln e=1)$

III. (១៥ពិន្ទុ) គេឲ្យសមីការឌីផេរ៉ង់ស្យែល $f''+2f'=0$ ។

១. គេតាង $g=f'$ ។ បង្ហាញថា g ជាចម្លើយនៃសមីការ $g'+2g=0$ ។

២. ដោះស្រាយសមីការ $g'+2g=0$ រួចទាញរកចម្លើយនៃសមីការ $f''+2f'=0$ ។

៣. ផ្ទៀងផ្ទាត់ចម្លើយនៅសំណួរ២ ដោយដោះស្រាយសមីការ $f''+2f'=0$ តាមសមីការសម្គាល់។

IV. (១០ពិន្ទុ) រកសមីការស្តង់ដានៃអេលីបដែលមានកំពូលទាំងពីរជាចំណុច $(4,0)$ និង $(-4,0)$ និង មានកំណុំមួយនៅត្រង់ចំណុច $(3,0)$ រួចសង់អេលីបនេះ។

V. (៣៥ពិន្ទុ) ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន$\left(O,\vec{i},\vec{j},\vec{k}\right)$មួយ គេដៅចំណុច$A(2,2,0)$, $B(0,2,2)$, $C(1,0,1)$។

១. រកសមីការស្វ៊ែ S ដែលមានអង្កត់ផ្ចិត AB ។ រកកូអរដោនេនៃចំណុចប្រសព្វទាំងពីររវាងស្វ៊ែ S និងបន្ទាត់ d សមីការប៉ារ៉ាម៉ែត $x=1+t$, $y=2$ និង $z=1+t$ ដែល t ជាចំនួនពិត។

២. រកកូអរដោនេនៃវ៉ិចទ័រផលគុណ $\vec{n}=\overrightarrow{CA}\times\overrightarrow{CB}$ គណនាផ្ទៃក្រឡានៃ $\Delta ABC$ ។
រកសមីការប្លង់ ABC ។

៣. ប្លង់ ABC ជួប (Ox) ត្រង់ M និងជួប Oz ត្រង់ N ។ រកកូអរដោនេនៃចំណុច M និង N ។
បង្ហាញថា $\overrightarrow{AB}=\overrightarrow{MN}$ និង $\overrightarrow{MA}\cdot\overrightarrow{MN}=0$ ។ ទាញបញ្ជាក់ថា ABNM ជាចតុកោណកែង។

៤. រកចម្ងាយពីចំណុច $D(0,2,0)$ ទៅប្លង់ ABC ។ទាញរកមាឌនៃតេត្រាអ៊ែត DBCA ។

VI. (៣៥ពិន្ទុ) f ជាអនុគមន៍កំណត់ចំពោះ $x > 0$ ដោយ $f(x) = 1 + 2\left(\frac{\ln x}{x}\right)$ ហើយមានក្រាប (C) ។

១. គណនា $\lim\limits_{x \to 0^+} f(x)$ និង $\lim\limits_{x \to +\infty} f(x)$ ។ កំណត់សមីការអាស៊ីមតូតឈរ និងដេកនៃក្រាប (C) ។

២. គណនាដេរីវេ $f'(x)$ និងសិក្សាសញ្ញានៃ $f'(x)$ ។ សង់តារាងអថេរភាពនៃអនុគមន៍ f ។

៣. កំណត់កូអរដោនេនៃចំណុចប្រសព្វ A រវាងក្រាប (C) និងបន្ទាត់ (D) : $y = 1$ ។
កំណត់សមីការបន្ទាត់ (L) ដែលប៉ះនឹងក្រាប (C) ត្រង់ចំណុច A ។

៤. គណនា $f\left(\frac{1}{2}\right)$ ។ សង់បន្ទាត់ (L) អាស៊ីមតូត និងក្រាប (C) នៅក្នុងតម្រុយតែមួយ។
(គេយក $e = 2.7,\ \frac{2}{e} = 0.7,\ \ln 2 = 0.7$ )

លឹម សីហា

## [ដំណោះស្រាយ]

I. គណនាលីមីត៖

ក. $\lim\limits_{x\to 1}\dfrac{1-x^2}{x^3-x^2+x-1}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to 1}\frac{(1-x)(1+x)}{(x-1)\left(x^2+1\right)}=\lim_{x\to 1}\frac{-(x-1)(1+x)}{(x-1)\left(x^2+1\right)}=\lim_{x\to 1}\frac{-(1+x)}{\left(x^2+1\right)}=\frac{-(1+1)}{1^2+1}=-1$$

ដូចនេះ $\boxed{\lim\limits_{x\to 1}\dfrac{1-x^2}{x^3-x^2+x-1}=-1}$

ខ. $\lim\limits_{x\to 0}\dfrac{\sin 3x}{-x}$ (មានរាងមិនកំណត់$\frac{0}{0}$)

$$=\lim_{x\to 0}\left(-3\frac{\sin 3x}{3x}\right)=-3\times 1=-3$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{\sin 3x}{-x}=-3}$

គ. $\lim\limits_{x\to 0}\dfrac{\sqrt{2+x}-\sqrt{2-x}}{\sin x}$ (មានរាងមិនកំណត់$\frac{0}{0}$)

$$=\lim_{x\to 0}\frac{\left(\sqrt{2+x}-\sqrt{2-x}\right)\left(\sqrt{2+x}+\sqrt{2-x}\right)}{\sin x\left(\sqrt{2+x}+\sqrt{2-x}\right)}=\lim_{x\to 0}\frac{2+x-(2-x)}{\sin x\left(\sqrt{2+x}+\sqrt{2-x}\right)}$$

$$=\lim_{x\to 0}\frac{2x}{\sin x\left(\sqrt{2+x}+\sqrt{2-x}\right)}=\lim_{x\to 0}\frac{x}{\sin x}\cdot\frac{2}{\sqrt{2+x}+\sqrt{2-x}}$$

$$=1\times\frac{2}{\sqrt{2+0}+\sqrt{2-0}}=\frac{2}{2\sqrt{2}}\times\frac{\sqrt{2}}{\sqrt{2}}=\frac{\sqrt{2}}{2}$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{\sqrt{2+x}-\sqrt{2-x}}{\sin x}=\dfrac{\sqrt{2}}{2}}$

II. គណនាអាំងតេក្រាល

- $I=\displaystyle\int_0^2\left(6x^2-3x-1\right)dx=\left[\frac{6x^3}{3}-\frac{3x^2}{2}-x\right]_0^2=2(2)^3-\frac{3(2)^2}{2}-2-0=8$ $\boxed{I=8}$
- $J=\displaystyle\int_0^{\frac{\pi}{4}}\left(1-2\sin^2 x\right)dx=\int_0^{\frac{\pi}{4}}\cos 2x dx=\left[\frac{1}{2}\sin 2x\right]_0^{\frac{\pi}{4}}=\frac{1}{2}\sin\frac{2\pi}{4}-\frac{1}{2}\sin 0=\frac{1}{2}$

ដូចនេះ $\boxed{J=\dfrac{1}{2}}$

បង្ហាញថា $f(x) = -\frac{2}{x} - \frac{2}{x^2}$

ដោយ $f(x) = -2\left(\frac{x+1}{x^2}\right) = \frac{-2x-2}{x^2} = \frac{-2x}{x^2} - \frac{2}{x^2} = -\frac{2}{x} - \frac{2}{x^2}$ ពិត

ដូចនេះ $\boxed{f(x) = -\frac{2}{x} - \frac{2}{x^2}}$

គណនា $K = \int_1^e f(x)dx \quad (\ln e = 1)$

$$K = \int_1^e f(x)dx = \int_1^e \left(-\frac{2}{x} - \frac{2}{x^2}\right)dx = \left[-2\ln|x| + \frac{2}{x}\right]_1^e = -2\ln e + \frac{2}{e} - \left(-2\ln 1 + \frac{2}{1}\right)$$

$$= -2 + \frac{2}{e} + 0 - 2 = -4 + \frac{2}{e}$$ ដូចនេះ $\boxed{K = -4 + \frac{2}{e}}$

III. ១. គេតាង $g = f'$ បង្ហាញថា $g$ ជាចម្លើយនៃសមីការ $g' + 2g = 0$

យើងមាន សមីការឌីផេរ៉ង់ស្យែល $f'' + 2f' = 0 \quad \Leftrightarrow \quad (f')' + 2f' = 0$

$$\Leftrightarrow \quad g' + 2g = 0$$

ដូចនេះ $\boxed{g = f' \text{ ជាចម្លើយនៃ } g' + 2g = 0}$

លឹម សីហា

២. ដោះស្រាយសមីការ $g' + 2g = 0$

$$g' + 2g = 0 \Rightarrow g' = -2g \Leftrightarrow \frac{dg}{dx} = -2g \Leftrightarrow \int \frac{1}{g}dg = \int -2dx \Rightarrow \ln|g| = -2$$

$$\Rightarrow g = Ae^{-2};\ A \in \mathbb{R}$$

ដូចនេះ $\boxed{\text{ចម្លើយនៃសមីការ } g' + 2g = 0 \text{ គឺ } g(x) = Ae^{-2x} \quad ;\ A \in \mathbb{R}}$

ទាញរកចម្លើយនៃសមីការ $f'' + 2f' = 0$

ដោយ $f' = g \quad \Rightarrow f = \int g(x)dx = \int Ae^{-2x}dx$

$$= -\frac{A}{2}e^{-2x} + C$$

$$= -De^{-2x} + C \quad ;\ D = \frac{A}{2}, C \in \mathbb{R}$$

ដូចនេះ $\boxed{\text{ចម្លើយនៃសមីការ } f'' + 2f' = 0 \text{ គឺ } f(x) = -De^{-2x} + C \quad ;\ A, C \in \mathbb{R}}$

៣. ផ្ទៀងផ្ទាត់ចម្លើយនៅសំណួរ២ ដោយដោះស្រាយសមីការ $f'' + 2f' = 0$ តាមសមីការសម្គាល់

សមីការសម្គាល់គឺ $r^2 + 2r = 0 \Leftrightarrow r(r+2) = 0 \Rightarrow r = 0, r = -2$

យើងបាន ចម្លើយនៃសមីការ គឺ

$f(x) = Ae^{0x} - Be^{-2x} = -Be^{-2x} + A = -De^{-2x} + C \quad ; \; D = B; \; C = A, C, D \in \mathbb{R}$

ដូចនេះ **ចម្លើយនៅសំណួរទី២ ត្រឹមត្រូវ**

IV. រកសមីការស្តង់ដានៃអេលីប

ដោយ កំពូល កំណុំមានអរដោនេថេរ គេបាន អ័ក្សទទឹងស្របអ័ក្សអាប់ស៊ីស

នោះ សមីការស្តង់ដា នៃអេលីបគឺ $\dfrac{(x-h)^2}{a^2} + \dfrac{(y-h)^2}{b^2} = 1$

- កំពូល$V_1(h+a, k)$ គឺ $(4, 0) \;\Rightarrow\; h + a = 4 \; ; \quad k = 0$
- កំពូល $V_2(h-a, k)$ គឺ $(-4, 0) \;\Rightarrow\; h - a = -4; \quad k = 0$

$$\begin{cases} h + a = 4 \\ \underline{h - a = -4} \end{cases}$$

$2h \quad = 0 \quad \Rightarrow \; h = 0; \quad a = 4$

លីម សីហា

- កំណុំ $F(h+c, 0)$ គឺ $(3, 0) \;\Rightarrow h + c = 3 \quad \Rightarrow \; c = 3$
- $c^2 = a^2 - b^2 \;\Rightarrow\; b^2 = a^2 - c^2 = 4^2 - 3^2 = 16 - 9 = 7$

ដូចនេះ **អេលីបមានសមីការ $\dfrac{x^2}{16} + \dfrac{y^2}{7} = 1$**

- សង់អេលីប   ផ្ចិតនៃអេលីបគឺ $I(0, 0)$



V. ១. រកសមីការស្វ៊ែ S ដែលមានអង្កត់ផ្ចិត AB

សមីការស្វ៊ែ S កំណត់ដោយ $(x-a)^2+(y-b)^2+(z-c)^2=r^2$

ដោយ ស្វ៊ែ S មានអង្កត់ផ្ចិត AB យើងបាន

- ចំណុចកណ្តាលនៃអង្កត់ AB ជាផ្ចិតនៃស្វ៊ែ S
- កាំនៃស្វ៊ែគឺ $r=\frac{|AB|}{2}$

យើងមាន $A(2,2,0),\ B(0,2,2)$ យើងបាន

- ផ្ចិត $I\left(\frac{x_A+x_B}{2},\frac{y_A+y_B}{2}\right)\quad\Rightarrow I\left(\frac{2+0}{2},\frac{2+2}{2},\frac{0+2}{2}\right)\quad\Rightarrow I(1,2,1)$
- កាំ $r=\frac{\sqrt{(0-2)^2+(2-2)^2+(2-0)^2}}{2}=\frac{\sqrt{8}}{2}\frac{2\sqrt{2}}{2}=\sqrt{2}$

ដូចនេះ | សមីការស្វ៊ែS គឺ $(x-1)^2+(y-2)^2+(z-1)^2=2$ |

រកកូអរដោនេនៃចំណុចប្រសព្វទាំងពីររវាងស្វ៊ែ S និងបន្ទាត់ d

$(S):\ (x-1)^2+(y-2)^2+(z-1)^2=2$

$(d): x=1+t,\ y=2\ ,z=1+t$

កូអរដោនេនៃចំណុចប្រសព្វរវាងស្វ៊ែ S និងបន្ទាត់ d គឺជាចម្លើយនៃប្រព័ន្ធសមីការរវាង S និង d

លីម សីហា

យក $x=1+t,\ y=2,\ z=1+t$ ជំនួសក្នុងសមីការស្វ៊ែS យើងបាន

$(1+t-1)^2+(2-2)^2+(1+t-1)^2=2$

$\Rightarrow\quad t^2+t^2=2\quad\Rightarrow 2t^2=2\quad\Rightarrow t^2=1\quad\Rightarrow t=\pm1$ ជំនួសក្នុងសមីការស្វ៊ែS

- ចំពោះ $t=1$ យើងបាន $x=2,\ y=2,\ z=2$
- ចំពោះ $t=-1$ យើងបាន $x=0,\ y=2,\ z=0$

ដូចនេះ | ចំណុចប្រសព្វទាំងពីររវាងស្វ៊ែS និងបន្ទាត់d គឺ $(2,2,2);\ (0,2,0)$ |

២. រកកូអរដោនេនៃវ៉ិចទ័រផលគុណ $\vec{n}=\overrightarrow{CA}\times\overrightarrow{CB}$

យើងមាន $A(2,2,0),\ B(0,2,2),\ C(1,0,1)$ យើងបាន

$\overrightarrow{CA}(2-1,2-0,0-1)\quad\Rightarrow\overrightarrow{CA}(1,2,-1)$

$\overrightarrow{CB}(0-1,2-0,2-1)\quad\Rightarrow\overrightarrow{CB}(-1,2,1)$

នាំឲ្យ $\overrightarrow{n} = \overrightarrow{CA} \times \overrightarrow{CB} = \begin{vmatrix} \overrightarrow{i} & \overrightarrow{j} & \overrightarrow{k} \\ 1 & 2 & -1 \\ -1 & 2 & 1 \end{vmatrix} = (2+2)\overrightarrow{i} - (1-1)\overrightarrow{j} + (2+2)\overrightarrow{k}$

$$= 4\overrightarrow{i} - 0\overrightarrow{j} + 4\overrightarrow{k}$$

ដូចនេះ $\boxed{\overrightarrow{n}\,(4,0,4)}$

គណនាផ្ទៃក្រឡានៃ $\Delta ABC$

$$S_{\Delta ABC} = \frac{\left|\overrightarrow{CA} \times \overrightarrow{CB}\right|}{2} = \frac{\sqrt{4^2+0^2+4^2}}{2} = \frac{4\sqrt{2}}{2} = 2\sqrt{2}$$

ដូចនេះ $\boxed{S_{\Delta ABC} = 2\sqrt{2} \text{ ឯកតាផ្ទៃ}}$

រកសមីការប្លង់ ABC

សមីការប្លង់ ABC កំណត់ដោយ $a(x-x_o)+b(y-y_o)+c(z-z_o)=0$

ដោយ ប្លង់ABC

- កាត់តាម $A(2,2,0)$
- ហើយ មានវ៉ិចទ័រ $\overrightarrow{n}\,(4,0,4)$ ជាវ៉ិចទ័រណរម៉ាល់ ព្រោះ $\overrightarrow{n} = \overrightarrow{CA} \times \overrightarrow{CB}$

លីម សីហា

យើងបាន ប្លង់ABC : $4(x-2)+0(y-2)+4(z-0)=0$

$$\Leftrightarrow \quad 4x+4z-8=0$$

$$\Leftrightarrow \quad x+z-2=0$$

ដូចនេះ $\boxed{\text{ប្លង់ABC :}\ x+z-2=0}$

៣. ប្លង់ ABC ជួប (Ox) ត្រង់ M និងជួប Oz ត្រង់ N រកកូអរដោនេនៃចំណុច M និង N

- ប្លង់ABC ជួប(Ox) $\Leftrightarrow y=0, z=0 \quad \Rightarrow x+0-2=0 \quad \Rightarrow x=2$

  ដូចនេះ $\boxed{M(2,0,0)}$

- ប្លង់ABC ជួប(Oz) $\Leftrightarrow x=0, y=0 \quad \Rightarrow 0+z-2=0 \quad \Rightarrow z=2$

  ដូចនេះ $\boxed{N(0,0,2)}$

បង្ហាញថា $\overrightarrow{AB} = \overrightarrow{MN}$ និង $\overrightarrow{MA} \cdot \overrightarrow{MN} = 0$

$\overrightarrow{AB}\,(0-2, 2-2, 2-0) \quad \Rightarrow \overrightarrow{AB}\,(-2, 0, 2)$

$\overrightarrow{MN}\,(0-2, 0-0, 2-0) \quad \Rightarrow \overrightarrow{MN}\,(-2, 0, 2)$ ដូចនេះ $\boxed{\overrightarrow{AB} = \overrightarrow{MN}}$

$\overrightarrow{MA}\,(2-2, 2-0, 0-0) \quad \Rightarrow \overrightarrow{MA}\,(0, 2, 0)$

$\overrightarrow{MA} \cdot \overrightarrow{MN} = -2(0) + 0(2) + 2(0) = 0$ ដូចនេះ $\boxed{\overrightarrow{MA} \cdot \overrightarrow{MN} = 0}$

ទាញបញ្ជាក់ថា ABNM ជាចតុកោណកែង

ដោយ $\overrightarrow{AB} = \overrightarrow{MN} \quad \Rightarrow \left|\overrightarrow{AB}\right| = \left|\overrightarrow{MN}\right| \quad (1)$

ហើយ $\overrightarrow{MA} \cdot \overrightarrow{MN} = 0 \quad \Rightarrow \overrightarrow{MA} \perp \overrightarrow{MN} \quad (2)$

តាម (1) និង (2) ដូចនេះ $\boxed{\text{ABNM ជាចតុកោណកែង}}$

៤. រកចម្ងាយពីចំណុច $D(0, 2, 0)$ ទៅប្លង់ ABC

លឹម សីហា

$$D_{(D,(ABC))} = \frac{|ax_o + by_o + cz_o + d|}{\sqrt{a^2 + b^2 + c^2}}$$

- $D(0, 2, 0)$
- $(ABC):\ x + z - 2 = 0$

$$\Longrightarrow D_{(D,(ABC))} = \frac{|0+0-2|}{\sqrt{1^2+1^2}} = \frac{2}{\sqrt{2}} \times \frac{\sqrt{2}}{2} = \frac{2\sqrt{2}}{2} = \sqrt{2}$$

ដូចនេះ $\boxed{D_{(D,(ABC))} = \sqrt{2} \text{ ឯកតាប្រវែង}}$

ទាញរកមាឌនៃតេត្រាអ៊ែត DBCA

$$V_{DBCA} = \frac{1}{3} \cdot S_{ABC} \times h$$

ដោយ $S_{\Delta ABC} = 2\sqrt{2}$

$h = D_{(D,(ABC))} = \sqrt{2}$

យើងបាន $V_{DBCA} = \frac{1}{3} \cdot 2\sqrt{2} \times \sqrt{2} = \frac{4}{3}$ ដូចនេះ $\boxed{V_{DBCA} = \frac{4}{3} \text{ ឯកតាមាឌ}}$

VI. ១. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$

$$f(x) = 1 + 2\left(\frac{\ln x}{x}\right)$$

- $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+}\left(1 + 2\left(\frac{\ln x}{x}\right)\right) = 1 + 2(-\infty) = -\infty$ ដូចនេះ $\boxed{\lim\limits_{x\to 0^+} f(x) = -\infty}$
- $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty}\left(1 + 2\left(\frac{\ln x}{x}\right)\right) = 1 + 2(0) = 1$ ដូចនេះ $\boxed{\lim\limits_{x\to +\infty} f(x) = 1}$

កំណត់សមីការអាស៊ីមតូតឈរ និងដេកនៃក្រាប $(C)$

- ដោយ $\lim\limits_{x\to 0^+} f(x) = -\infty$ ដូចនេះ បន្ទាត់ $x = 0$ ជាអាស៊ីមតូតឈរ
- ដោយ $\lim\limits_{x\to +\infty} f(x) = 1$ ដូចនេះ បន្ទាត់ $y = 1$ ជាអាស៊ីមតូតដេក

២. គណនាដេរីវេ $f'(x)$

$$f'(x) = \left(1 + 2\left(\frac{\ln x}{x}\right)\right)' = 2\left(\frac{(\ln x)'x - x'\ln x}{x^2}\right) = \frac{2 - 2\ln x}{x^2}$$

ដូចនេះ $\boxed{f'(x) = \dfrac{2 - 2\ln x}{x^2}}$

លឹម សីហា

សិក្សាសញ្ញានៃ $f'(x)$

ដោយ $x^2 > 0 \Rightarrow f'(x)$ មានសញ្ញាតាមភាគយក $2 - 2\ln x$

- $f'(x) = 0 \quad \Leftrightarrow 2 - 2\ln x = 0 \Leftrightarrow -2\ln x = -2 \Rightarrow \ln x = 1 \Rightarrow x = e$
- $f'(x) > 0 \quad \Leftrightarrow 2 - 2\ln x > 0 \Leftrightarrow -2\ln x > -2 \Rightarrow \ln x < 1 \Rightarrow x < e$
- $f'(x) < 0 \quad \Leftrightarrow 2 - 2\ln x < 0 \Leftrightarrow -2\ln x < -2 \Rightarrow \ln x > 1 \Rightarrow x > e$

យើងបាន តារាងសញ្ញា $f'(x)$ គឺ

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |

- $x \in (0, e);\ f'(x) > 0$
- $x \in (e, +\infty);\ f'(x) < 0$

សង់តារាងអថេរភាពនៃអនុគមន៍ $f$

- $x = e;\ f(e) = 1 + 2\left(\frac{\ln e}{e}\right) = 1 + \frac{2}{e} = 1 + 0.7 = 1.7$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | ‖ $-\infty$ | ↗ | $1.7$ | ↘ | $1$ |

៣. កំណត់កូអរដោនេនៃចំណុចប្រសព្វ A រវាងក្រាប $(C)$ និងបន្ទាត់ $(D):\ y = 1$

- $(C):\ y = 1 + 2\left(\frac{\ln x}{x}\right)$
- $(D):\ y = 1$

$$\Rightarrow (C)\cap(D) \Leftrightarrow 1 + 2\left(\frac{\ln x}{x}\right) = 1 \quad \Rightarrow \quad 2\frac{\ln x}{x} = 0$$

$$\Rightarrow \quad \ln x = 0$$

$$\Rightarrow \quad x = 1$$

លឹម សីហា

ដូចនេះ **កូអរដោនេនៃចំណុចប្រសព្វ A គឺ $A(1,1)$**

កំណត់សមីការបន្ទាត់ $(L)$ ដែលប៉ះនឹងក្រាប $(C)$ ត្រង់ចំណុច A

$(L):\ y = f'(x_o)(x - x_o) + f(x_o)$

- $(L)$ ប៉ះក្រាប C ត្រង់ $A(1,1)$ $\quad \Rightarrow x_o = 1, y_o = 1$
- $f'(x_o) = f'(1) = \frac{2 - 2\ln 1}{1^2} = 2 \quad ;\ f(x_o) = y_o = 2$

$\Rightarrow (L):\ y = 2(x-1) + 1 = 2x - 1$

ដូចនេះ **$(L):\ y = 2x - 1$**

៩. គណនា $f\left(\frac{1}{2}\right)$

- $f(\frac{1}{2}) = 1 + 2\left(\dfrac{\ln\frac{1}{2}}{\frac{1}{2}}\right) = 1 + 4\ln 2^{-1} = 1 - 4\ln 2 = 1 - 4(0.7) = -1.8$

ដូចនេះ $\boxed{f(\frac{1}{2}) = -1.8}$

សង់បន្ទាត់ (L) អាស៊ីមតូត និងក្រាប (C)

- $(L):\ y = 2x - 1$

| x | 0 | $\frac{1}{2}$ |
|---|---|---|
| y | $-1$ | 0 |



# វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡង
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨

## [វិញ្ញាសាទី៩]

I. (១៥ពិន្ទុ)

១. ដោះស្រាយសមីការ $z^2 - 2\sqrt{2}z + 4 = 0$ (1) ក្នុងសំណុំចំនួនកុំផ្លិច។
រកម៉ូឌុល និងអាគុយម៉ង់នៃឫសនីមួយៗរបស់សមីការ (1)

២. សរសេរ $w = \left(\dfrac{\sqrt{2}+i\sqrt{2}}{\sqrt{2}-i\sqrt{2}}\right)^2$ ជាទម្រង់ត្រីកោណមាត្រ។

II. (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to+\infty} \dfrac{x^2+x+1}{x^2+1}$ ខ. $\lim\limits_{x\to3} \dfrac{x^3-27}{\sqrt{x+6}-3}$ គ. $\lim\limits_{x\to0} \dfrac{e^x+e^{-x}}{2}$

III. (១៥ពិន្ទុ) គ្រូបន្ទុកថ្នាក់បានជ្រើសរើសប្រធានក្រុមរេនសំអាតថ្នាក់ថ្ងៃចំនួន 6 នាក់នៃថ្នាក់រៀនមួយដែលមានសិស្សប្រុសចំនួន20 នាក់ និងសិស្សស្រីចំនួន 15នាក់។ គណនាប្រូបាបខាងក្រោម៖

A «ប្រធានក្រុមសុទ្ធតែប្រុស»

B «ប្រធានក្រុមសុទ្ធតែស្រី»

C «ប្រធានក្រុមមានប្រុស 3 នាក់ និងស្រី 3 នាក់» ។

IV. (១៥ពិន្ទុ) គណនាអាំងតេក្រាល៖

$I = \int_1^3 \left(x-2+3x^2\right)dx$ $J = \int_0^{\frac{\pi}{4}} (\sin 2x - \cos x)\,dx$ $K = \int_0^1 \dfrac{x^3+(x+1)^2}{x^2+1}dx$

ដើម្បីគណនា K យើងត្រូវបង្ហាញថា $\dfrac{x^3+(x+1)^2}{x^2+1} = x+1+\dfrac{x}{x^2+1}$ ។

V. (៣០ពិន្ទុ)

១. អេលីប E មួយមានសមីការ $25x^2+16y^2-150x+64y = 111$ ។

ក. រកកូអរដោនេនៃផ្ចិត កំពូល និងកំណុំរបស់អេលីប E ។

ខ. សង់អេលីប E ក្នុងតម្រុយកូអរដោនេមួយ។

លឹម សីហា

២. ចំណុច $M(-1,0,1);\ N(0,1,2)$ និង $P(1,2,-1)$ ស្ថិតនៅក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $\left(O,\vec{i},\vec{j},\vec{k}\right)$ មួយ។ ប្លង់ $\alpha$ មួយមានសមីការ $x-2y+z-4=0$ ។

ក. រកកូអរដោនេនៃវ៉ិចទ័រ $\vec{n}=\overrightarrow{MN}\times\overrightarrow{MP}$ ហើយទាញរកសមីការប្លង់ $\beta$ ដែលកាត់តាមចំណុច $M,N$ និង $P$ ។

ខ. រកសមីការស្តង់ដានៃស្វ៊ែ $S$ មួយដែលមានផ្ចិត $M$ ហើយកាត់តាមចំណុច $N$ ។ តើប្លង់ $\alpha$ ជួបនឹងស្វ៊ែ $S$ ឬទេ?

VI. (៣៥ពិន្ទុ) គេឲ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x+2-\dfrac{4e^x}{e^x+3}$ ។ គេតាង $C$ ជាក្រាបរបស់វានៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j}\right)$ ។

១. a. គណនាលីមីត $f$ ត្រង់ $-\infty$ និង $+\infty$ ។

b. សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងបន្ទាត់ $d_1$ ដែលមានសមីការ $y=x+2$ ។

២. a. ស្រាយបញ្ជាក់ថាចំពោះគ្រប់ចំនួនពិត $x,\ f'(x)=\left(\dfrac{e^x-3}{e^x+3}\right)^2$ ។

b. សិក្សាអថេរភាពនៃ $f$ លើ $\mathbb{R}$ និង សង់តារាងអថេរភាពនៃ $f$ ។

៣. a. តើគេអាចថាយ៉ាងណាចំពោះបន្ទាត់ប៉ះ$d_2$ ទៅនឹងក្រាប$C$ ត្រង់ចំណុច$I$ ដែលមានអាប់ស៊ីស$\ln(3)$?

b. សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងបន្ទាត់ប៉ះ $d_2$ ។

៤. a. បង្ហាញថាបន្ទាត់ប៉ះ $d_3$ ទៅនឹងក្រាប $C$ ត្រង់ចំណុចដែលមានអាប់ស៊ីសសូន្យមានសមីការ $y=\dfrac{1}{4}x+1$ ។

b. ដោយសន្មត់ថាចំនុច $I$ ជាផ្ចិតឆ្លុះនៃក្រាប $C$ និងក្នុងតម្លៃប្រហែលនៃ $\ln(3)$ ។ ចូរសង់ក្រាប $C$ និងបន្ទាត់ប៉ះ $d_1,d_2,\ d_3$ ។ (នៅក្នុងតម្រុយនេះមួយឯកតាស្មើ 2cm)

## [ដំណោះស្រាយ]

I. ១. ដោះស្រាយសមីការ $z^2-2\sqrt{2}z+4=0$ (1) ក្នុងសំណុំចំនួនកុំផ្លិច

$z^2-2\sqrt{2}z+4=0 \qquad \Delta=b^2-4ac=\left(-2\sqrt{2}\right)^2-4(1)(4)=4(2)-16=-8$

$$\Rightarrow \sqrt{\Delta}=\sqrt{-8}=2i\sqrt{2}$$

$$z_1=\frac{-b-\sqrt{\Delta}}{2a}=\frac{-\left(-2\sqrt{2}\right)-2i\sqrt{2}}{2(1)}=\sqrt{2}-\sqrt{2}i$$

$$z_2=\frac{-b+\sqrt{\Delta}}{2a}=\sqrt{2}+\sqrt{2}i$$

ដូចនេះ $\boxed{z_1=\sqrt{2}-\sqrt{2}i \quad ; \quad z_2=\sqrt{2}+\sqrt{2}i}$

រកម៉ូឌុល និងអាគុយម៉ង់នៃឫសនីមួយៗរបស់សមីការ (1)

- ដោយ $z_1=\sqrt{2}-\sqrt{2}i=2\left(\frac{\sqrt{2}}{2}-\frac{\sqrt{2}}{2}i\right)=2\left(\cos\frac{7\pi}{4}+i\sin\frac{7\pi}{4}\right)$

ដូចនេះ $z_1$ មាន ម៉ូឌុល $r=2$ និងអាគុយម៉ង់ $\theta=\frac{7\pi}{4}$ ឬ $\theta=\frac{7\pi}{4}+2k\pi \quad ; k\in\mathbb{Z}$

- ដោយ $z_2=\sqrt{2}+\sqrt{2}i=2\left(\frac{\sqrt{2}}{2}+\frac{\sqrt{2}}{2}i\right)=2\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)$

ដូចនេះ $z_2$ មាន ម៉ូឌុល $r=2$ និងអាគុយម៉ង់ $\theta=\frac{\pi}{4}$ ឬ $\theta=\frac{\pi}{4}+2k\pi \quad ; k\in\mathbb{Z}$

២. សរសេរ $w=\left(\frac{\sqrt{2}+i\sqrt{2}}{\sqrt{2}-i\sqrt{2}}\right)^2$ ជាទម្រង់ត្រីកោណមាត្រ

$$w=\left(\frac{\sqrt{2}+i\sqrt{2}}{\sqrt{2}-i\sqrt{2}}\right)^2=\left(\frac{z_2}{z_1}\right)^2=\left(\frac{2\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)}{2\left(\cos\frac{7\pi}{4}+i\sin\frac{7\pi}{4}\right)}\right)^2$$

$$=\left(\cos\left(\frac{\pi}{4}-\frac{7\pi}{4}\right)+i\sin\left(\frac{\pi}{4}-\frac{7\pi}{4}\right)\right)^2=\left(\cos\left(-\frac{3\pi}{2}\right)+i\sin\left(-\frac{3\pi}{2}\right)\right)^2$$

$$=\cos(-3\pi)+i\sin(-3\pi)=\cos(-4\pi+\pi)+i\sin(-4\pi+\pi)=\cos\pi+i\sin\pi$$

ដូចនេះ $\boxed{w=\cos\pi+i\sin\pi}$

II. គណនាលីមីត៖

ក. $\lim\limits_{x\to+\infty}\dfrac{x^2+x+1}{x^2+1}$ (មានរាងមិនកំណត់ $\frac{\infty}{\infty}$)

$$=\lim_{x\to+\infty}\frac{x^2\left(1+\frac{1}{x}+\frac{1}{x^2}\right)}{x^2\left(1+\frac{1}{x^2}\right)}=\frac{1+0+0}{1+0}=1$$

ដូចនេះ $\boxed{\lim\limits_{x\to+\infty}\dfrac{x^2+x+1}{x^2+1}=1}$

ខ. $\lim\limits_{x\to3}\dfrac{x^3-27}{\sqrt{x+6}-3}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to3}\frac{\left(x^3-3^3\right)\left(\sqrt{x+6}+3\right)}{\left(\sqrt{x+6}-3\right)\left(\sqrt{x+6}+3\right)}=\lim_{x\to3}\frac{(x-3)\left(x^2+3x+9\right)\left(\sqrt{x+6}+3\right)}{(x+6)-9}$$

$$=\left(3^2+3\cdot3+9\right)\left(\sqrt{3+6}+3\right)=27\times6=162$$

ដូចនេះ $\boxed{\lim\limits_{x\to3}\dfrac{x^3-27}{\sqrt{x+6}-3}=162}$

គ. $\lim\limits_{x\to0}\dfrac{e^x+e^{-x}}{2}=\dfrac{e^0+e^{-0}}{2}=\dfrac{1+1}{2}=1$ ដូចនេះ $\boxed{\lim\limits_{x\to0}\dfrac{e^x+e^{-x}}{2}=1}$

លីម សីហា

III. A «ប្រធានក្រុមសុទ្ធតែប្រុស»

តាមរូបមន្ត $P(A)=\dfrac{n(A)}{n(S)}$ ដោយ $n(A)=C(20,6)=\dfrac{20!}{14!6!}$

$$=\frac{20\times19\times18\times17\times16\times15}{6\times5\times4\times3\times2\times1}$$

$$=19\times17\times8\times15=38760$$

$$n(S)=C(35,6)=\frac{35!}{29!6!}$$

$$=\frac{35\times34\times33\times32\times31\times30}{6\times5\times4\times3\times2\times1}$$

$$=35\times34\times11\times4\times31=1623160$$

យើងបាន $P(A)=\dfrac{38760}{1623160}=\dfrac{19\times17\times8\times15}{35\times34\times11\times4\times31}=\dfrac{19\times3}{7\times11\times31}=\dfrac{57}{2387}$

ដូចនេះ $\boxed{P(A)=\dfrac{57}{2387}}$

B «ប្រធានក្រុមសុទ្ធតែស្រី»

តាមរូបមន្ត $P(B)=\dfrac{n(B)}{n(S)}$ ដោយ $n(B)=C(15,6)=\dfrac{15!}{9!6!}$

$$=\frac{15\times14\times13\times12\times11\times10}{6\times5\times4\times3\times2\times1}$$

$$=7\times13\times11\times5=5005$$

$$n(S)=1623160$$

នាំឲ្យ $P(B)=\dfrac{5005}{1623160}=\dfrac{7\times13\times11\times5}{35\times34\times11\times4\times31}=\dfrac{13}{34\times4\times31}=\dfrac{13}{4216}$

ដូចនេះ $\boxed{P(B)=\dfrac{13}{4216}}$

C «ប្រធានក្រុមមានប្រុស3 នាក់ និងស្រី3 នាក់»

តាមរូបមន្ត $P(C)=\dfrac{n(C)}{n(S)}$ ដោយ $n(C)=C(20,3)C(15,3)$

$$=\frac{20!}{17!3!}\cdot\frac{15!}{12!3!}$$

$$=\frac{20\times19\times18}{3\times2}\cdot\frac{15\times14\times13}{3\times2}$$

$$=10\times19\times15\times14\times13=518700$$

លឹម ស៊ីហា

$$n(S)=1623160$$

យើងបាន $P(C)=\dfrac{518700}{1623160}=\dfrac{10\times19\times15\times14\times13}{35\times34\times11\times4\times31}=\dfrac{19\times15\times13}{34\times11\times31}=\dfrac{3705}{11594}$

ដូចនេះ $\boxed{P(C)=\dfrac{3705}{11594}}$

IV. គណនាអាំងតេក្រាល៖

$$I=\int_1^3\left(x-2+3x^2\right)dx=\left[\frac{x^2}{2}-2x+\frac{3x^3}{3}\right]_1^3=\frac{3^2}{2}-2(3)+3^3-\left(\frac{1^2}{2}-2(1)+1^3\right)$$

$$=\frac{9}{2}-6+27-\frac{1}{2}+2-1=\frac{8}{2}+22=\frac{8+44}{2}=26 \qquad \boxed{I=26}$$

$$J=\int_0^{\frac{\pi}{4}}(\sin 2x-\cos x)\,dx=\left[-\frac{1}{2}\cos 2x-\sin x\right]_0^{\frac{\pi}{4}}$$

$$=-\frac{1}{2}\cos\frac{\pi}{2}-\sin\frac{\pi}{4}-\left(-\frac{1}{2}\cos 0-\sin 0\right)=0-\frac{\sqrt{2}}{2}+\frac{1}{2}=\frac{1-\sqrt{2}}{2} \qquad \boxed{J=\frac{1-\sqrt{2}}{2}}$$

$$K=\int_0^1\frac{x^3+(x+1)^2}{x^2+1}dx$$

ដោយ $x+1+\frac{x}{x^2+1}=\frac{(x+1)\left(x^2+1\right)+x}{x^2+1}=\frac{x^3+x+x^2+1+x}{x^2+1}$

$$=\frac{x^3+x^2+2x+1}{x^2+1}=\frac{x^3+(x+1)^2}{x^2+1}$$

គេបាន $\int_0^1\frac{x^3+(x+1)^2}{x^2+1}dx=\int_0^1\left(x+1+\frac{x}{x^2+1}\right)dx=\int_0^1\left(x+1+\frac{1}{2}\cdot\frac{\left(x^2+1\right)'}{x^2+1}\right)dx$

$$=\left[\frac{x^2}{2}+x+\frac{1}{2}\cdot\ln\left|x^2+1\right|\right]_0^1=\frac{1^2}{2}+1+\frac{1}{2}\ln 2-0$$

$$=\frac{3}{2}+\frac{\ln 2}{2}=\frac{3+\ln 2}{2}$$

ដូចនេះ $\boxed{K=\frac{3+\ln 2}{2}}$

V. ១. ក. រកកូអរដោនេនៃផ្ចិត កំពូល និងកំណុំរបស់អេលីប E

យើងមាន (E) : $25x^2+16y^2-150x+64y=111$

គេបាន $25x^2+16y^2-150x+64y=111$

$\Leftrightarrow 25x^2-150x+16y^2+64y=111$

$\Leftrightarrow 25\left(x^2-6x+9\right)-25(9)+16\left(y^2+4y+4\right)-16(4)=111$

$\Leftrightarrow 25(x-3)^2-225+16(y+2)^2-64=111$

$\Leftrightarrow 25(x-3)^2+16(y+2)^2=400$

$\Leftrightarrow \frac{25(x-3)^2}{400}+\frac{16(y+2)^2}{400}=\frac{400}{400}$

$\Leftrightarrow \frac{(x-3)^2}{16}+\frac{(y+2)^2}{25}=1$

$\Leftrightarrow \frac{(x-3)^2}{4^2}+\frac{(y+2)^2}{5^2}=1$

គេបាន

- អេលីបមានអ័ក្សធំជាអ័ក្សឈរ
- $h=3,\ k=-2$ ; $a=5,\ b=4$; $c^2=a^2-b^2=25-16=9 \quad \Rightarrow c=3$



លឹម សីហា

- ផ្ចិត$(h,k)$ $\boxed{\text{ផ្ចិត}(3,-2)}$
- កំពូល $V_1(h,k-a);\ V_2(h,k+a)$ $\boxed{\text{កំពូល } V_1(3,-7);\ V_2(3,3)}$
- កំណុំ $F_1(h,k-c);\ F_2(h,k+c)$ $\boxed{\text{កំណុំ } F_1(3,-5);\ F_2(3,1)}$

ខ. សង់អេលីប E ក្នុងតម្រុយកូអរដោនេ




២. ក. រកកូអរដោនេនៃវ៉ិចទ័រ $\vec{n} = \overrightarrow{MN} \times \overrightarrow{MP}$

យើងមាន ចំណុច $M(-1,0,1);\ N(0,1,2)\ ;\ P(1,2,-1)$

គេបាន $\overrightarrow{MN}\,(0-(-1),1-0,2-1) \quad \Rightarrow \overrightarrow{MN}\,(1,1,1)$

$\overrightarrow{MP}\,(1-(-1),2-0,-1-1) \quad \Rightarrow \overrightarrow{MP}\,(2,2,-2)$

$$\vec{n} = \overrightarrow{MN} \times \overrightarrow{MP} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 1 & 1 & 1 \\ 2 & 2 & -2 \end{vmatrix} = (-2-2)\,\vec{i} - (-2-2)\,\vec{j} + (2-2)\,\vec{k}$$

$$= -4\,\vec{i} + 4\,\vec{j} + 0\,\vec{k}$$

ដូចនេះ $\boxed{\vec{n}\,(-4,4,0)}$

រកសមីការប្លង់ (β)

សមីការប្លង់ (β) កំណត់ដោយ $(\beta):\ a(x-x_o)+b(y-y_o)+c(z-z_o)=0$

ដោយ ប្លង់ (β) កាត់តាមចំណុច M, N និង P

យើងបាន $\vec{n}(-4,4,0)$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់(β) $\Rightarrow\ a=-4,\ b=4,\ c=0$

(β) កាត់តាម $M(-1,0,1)$ $\Rightarrow\ x_o=-1,\ y_o=0\ ,\ z_o=1$

$$\Longrightarrow\ (\beta):-4(x+1)+4(y-0)+0(z-1)=0$$

$$\Leftrightarrow\ -4x+4y-4=0$$

$$\Leftrightarrow x-y+1=0$$

ដូចនេះ **សមីការប្លង់គឺ $(\beta):\ x-y+1=0$**

ខ. រកសមីការស្តង់ដានៃស្វ៊ែ S

សមីការស្តង់ដានៃស្វ៊ែ S កំណត់ដោយ $(S):\ (x-a)^2+(y-b)^2+(z-c)^2=r^2$

ដោយ ស្វ៊ែ (S) មានផ្ចិត $M(-1,0,1)$ $\Rightarrow\ a=-1,\ b=0,\ c=1$

ហើយ ស្វ៊ែ(S) កាត់តាមចំណុច N គេបាន $r=MN=\sqrt{1^2+1^2+1^2}=\sqrt{3}$

ដូចនេះ **សមីការស្តង់ដានៃស្វ៊ែ(S) គឺ $(x+4)^2+y^2+(z-1)^2=3$**

លឹម សីហា

ប្លង់ α ជួបនឹងស្វ៊ែ S ឬទេ

បើស្វ៊ែ S ជួបនឹងប្លង់ α លុះត្រាតែ

ចម្ងាយពីផ្ចិតនៃស្វ៊ែS ទៅប្លង់(α) គឺតូចជាងឬស្មើ កាំr នៃស្វ៊ែS

- ប្លង់ $(\alpha):\ x-2y+z-4=0$
- ផ្ចិតស្វ៊ែគឺ $M(-1,0,1)$

គេបាន

$$D(M,(\alpha))=\frac{|-1-2(0)+1-4|}{\sqrt{1^2+(-2)^2+1^2}}=\frac{4}{\sqrt{6}}=\sqrt{\frac{16}{6}}=\sqrt{\frac{8}{3}}<r$$

ដូចនេះ **ប្លង់α ជួបស្វ៊ែ S**

VI. ១. a. គណនាលីមីត f ត្រង់ $-\infty$ និង $+\infty$

$$\lim_{x\to-\infty} f(x) = \lim_{x\to-\infty}\left(x+2-\frac{4e^x}{e^x+3}\right) = -\infty + 2 - \frac{4(0)}{0+3} = -\infty$$

ដូចនេះ $\boxed{\lim_{x\to-\infty} f(x) = -\infty}$

$$\lim_{x\to+\infty} f(x) = \lim_{x\to+\infty}\left(x+2-\frac{4e^x}{e^x+3}\right) = \lim_{x\to+\infty}\left(x+2-\frac{4}{1+\frac{3}{e^x}}\right) = +\infty$$

ដូចនេះ $\boxed{\lim_{x\to+\infty} f(x) = +\infty}$

b. សិក្សាទីតាំងនៃក្រាប C ធៀបនឹងបន្ទាត់ $d_1 :\ y = x+2$

$(C):\ y_c = x+2-\dfrac{4e^x}{e^x+3}\quad ;\quad (d_1):\ y_d = x+2$

គេបាន $y_c - y_d = x+2-\dfrac{4e^x}{e^x+3} - (x+2) = -\dfrac{4e^x}{e^x+3} < 0 \quad \forall x \in \mathbb{R}$

**ដូចនេះ** $\boxed{\text{គ្រប់ } x \in (-\infty,+\infty) \text{ ក្រាប } (C) \text{ ស្ថិតនៅក្រោមបន្ទាត់ } (d_1)}$

២. a. ស្រាយបញ្ជាក់ថាចំពោះគ្រប់ចំនួនពិត $x$, $f'(x) = \left(\dfrac{e^x-3}{e^x+3}\right)^2$

$$f'(x) = \left(x+2-\frac{4e^x}{e^x+3}\right)' = 1 - \frac{4e^x(e^x+3)-(e^x+3)'4e^x}{(e^x+3)^2}$$

$$= 1 - \frac{4e^{2x}+12e^x-4e^{2x}}{(e^x+3)^2} = 1 - \frac{12e^x}{(e^x+3)^2} = \frac{e^{2x}+6e^x+9-12e^x}{(e^x+3)^2}$$

$$= \frac{e^{2x}-6e^x+9}{(e^x+3)^2} = \frac{(e^x-3)^2}{(e^x+3)^2}$$

**ដូចនេះ** $\boxed{f'(x) = \left(\dfrac{e^x-3}{e^x+3}\right)^2}$

b. សិក្សាអថេរភាពនៃ f លើ $\mathbb{R}$

ដោយ $f'(x) = \left(\dfrac{e^x-3}{e^x+3}\right)^2 \geq 0 \quad \forall \in \mathbb{R}$

$$f'(x) = 0 \quad \Leftrightarrow \quad e^x - 3 = 0 \quad \Rightarrow \quad x = \ln 3$$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $\ln 3$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $+$ | |

គេបាន អនុគមន៍f ជាអនុគមន៍កើនជានិច្ចលើ $x \in \mathbb{R}$

តារាងអថេរភាពនៃf

$$x = \ln 3 \quad \Rightarrow \ f(\ln 3) = \ln 3 + 2 - \frac{4e^{\ln 3}}{e^{\ln 3}+3} = \ln 3 + 2 - \frac{4\times 3}{3+3} = \ln 3$$

| $x$ | $-\infty$ | | $\ln 3$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $\ln 3$ | ↗ | $+\infty$ |

៣. a. ចំពោះបន្ទាត់ប៉ះ $d_2$ ទៅនឹងក្រាបC ត្រង់ចំណុចI ដែលមានអាប់ស៊ីស $\ln(3)$

គេបាន $d_2 : \ y = f'(\ln 3)(x - \ln 3) + f(\ln 3)$

ដោយ $f'(x) = \left(\frac{e^x - 3}{e^x + 3}\right)^2 \quad \Rightarrow \ f'(\ln 3) = \left(\frac{e^{\ln 3} - 3}{e^{\ln 3} + 3}\right) = \frac{3-3}{3+3} = 0$

មេគុណប្រាប់ទិសនៃបន្ទាត់ $d_2$ គឺ ស្មើ $0$

$\Rightarrow d_2 : \ y = f(\ln 3) = \ln 3$ ជាបន្ទាត់ដេកស្របនឹងអ័ក្សអាប់ស៊ីស

**ដូចនេះ** បន្ទាត់ $d_2 : \ y = \ln 3$

b. សិក្សាទីតាំងនៃក្រាប C ធៀបនឹងបន្ទាត់ប៉ះ $d_2$

$$(C) : \ y_c = x + 2 - \frac{4e^x}{e^x + 3} \quad ; \quad (d_2) : \ y_d = \ln 3$$

តាមតារាងអថេរភាព យើងបាន

- $x \in (-\infty, \ln 3)$ គឺ ក្រាប $(C)$ ស្ថិតនៅក្រោមបន្ទាត់ $d_2$
- $x \in (\ln 3, +\infty)$ គឺ ក្រាប $(C)$ ស្ថិតនៅលើបន្ទាត់ $d_2$

- $x = \ln 3$ គឺ ក្រាប (C) កាត់បន្ទាត់ $(d_2)$

៤. a. បង្ហាញថាបន្ទាត់ប៉ះ $d_3$ មានរាង $y = \frac{1}{4}x + 1$

ដោយ $d_3$ ប៉ះ C ត្រង់ចំណុចមានអាប់ស៊ីសសូន្យ គេបាន

$d_3 : \ y = f'(0)(x-0) + f(0)$

- $f'(x) = \left(\frac{e^x - 3}{e^x + 3}\right)^2 \quad \Rightarrow \ f'(0) = \left(\frac{1-3}{1+3}\right)^2 = \frac{1}{4}$
- $f(x) = x + 2 - \frac{4e^x}{e^x + 3} \quad \Rightarrow \ f(0) = 2 - \frac{4}{1+3} = 1$

គេបាន $d_3 : \ y = \frac{1}{4}x + 1$ ពិត **ដូចនេះ** $\boxed{d_3 : \ y = \frac{1}{4}x + 1}$

b. សង់ក្រាប C និងបន្ទាត់ $d_1, d_2, \ d_3$



# វិញ្ញាសាគណិតវិទ្យាត្រៀមប្រឡង
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨

## [វិញ្ញាសាទី១០]

I. (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to1}\dfrac{1-x^2}{x^2+2-3x}$ ខ. $\lim\limits_{x\to3}\dfrac{\sqrt{x+6}-3}{x^3-27}$ គ. $\lim\limits_{x\to0}\dfrac{5\sin5x}{x}$

II. (១០ពិន្ទុ) គេឲ្យចំនួនកុំផ្លិច $a=2\sqrt{3}-2i$ និង $b=-\sqrt{2}+i\sqrt{2}$ ។

១. សរសេរ $Z=a^2+b^2+4ai+\sqrt{2}b$ ជាទម្រង់ពីជគណិត។

២. សរសេរ $a, b$ និង $ab$ ជាទម្រង់ត្រីកោណមាត្រ។

III. (១០ពិន្ទុ) គេប្រើលេខពី 0 ដល់ 9 ដើម្បីសរសេរចំនួនដែលមានលេខ 4 ខ្ទង់ ដោយខ្ទង់ដើមដំបូងមិនប្រើលេខ 0 ទេ។

១. តើគេអាចសរសេរបានប៉ុន្មានចំនួនខុសៗគ្នាតាមរបៀបខាងលើនេះ?

២. តើមានប៉ុន្មានចំនួនដែលមានលេខទាំង 4 ខ្ទង់ខុសៗគ្នា?

៣. តើមានប៉ុន្មានចំនួនដែលមានលេខទាំង 4 ខ្ទង់ដូចគ្នា?

IV. (១៥ពិន្ទុ) គេឲ្យអនុគមន៍ $f(x)=\dfrac{3x^2-5x-2}{x(x-1)^2}$ ចំពោះគ្រប់ $x$ ដែល $x\neq0,\ x\neq1$។

១. កំណត់ចំនួនពិត $a, b\,;\,c$ ដើម្បីឲ្យបាន $f(x)=\dfrac{a}{x}+\dfrac{b}{x-1}+\dfrac{c}{(x-1)^2}$ ចំពោះគ្រប់ $x\neq0, x\neq1$។

២. គណនា $I=\displaystyle\int_2^3 f(x)dx$ ។

V. (២៥ពិន្ទុ)

1. ក្នុងលំហប្រដាប់ដោយតម្រុយ $\left(o,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច $A(-2,1,0)$ , $B(0,1,1)$ , $C(1,2,2)$ និង $D(0,3,-4)$។

a. រកវ៉ិចទ័រ $\overrightarrow{AB},\ \overrightarrow{AC},\ \overrightarrow{AD},\ \overrightarrow{BC},\ \overrightarrow{BD}, \overrightarrow{CD}$ ។

b. គណនាប្រវែង AB, AC, AD, BD និង CD ។ ទាញបង្ហាញថាត្រីកោណ ABD និង ACD កែងត្រង់ A ។

2. គេមានសមីការ $9y^2 - 16x^2 = 144$ ។ បង្ហាញថាសមីការនេះជាសមីការអ៊ីពែបូល។ រកកូអរដោនេរបស់កំពូលទាំងពីរ និង កំណុំទាំងពីរនៃអ៊ីពែបូល។ រកសមីការអាស៊ីមតូតរបស់អ៊ីពែបូលនេះ និងសង់អ៊ីពែបូលនេះ។

VI. (២០ពិន្ទុ) គេមានអនុគមន៍ f កំណត់ចំពោះ $x > 0$ ដោយ $y = f(x) = \dfrac{x + \ln x}{x}$ និងមានខ្សែកោង C ។

១. គណនាដេរីវេ $f'(x)$ ។ បង្ហាញថា f មានតម្លៃអតិបរមាមួយ ហើយគណនាតម្លៃអតិបរមានោះ។

២. គណនាលីមីត $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ ។ កំណត់សមីការនៃអាស៊ីមតូតឈរ និងដេកនៃក្រាបC។ សង់តារាងអថេរភាពនៃអនុគមន៍ f។

VII. (៣០ពិន្ទុ) អនុគមន៍ f កំណត់ចំពោះ $x > 0$ ដោយ $y = f(x) = 1 - \dfrac{2\ln x}{x}$ ហើយមានក្រាប C ។

១. រក $\lim\limits_{x\to +\infty} f(x)$ និង $\lim\limits_{x\to 0} f(x)$ ។ រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប C ។

២. គណនាដេរីវេ $f'(x)$ ហើយសង់តារាងអថេរភាពនៃអនុគមន៍ f ។

៣. សង់ក្រាប C នៅក្នុងតម្រុយកូអរដោនេមួយ។ គេឲ្យ $e = 2.7$, $\dfrac{2}{e} = 0.7$ ។

៤. គណនាផ្ទៃក្រឡាផ្ទៃកប្លង់កំណត់ដោយក្រាប C អាស៊ីមតូតដេក បន្ទាត់ឈរ $x = 1$ និង $x = e$ ។

លឹម សីហា

I. គណនាលីមីត៖

ក. $\lim\limits_{x\to 1}\dfrac{1-x^2}{x^2+2-3x}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to 1}\frac{(1-x)(1+x)}{(x-1)(x-2)}=\lim_{x\to 1}\frac{-(x-1)(1+x)}{(x-1)(x-2)}=\lim_{x\to 1}\frac{-(1+x)}{x-2}=\frac{-(1+1)}{1-2}=2$$

ដូចនេះ $\boxed{\lim\limits_{x\to 1}\dfrac{1-x^2}{x^2+2-3x}=2}$

ខ. $\lim\limits_{x\to 3}\dfrac{\sqrt{x+6}-3}{x^3-27}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to 3}\frac{\left(\sqrt{x+6}-3\right)\left(\sqrt{x+6}+3\right)}{\left(x^3-3^3\right)\left(\sqrt{x+6}+3\right)}=\lim_{x\to 3}\frac{x+6-9}{(x-3)\left(x^2+3x+9\right)\left(\sqrt{x+6}+3\right)}$$

$$=\lim_{x\to 3}\frac{1}{\left(x^2+3x+9\right)\left(\sqrt{x+6}+3\right)}=\frac{1}{(9+9+9)\left(\sqrt{9}+3\right)}=\frac{1}{162}$$

ដូចនេះ $\boxed{\lim\limits_{x\to 3}\dfrac{\sqrt{x+6}-3}{x^3-27}=\dfrac{1}{162}}$

គ. $\lim\limits_{x\to 0}\dfrac{5\sin 5x}{x}$ (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to 0}25\cdot\frac{\sin 5x}{5x}=25\times 1=25$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{5\sin 5x}{x}=25}$

II. ១. សរសេរ $Z=a^2+b^2+4ai+\sqrt{2}b$ ជាទម្រង់ពីជគណិត

ដោយ $a=2\sqrt{3}-2i$ ; $b=-\sqrt{2}+i\sqrt{2}$

គេបាន $Z=a^2+b^2+4ai+\sqrt{2}b$

$$=\left(2\sqrt{3}-2i\right)^2+\left(-\sqrt{2}+i\sqrt{2}\right)^2+4\left(2\sqrt{3}-2i\right)i+\sqrt{2}\left(-\sqrt{2}+i\sqrt{2}\right)$$

$$=4(3)-8\sqrt{3}i+4i^2+2-2(2)i+2i^2+8\sqrt{3}i-8i^2-2+2i$$

$$=14-2i$$

$\boxed{Z=14-2i}$

២. សរសេរ a, b និង ab ជាទម្រង់ត្រីកោណមាត្រ

- ដោយ $a = 2\sqrt{3} - 2i = 4\left(\frac{\sqrt{3}}{2} - \frac{1}{2}i\right) = 4\left(\cos\frac{11\pi}{6} + i\sin\frac{11\pi}{6}\right)$

ដូចនេះ ទម្រង់ត្រីកោណមាត្រនៃa គឺ $a = 4\left(\cos\frac{11\pi}{6} + i\sin\frac{11\pi}{6}\right)$

- ដោយ $b = -\sqrt{2} + i\sqrt{2} = 2\left(-\frac{\sqrt{2}}{2} + \frac{\sqrt{2}}{2}i\right) = 2\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)$

ដូចនេះ ទម្រង់ត្រីកោណមាត្រនៃb គឺ $b = 2\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)$

- ដោយ $ab = \left(4\left(\cos\frac{11\pi}{6} + i\sin\frac{11\pi}{6}\right)\right)\left(2\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)\right)$

$$= 8\left(\cos\left(\frac{11\pi}{6} + \frac{3\pi}{4}\right) + i\sin\left(\frac{11\pi}{6} + \frac{3\pi}{4}\right)\right) = 8\left(\cos\frac{31\pi}{12} + i\sin\frac{31\pi}{12}\right)$$

$$= 8\left(\cos\left(2\pi + \frac{7\pi}{12}\right) + i\sin\left(2\pi + \frac{7\pi}{12}\right)\right) = 8\left(\cos\frac{7\pi}{12} + i\sin\frac{7\pi}{12}\right)$$

ដូចនេះ ទម្រង់ធរណីមាត្រនៃab គឺ $ab = 8\left(\cos\frac{7\pi}{12} + i\sin\frac{7\pi}{12}\right)$

III. ១. រកចំនួនរបៀបដែលគេអាចបង្កើតចំនួនដែលមានលេខ4 ខ្ទង់

លេខដែលយកមកប្រើមាន $0, 1, 2, 3, 4, 5, 6, 7, 8, 9$ មាន១០ករណី

ហើយខ្ទង់នីមួយៗអាចដូចគ្នា យើងបាន

- ខ្ទង់ដើមដំបូងមិនប្រើលេខ 0 $\Rightarrow$ ខ្ទង់ដើមដំបូងអាចមាន តែ 9 ករណី
- ខ្ទង់បន្ទាប់អាច មាន 10 ករណី
- ខ្ទង់បន្ទាប់ទៀតអាច មាន 10 ករណី
- ខ្ទង់ចុងក្រោយអាច មាន 10 ករណី

យើងបាន ចំនួនរបៀបដែលគេអាចបង្កើនចំនួនដែលមានលេខ4ខ្ទង់ គឺ $9 \times 10 \times 10 \times 10 = 9000$

ដូចនេះ ចំនួនសរុបគឺ 9000 ចំនួន

២. រកចំនួនដែលលេខទាំង4ខ្ទង់ខុសៗគ្នា

- ខ្ទង់ដំបូងមិនយក 0 អាចមាន 9 ករណី
- ខ្ទង់បន្ទាប់អាចមាន 9 ករណី
- ខ្ទង់បន្ទាប់ទៀតអាចមាន តែ 8 ករណី
- ខ្ទង់ចុងក្រោយអាចមាន តែ 7 ករណី

យើងបាន ចំនួនសរុបនៃចំនួនដែលខ្ទង់ទាំងអស់ខុសៗគ្នា គឺ $9 \times 9 \times 8 \times 7 = 4536$

ដូចនេះ **ចំនួនសរុបនៃចំនួនដែលខ្ទង់ទាំងអស់ខុសៗគ្នា គឺ 4536 ចំនួន**

៣. រកចំនួនដែលលេខទាំង4 ខ្ទង់ដូចៗគ្នា

ចំនួនដែលលេខទាំង4 ខ្ទង់ដូចៗគ្នា មាន $\{(1111);\ (2222);\ (3333);\ (4444);$

$(5555);\ (6666);\ (7777);\ (8888);\ (9999)\}$

សរុប មាន 9 ចំនួន

ដូចនេះ **ចំនួនដែលលេខទាំង 4 ខ្ទង់ដូចៗគ្នា មាន 9 ចំនួន**

IV. ១. កំណត់ចំនួនពិត a, b ; c ដើម្បីឲ្យបាន $f(x) = \frac{a}{x} + \frac{b}{x-1} + \frac{c}{(x-1)^2}$

យើងមាន $f(x) = \dfrac{3x^2-5x-2}{x(x-1)^2}$

$$f(x) = \frac{a}{x} + \frac{b}{x-1} + \frac{c}{(x-1)^2} \quad \Leftrightarrow \quad \frac{3x^2-5x-2}{x(x-1)^2} = \frac{a}{x} + \frac{b}{x-1} + \frac{c}{(x-1)^2}$$

$$= \frac{a(x-1)^2 + bx(x-1) + cx}{x(x-1)^2}$$

$$= \frac{ax^2 - 2ax + a + bx^2 - bx + cx}{x(x-1)^2}$$

$$= \frac{(a+b)x^2 + (-2a-b+c)x + a}{x(x-1)^2}$$

$$\Longrightarrow \begin{cases} a + b = 3 & (1) \\ -2a - b + c = -5 & (2) \\ a = -2 \end{cases}$$

យក $a=-2$ ជំនួសក្នុងសមីការ (1) យើងបាន $-2+b=3 \Rightarrow b=5$

$$(2):\ -2(-2)-5+c=-5 \quad \Rightarrow c=-4$$

ដូចនេះ $\boxed{a=-2,\ b=5,\ c=-4}$

២. គណនា $I=\displaystyle\int_2^3 f(x)dx$

យើងមាន $f(x)=\dfrac{a}{x}+\dfrac{b}{x-1}+\dfrac{c}{(x-1)^2}=-\dfrac{2}{x}+\dfrac{5}{x-1}-\dfrac{4}{(x-1)^2}$

$$\Rightarrow I=\int_2^3 f(x)dx=\int_2^3\left(-\frac{2}{x}+\frac{5}{x-1}-\frac{4}{(x-1)^2}\right)dx$$

$$=\left[-2\ln|x|+5\ln|x-1|-4\frac{-1}{x-1}\right]_2^3$$

$$=-2\ln 3+5\ln 2+\frac{4}{2}-\left(-2\ln 2+5\ln 1+\frac{4}{1}\right)$$

$$=-2\ln 3+7\ln 2-2$$

ដូចនេះ $\boxed{I=7\ln 2-2\ln 3-2}$

លឹម សីហា

V. 1. a. រកវ៉ិចទ័រ $\overrightarrow{AB},\ \overrightarrow{AC},\ \overrightarrow{AD},\ \overrightarrow{BC},\ \overrightarrow{BD},\ \overrightarrow{CD}$

យើងមាន $A(-2,1,0)$ , $B(0,1,1)$ , $C(1,2,2)$ និង $D(0,3,-4)$ គេបាន

$$\overrightarrow{AB}(0-(-2),1-1,1-0) \quad \Rightarrow \overrightarrow{AB}(2,0,1)$$

$$\overrightarrow{AC}(1-(-2),2-1,2-0) \quad \Rightarrow \overrightarrow{AC}(3,1,2)$$

$$\overrightarrow{AD}(0-(-2),3-1,-4-0) \quad \Rightarrow \overrightarrow{AD}(2,2,-4)$$

$$\overrightarrow{BC}(1-0,2-1,2-1) \quad \Rightarrow \overrightarrow{BC}(1,1,1)$$

$$\overrightarrow{BD}(0-0,3-1,-4-1) \quad \Rightarrow \overrightarrow{BD}(0,2,-5)$$

$$\overrightarrow{CD}(0-1,3-2,-4-2) \quad \Rightarrow \overrightarrow{CD}(-1,1,-6)$$

b. គណនាប្រវែង AB, AC, AD, BD និង CD

$AB=\left|\overrightarrow{AB}\right|=\sqrt{2^2+0^2+1^2}=\sqrt{5}$ ឯកតាប្រវែង

$AC=\left|\overrightarrow{AC}\right|=\sqrt{3^2+1^2+2^2}=\sqrt{14}$ ឯកតាប្រវែង

$$AD = \left|\overrightarrow{AD}\right| = \sqrt{2^2 + 2^2 + (-4)^2} = \sqrt{24} = 2\sqrt{6}$$ ឯកតាប្រវែង

$$BD = \left|\overrightarrow{BD}\right| = \sqrt{0^2 + 2^2 + (-5)^2} = \sqrt{29}$$ ឯកតាប្រវែង

$$CD = \left|\overrightarrow{CD}\right| = \sqrt{(-1)^2 + 1^2 + (-6)^2} = \sqrt{38}$$ ឯកតាប្រវែង

ទាញបង្ហាញថាត្រីកោណ ABD និង ACD កែងត្រង់ A

យើងមាន $\overrightarrow{AB}(2,0,1)$; $\overrightarrow{AD}(2,2,-4)$; $\overrightarrow{AC}(3,1,2)$

- ដោយ $\overrightarrow{AB}\cdot\overrightarrow{AD} = 2(2)+0(2)+1(-4) = -4 = 0 \quad \Rightarrow \overrightarrow{AB}\perp\overrightarrow{AD}$ ត្រង់ A

  **ដូចនេះ** ABD ជាត្រីកោណកែងត្រង់ A

- ដោយ $\overrightarrow{AC}\cdot\overrightarrow{AD} = 3(2)+1(2)+2(-4) = 8-8 = 0 \quad \Rightarrow \overrightarrow{AC}\perp\overrightarrow{AD}$ ត្រង់ A

  **ដូចនេះ** ACD ជាត្រីកោណកែងត្រង់ A

2. បង្ហាញថាសមីការ $9y^2 - 16x^2 = 144$ ជាសមីការអ៊ីពែបូល

$$9y^2 - 16x^2 = 144 \Leftrightarrow \frac{9y^2}{144} - \frac{16x^2}{144} = \frac{144}{144}$$

$$\Leftrightarrow \frac{y^2}{16} - \frac{x^2}{9} = 1$$

$$\Leftrightarrow \frac{(y-0)^2}{4^2} - \frac{(x-0)^2}{3^2} = 1$$ ជាសមីការអ៊ីពែប៉ូលមានផ្ចិត $(0,0)$

រកកូអរដោនេរបស់កំពូលទាំងពីរ កំណុំទាំងពីរនៃអ៊ីពែបូល និងរកសមីការអាស៊ីមតូតរបស់អ៊ីពែបូល

ដោយ អ៊ីពែបូលមានសមីការ $\frac{(y-0)^2}{4^2} - \frac{(x-0)^2}{3^2} = 1$ គេបាន

- អ័ក្សទទឹងជាអ័ក្សឈរ
- $h = 0;\ k = 0;\quad a = 4;\ b = 3;\quad c^2 = a^2 + b^2 = 16 + 9 = 25 \Rightarrow c = \sqrt{25} = 5$
- កំពូលគឺ $V_1(h, k-a);\ V(h, k+a) \quad \Rightarrow \boxed{V_1(0,-4);\ V_2(0,4)}$
- កំណុំគឺ $F_1(h, k-c);\ F_2(h, k+c) \quad \Rightarrow \boxed{F_1(0,-5);\ F_2(0,5)}$
- អាស៊ីមតូតគឺ $y = k - \frac{a}{b}(x-h)$ និង $y = k + \frac{a}{b}(x-h)$ $\boxed{y = -\frac{4}{3}x \text{ និង } y = \frac{4}{3}x}$

សង់អ៊ីពែបូលនេះ




VI. ១. គណនាដេរីវេ $f'(x)$

$$y=f(x)=\frac{x+\ln x}{x}$$

$$f'(x)=\left(\frac{x+\ln x}{x}\right)'=\frac{(x+\ln x)'\,x-x'\,(x+\ln x)}{x^2}=\frac{x+1-x-\ln x}{x^2}=\frac{1-\ln x}{x^2}$$

ដូចនេះ $\boxed{f'(x)=\frac{1-\ln x}{x^2}}$

បង្ហាញថា f មានតម្លៃអតិបរមាមួយ ហើយគណនាតម្លៃអតិបរមានោះ

$f'(x)=\frac{1-\ln x}{x^2}$ ដោយ $x^2>0 \Rightarrow f'(x)$ មានសញ្ញាដូចភាគយក $1-\ln x$

- $f'(x)=0 \Leftrightarrow \quad 1-\ln x=0 \quad \Rightarrow -\ln x=-1 \quad \Rightarrow \ln x=1 \Rightarrow x=e$
- $f'(x)>0 \Leftrightarrow \quad 1-\ln x>0 \quad \Rightarrow -\ln x>-1 \quad \Rightarrow \ln x<1 \Rightarrow x<e$
- $f'(x)<0 \Leftrightarrow \quad 1-\ln x<0 \quad \Rightarrow -\ln x<-1 \quad \Rightarrow \ln x>1 \Rightarrow x>e$

លឹម សីហា

យើងបាន តារាងសញ្ញា $f'(x)$ គឺ

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | $\|\|$ | $+$ | $0$ | $-$ | |

- ត្រង់ $x = e$ ; $f'(x) = 0$ ហើយប្តូរសញ្ញាពី$+$ ទៅ $-$ យើងបាន $f$ មានតម្លៃអតិបរមាធៀបមួយ គឺ

$$\boxed{f(e) = \frac{e + \ln e}{e} = 1 + \frac{1}{e}}$$

២. គណនាលីមីត $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$

$$y = f(x) = \frac{x + \ln x}{x}$$

- $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+} \left(\frac{x + \ln x}{x}\right) = -\infty$ ដូចនេះ $\boxed{\lim\limits_{x\to 0^+} f(x) = -\infty}$

- $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty} \left(\frac{x + \ln x}{x}\right) = \lim\limits_{x\to +\infty} \left(1 + \frac{\ln x}{x}\right) = 1$

ដូចនេះ $\boxed{\lim\limits_{x\to 0^+} f(x) = 1}$

លីម សីហា

កំណត់សមីការនៃអាស៊ីមតូតឈរ និងដេកនៃក្រាប$C$

- ដោយ $\lim\limits_{x\to 0^+} f(x) = -\infty$ ដូចនេះ $\boxed{\text{បន្ទាត់}x = 0 \text{ ជាអាស៊ីមតូតឈរ}}$

- ដោយ $\lim\limits_{x\to +\infty} f(x) = 1$ ដូចនេះ $\boxed{\text{បន្ទាត់}y = 1 \text{ ជាអាស៊ីមតូតដេក}}$

តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | $\|\|$ | $+$ | $0$ | $-$ | |
| $f(x)$ | $\|\|$ $-\infty$ | $\nearrow$ | $1 + \frac{1}{e}$ | $\searrow$ | $1$ |

VII. ១. រក $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to 0} f(x)$

ដោយ $y = f(x) = 1 - \dfrac{2\ln x}{x}$ គេបាន

$$\lim_{x\to+\infty} f(x) = \lim_{x\to+\infty}\left(1 - \frac{2\ln x}{x}\right) = 1 - 0 = 1 \quad \boxed{\lim_{x\to+\infty} f(x) = 1}$$

$$\lim_{x\to 0} f(x) = \lim_{x\to 0}\left(1 - \frac{2\ln x}{x}\right) = 1 - (-\infty) + \infty \quad \boxed{\lim_{x\to 0} f(x) = +\infty}$$

រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប C

- ដោយ $\lim\limits_{x\to 0} f(x) = +\infty$ ដូចនេះ $\boxed{x = 0 \text{ ជាអាស៊ីមតូតឈរ}}$
- ដោយ $\lim\limits_{x\to+\infty} f(x) = 1$ ដូចនេះ $\boxed{y = 1 \text{ ជាអាស៊ីមតូតដេក}}$

២. គណនាដេរីវេ $f'(x)$

ដោយ $y = f(x) = 1 - \dfrac{2\ln x}{x}$ គេបាន

$$f'(x) = \left(1 - \frac{2\ln x}{x}\right)^2 = \frac{-2(\ln x)'x - x'(-2\ln x)}{x^2} = \frac{-2 + 2\ln x}{x^2}$$

$$\boxed{f'(x) = \frac{-2 + 2\ln x}{x^2}}$$

សង់តារាងអថេរភាពនៃអនុគមន៍ f

សញ្ញាf′(x)

$f'(x) = \dfrac{-2 + 2\ln x}{x^2}$ មានសញ្ញាតាមភាគយក ព្រោះ $x^2 > 0; \quad \forall x \in (0, +\infty)$

- $f'(x) = 0 \quad \Leftrightarrow -2 + 2\ln x = 0 \Rightarrow \ln x = 1 \Leftrightarrow x = e = 2.7$
- $f'(x) > 0 \quad \Leftrightarrow -2 + 2\ln x > 0 \Rightarrow \ln x > 1 \Leftrightarrow x > 2.7$
- $f'(x) < 0 \quad \Leftrightarrow -2 + 2\ln x < 0 \Rightarrow \ln x < 1 \Leftrightarrow x < 2.7$
- $f(2.7) = f(e) = 1 - \dfrac{2\ln e}{e} = 1 - \dfrac{2}{e} = 1 - 0.7 = 0.3$

គេបាន តារាងអថេរភាពនៃf

| $x$ | $0$ | | $2.7$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | ‖ | $+\infty$ ↘ | $0.3$ | ↗ $1$ | |

៣. សង់ក្រាប C នៅក្នុងតម្រុយកូអរដោនេ




៤. គណនាផ្ទៃក្រឡាផ្ទៃកប្លង់កំណត់ដោយក្រាប C អាស៊ីមតូតដេក បន្ទាត់ឈរ $x = 1$ និង $x = e$

ពេល $x \in [2, e]$ ក្រាប C ស្ថិតក្រោម បន្ទាត់ $y = 1$ គេបាន

$$S = \int_1^e [1 - f(x)]\, dx = \int_1^e \frac{2\ln x}{x} dx = \int_1^e 2\,(\ln x)' \ln x dx$$

$$= \left[2\frac{\ln^2 x}{2}\right]_1^e = \ln^2 e - \ln^2 1 = 1^2 - 0^2 = 1$$

ដូចនេះ $\boxed{S = 1 \text{ ឯកតាផ្ទៃ}}$